**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# កំណែទម្រង់ពន្ធដារ
# នៅក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ប៊ុន ម៉េងហ៊ុក**

**កៅ ស៊ិនឆុង**

សាស្ត្រាចារ្យណែនាំ

លោក **ឡាញ់ ជា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# **សេចក្តីថ្លែងអំណរគុណ**

ឃឃឃ📖ឃឃឃ

ខ្ញុំបាទឈ្មោះ **ម៉ុន ម៉េងហ៊ុក** និងខ្ញុំបាទឈ្មោះ **កៅ ស៊ិនឆុង** យើងខ្ញុំទាំងពីរជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ ថ្នាក់អាហារូបករណ៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០១៨ ។

**សូមលំឱនកាយវាចាចិត្តដើម្បីសម្តែងការគោរព ការដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ ៖**

**លោកឪពុក ម៉ុន ហៀង** **លោកឪពុក កៅ គីមសៀ**

**អ្នកម្តាយ ឌួង ឧសភា** **អ្នកម្តាយ នង សុវត្ថិឌី**

ដែលបានផ្តល់កំណើតសម្រាប់ការរស់នៅ និងការសិក្សារបស់កូនៗរហូតទទួលបានការបញ្ចប់ការសិក្សាដោយជោគជ័យ។ គុណូបការៈរបស់លោកទាំងបួនមានទំហំធំធេង ពលីកម្មគ្រប់បែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវភាពកក់ក្តៅ សេចក្តីស្រលាញ់អនុគ្រោះ ព្រហ្មវិហារធម៌ និងអប់រំទូន្មានឱ្យដើរតាមគន្លងធម៌។ មិនតែប៉ុណ្ណោះ លោកទាំងបួនបានទំនុកបម្រុងថវិកា និងសិក្ខាបករណ៍ចាប់តាំងពី កម្រិតបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សា ធ្វើអោយកូនៗចងចាំជានិច្ចមិនអាចបំភ្លេចបាន។

ចំពោះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន** ដែលជាអគ្គមគ្គុទ្ទេសន៍ដ៏ឆ្នើម រួមជាមួយសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានបង្កឱ្យមានកាលានុវត្តភាពដ៏គាប់ប្រសើរ និងជម្រុញអោយសង្គមកម្ពុជាមានវឌ្ឍនភាពគ្រប់វិស័យទាំងអស់ រួមទាំងវិស័យអប់រំផងដែរ ។

ចំពោះ **ក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានបង្កើតនូវកន្លែងផ្តល់ចំណេះដឹងដល់ប្រជាជនគ្រប់ៗរូប ដោយយកចំណេះ និងជំនាញទាំងនោះមកអភិវឌ្ឍខ្លួន និងស្វែងរកមុខរបរចិញ្ចឹមជីវិតដោយខ្លួនឯងប្រកបដោយសមធម៌ សុចរិត និងប្រកបដោយតម្លាភាពចំពោះមុខច្បាប់។ លើសពីនេះទៅទៀត យើងខ្ញុំក៏សូមធ្វើការអរគុណយ៉ាងក្រៃលែងចំពោះអាហារូបករណ៍រយៈពេលបួនឆ្នាំក្នុងសាកលវិទ្យាល័យមួយនេះ ដែលបានមកពី **ក្រសួងអប់រំ យុវជន និងកីឡា**។

ចំពោះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល **គង់ វិបុល** ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និង មន្ត្រីគ្រប់ជាន់ថ្នាក់ដែលបម្រើការក្នុងអគ្គនាយកដ្ឋាន ដែលបានជួយសម្រួលដល់ការសិក្សាស្រាវជ្រាវ ក៏ដូចជាផ្តល់ជាកន្លែងសម្រាប់ស្រាវជ្រាវ និងផ្តល់ជាឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងប្រធានបទមួយនេះផងដែរ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោក លោកស្រីទាំងអស់** ដែលជាសាស្ត្រាចារ្យបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនអប់រំទូន្មាន លះបង់ពេលវេលា ព្រមទាំងកម្លាំងកាយចិត្ត ក្នុងការដឹកនាំ និងណែនាំដល់យើងខ្ញុំទាំងពីរ ក្នុងរយៈពេល៤ឆ្នាំមកនេះ ដើម្បីអោយយើងខ្ញុំទាំងពីរ មានសមត្ថភាពយល់ដឹងផ្នែកនីតិសាស្ត្រ លើបញ្ហានានា ដែលពាក់ព័ន្ធទៅនឹងផ្នែកច្បាប់នៅក្នុងប្រទេស ព្រមទាំងច្បាប់អន្តរជាតិថែមទៀតផង ។

ចំពោះ លោកសាស្ត្រាចារ្យ **ឡាញ់ ដា** ជាសាស្ត្រាចារ្យ ដែលបានផ្តល់ការណែនាំដល់ការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ និងបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីធ្វើការណែនាំផ្តល់យោបល់ និងកែតម្រូវកំហុសឆ្គងនានា ក្នុងគោលបំណងជួយឱ្យសារណាបញ្ចប់ការសិក្សាមួយនេះ ប្រសូតចេញជារូបរាងឡើង និង ទទួលបានជោគជ័យ ។

ចំពោះ លោក **ញ៉ិន ឧុត្តី** ប្រធានការិយាល័យ គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារ នៃនាយកដ្ឋាននីតិកម្ម ដែលបានទទួលស្វាគមន៍នៃការចុះទៅស្រាវជ្រាវយ៉ាងកក់ក្តៅ និងជួយសម្រួលបញ្ហាផ្សេងៗ ក៏ដូចជាផ្តល់យោបល់ និងគំនិតដ៏មានតម្លៃជាច្រើនចំពោះសារណាបញ្ចប់ការសិក្សាមួយនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរ សូមថ្លែងអំណរគុណ និងសូមប្រសិទ្ធិពរជ័យដល់វត្ថុសក្តិសិទ្ធិក្នុងលោក សូមជួយថែរក្សាដល់លោកទាំងអស់ដែលបានរៀបរាប់ខាងលើ ជួបតែពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លាតឡើយ ព្រមទាំងឧទ្ទិសដល់ទេវតា ឥន្ទព្រហ្មជួយឱ្យប្រទេសជាតិរបស់យើង រួមទាំងប្រជាជនទាំងអស់ជួបតែសន្តិភាព សុវត្ថិភាព និងមានការអភិវឌ្ឍន៍រីកចម្រើនឆ្ពោះទៅមុខជានិរន្តន៍ ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២៣ ផ្នែកនីតិសាស្ត្រ ថ្នាក់អាហារូបករណ៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៤ ដល់ ២០១៨ បានចំណាយរយៈពេល៤ឆ្នាំ ដ៏មានតម្លៃ ដើម្បីទទួលបាននូវចំណេះដឹងក្រោមការបង្ហាត់បង្រៀន មុខវិជ្ជានានា ពីសំណាក់សាស្ត្រាចារ្យទាំងឡាយ។

ទន្ទឹមនឹងនេះ ដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់សាស្ត្រាចារ្យ ក៏ដូចជាតម្រូវការចាំបាច់របស់សាកលវិទ្យាល័យ ដែលតម្រូវឲ្យនិស្សិតទទួលបានចំណាត់ថ្នាក់តាមការកំណត់ ត្រូវរៀបចំជាសារណា ឬរបាយការណ៍ នៅពេលបញ្ចប់ការសិក្សា និងដើម្បីទុកជាស្នាដៃ ក៏ដូចជាឯកសារសម្រាប់ប្អូននិស្សិតជំនាន់ក្រោយ ធ្វើការស្រាវជ្រាវបន្ថែម។ នៅក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំមានការចាប់អារម្មណ៍ទៅលើ វិស័យពន្ធដារនៅក្នុងប្រទេសកម្ពុជា ដែលជាហេតុជំរុញទឹកចិត្តឱ្យយើងខ្ញុំទាំងពីរនាក់រៀបចំតាក់តែង នូវសារណាបញ្ចប់ការសិក្សាមួយក្រោមប្រធានបទ **កំណែទម្រង់ពន្ធដារនៅក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា** ដែលកើតចេញពីកិច្ចខិតខំ ប្រឹងប្រែង និងការព្យាយាមរបស់ក្រុមខ្ញុំបាទ។ យើងខ្ញុំបានយកចិត្តទុកដាក់អស់ពីលទ្ធភាព សមត្ថភាព និងចំណេះដឹងដែលបានសិក្សាកន្លងមក រួមផ្សំនឹងការពិភាក្សា ក៏ដូចជាសុំយោបល់ពីសាស្ត្រាចារ្យមួយចំនួន ទើបសម្រេចបានជារូបរាង សារណាបញ្ចប់ការសិក្សាមួយនេះឡើង។

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលបានសរសេរ និងរៀបរៀងសារណានេះឡើង ក្រោមការណែនាំពីសាស្ត្រាចារ្យ **ឡាញ់ ដា**។ ស្នាដៃមួយនេះ យើងខ្ញុំសង្ឃឹមថានឹងចូលរួមចំណែកក្នុងការសម្រួលដល់និស្សិត និងមិត្តអ្នកអាន ក្នុងការពង្រីកចំណេះដឹង និងផ្តល់គំនិតបន្ថែមទៀត។

ជាទីបញ្ចប់ យើងខ្ញុំសង្ឃឹមថា មិត្តនិស្សិត និងមិត្តអ្នកអានទាំងអស់ ចូលរួមវាយតម្លៃ និងបញ្ចេញមតិរិះគន់ក្នុងន័យស្ថាបនាឲ្យបានទាំងអស់គ្នា ដើម្បីរួបរួម សាមគ្គីបំពេញចន្លោះខ្វះខាតលើកំហុសដោយអចេតនាផ្សេងៗនៅក្នុងសារណានេះ ។

# មាតិកា

ឆឆឆ📖ឈឈឈ

**ទំព័រ**


**សេចក្តីផ្តើម** ........ ០១

១. ទិដ្ឋភាពទូទៅ ........ ០១

២. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ០២

៣. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ០៤

៤. គោលបំណងនៃការស្រាវជ្រាវ ........ ០៤

៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ០៥

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ០៥

៧. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ០៦

៨. រចនាសម្ព័ន្ធនៃការស្រាវស្រាវ ........ ០៧

**ជំពូកទី១ ស្ថានភាពទូទៅនៃកំណែទម្រង់ពន្ធដារ** ........ ០៨

**កថាខណ្ឌទី១ សញ្ញាណទូទៅ** ........ ០៨

១. ប្រវត្តិពន្ធដារនៅកម្ពុជា ........ ០៨

២. គោលបំណងនៃកំណែទម្រង់ ........ ១០

៣.មូលហេតុនៃការធ្វើកំណែទម្រង់ ........ ១១

**កថាខណ្ឌទី២ ក្របខណ្ឌនៃកំណែទម្រង់ពន្ធដារ** ........ ១៣

១. ក្របខណ្ឌគោលនយោបាយ ........ ១៤

២. ក្របខណ្ឌគតិយុត្តិ ........ ២១

៣. រចនាសម្ព័ន្ធគ្រប់គ្រងនៃអគ្គនាយកដ្ឋានពន្ធដារ ........ ២៣

**ជំពូកទី២ កំណែទម្រង់មុខងាររដ្ឋបាលសារពើពន្ធសំខាន់ៗ** ........ ២៦

**កថាខណ្ឌទី១ មុខងារប្រតិបត្តិការស្នូល** ........ ២៦

១. ការចុះបញ្ជីរបស់អ្នកជាប់ពន្ធ ........ ២៦

២. ការផ្តល់សេវាជូនអ្នកជាប់ពន្ធ ........ ២៨

៣. ការចាត់ចែងលិខិតប្រកាសពន្ធ ............................................................ ៣០

៤. សវនកម្មពន្ធដារ ............................................................ ៣២

៥. ការប្រមូលបំណុលពន្ធ និងការដោះស្រាយវិវាទសារពើពន្ធ ............................................................ ៣៥

**កថាខណ្ឌទី២ មុខងារបន្ទាប់បន្សំ** ............................................................ ៣៦

១. ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ ............................................................ ៣៦

២. ការគ្រប់គ្រងធនធានមនុស្ស ............................................................ ៣៨

៣. បច្ចេកវិទ្យាព័ត៌មាន ............................................................ ៤០

**ជំពូកទី៣ កំណែទម្រង់សារពើពន្ធ និងសមិទ្ធផល** ............................................................ ៤៣

**កថាខណ្ឌទី១ កំណែទម្រង់សារពើពន្ធ** ............................................................ ៤៣

១. ពន្ធលើប្រាក់ចំណូល ............................................................ ៤៣

២. ពន្ធលើប្រាក់បៀវត្ស ............................................................ ៤៨

៣. អាករលើតម្លៃបន្ថែម ............................................................ ៤៩

៤. ពន្ធប៉ាតង់ ............................................................ ៥១

៥. ពន្ធប្រថាប់ត្រា ............................................................ ៥២

៦. ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ............................................................ ៥៣

៧. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ............................................................ ៥៥

៨. ពន្ធលើដីធ្លីមិនប្រើប្រាស់ ............................................................ ៥៧

៩. ពន្ធសត្តឃាត ............................................................ ៥៧

**កថាខណ្ឌទី២ សមិទ្ធផលនៃកំណែទម្រង់ពន្ធដារ** ............................................................ ៥៧

១. បញ្ហាប្រឈម ............................................................ ៥៧

១.១. ធនធានមនុស្ស ............................................................ ៥៧

១.២. ធនធានហិរញ្ញវត្ថុ ............................................................ ៥៨

១.៣. បទដ្ឋានគតិយុត្ត ............................................................ ៥៩

២. សមិទ្ធផល ............................................................ ៦០

២.១. ផ្នែករដ្ឋបាល ............................................................ ៦០

២.២. ការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ........................................ ៦១

**សេចក្តីសន្និដ្ឋាន** ........................................................................................ ៦៦

**អនុសាសន៍** ................................................................................................ ៦៨

**ឯកសារយោង**.................................................................................................

**ឧបសម្ព័ន្ធ** .....................................................................................................

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. និដ្ឋភាពទូទៅ

នៅក្នុងសាកលលោកយើងនេះ ការប្រមូលពន្ធកើតឡើងជាយូរអង្វែងណាស់មកហើយ ដោយផ្តើមចេញពីគោលការណ៍នៃការព្រមព្រៀងគ្នាក្នុងការបង់ពន្ធ នៅក្នុងឆ្នាំ១២១៤ នារជ្ជកាលរបស់ព្រះមហាក្សត្រ Jeam Sans Terre នៃប្រទេសអង់គ្លេស។

នៅក្នុងឆ្នាំ ១៨៩៧ ពន្ធដារនៃប្រទេសកម្ពុជាត្រូវបានបង្កើតឡើងក្រោម របបអាណានិគមនិយមបារាំង បន្ទាប់មកទៀតក្រោយឆ្នាំ១៩៩៣ ទើបប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញ ការអនុវត្តប្រព័ន្ធពន្ធដារមានរបៀបរៀបរយបន្តិច ដោយមានច្បាប់គ្រប់គ្រងត្រឹមត្រូវ។ ប្រតិបត្តិការណ៍ពន្ធដារក្នុងសម័យនោះ មានភាពស្មុគស្មាញ ចន្លោះប្រហោងច្រើន ការប្រមូលពន្ធមិនបានត្រឹមត្រូវគ្មានសុក្រឹត្យភាព និងមិនអាចបំពេញតម្រូវការចំណាយរបស់រដ្ឋបាន។ ដោយឡែកមួយទសវត្សរ៍កន្លងទៅនេះ ក្រោមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងទី៣ ការអនុវត្តពន្ធ និងការប្រមូលពន្ធ យើងឃើញថាកាន់តែមានប្រសិទ្ធិភាពជាងមុនឆ្ងាយ គួរឱ្យកត់សម្គាល់។

រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងកែសម្រួល និងរៀបចំឱ្យប្រព័ន្ធពន្ធដារកាន់តែល្អពោលគឺ ការរៀបប្រព័ន្ធពន្ធដារឱ្យមានគម្លាតគ្នាតិចបំផុតរវាងអ្នកមាន និងអ្នកក្រ។ បន្ថែមពីលើនេះ ពន្ធដារមានធាតុសំខាន់ៗពីរ គឺមូលដ្ឋានកំណត់ពន្ធ និងអត្រាពន្ធ បើយើងក្រឡេកមើលក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងធ្វើកែប្រែចំណុចទាំងពីរនេះ ឱ្យអនុវត្តទៅបានកាន់តែមានប្រសិទ្ធិភាព និងល្អប្រសើរជាងមុន ចំពោះប្រជាជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏មានភាពសាទរទៅនឹងកំណែទម្រង់នា ៤ ឬ៥ឆ្នាំកន្លងទៅនេះដែរ។ រាជរដ្ឋាភិបាលទៀតសោត ក៏មិនភ្លេចផងដែរ ក្នុងការរៀបចំរដ្ឋបាលសារពើពន្ធ ឱ្យកាន់តែមានភាពរលូនឆាប់រហ័ស និងមានប្រសិទ្ធិភាពខ្ពស់។

ជារួមគ្រប់គោលនយោបាយរបស់រាជរដ្ឋាភិបាល បង្កើតឡើងដើម្បីជំរុញឱ្យមានភាពរីកចម្រើននៅក្នុងប្រទេស និងធ្វើឱ្យមានសមភាព សមធម៌ រវាងបុគ្គលគ្រប់រូប ជាពិសេសគឺ ធ្វើឱ្យសេដ្ឋកិច្ចក្នុងប្រទេសមានការរីកចម្រើនជាលំដាប់ផងដែរ។

## ២. លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនៃប្រទេសកម្ពុជាបានបញ្ចប់ទៅ ជាងបួនទសវត្សរ៍មកនេះ ប្រទេសកម្ពុជា បានបោះជំហានយ៉ាងសន្សឹមៗទៅរកអនាគតកាលដ៏ភ្លឺស្វាង ត្រចះត្រចង់ បើយើងសង្កេតឱ្យបានជាក់លាក់ទៅ ប្រទេសកម្ពុជាបានផ្លាស់ប្តូរយ៉ាងច្រើន ពីសេដ្ឋកិច្ចបែបផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរី ពីរដ្ឋមួយដែលគ្រប់គ្រងដោយឯកបក្សប្តូរទៅជាពហុបក្ស និងមានអភិបាលកិច្ចលក្ខណៈប្រជាធិបតេយ្យសេរី ពីប្រទេសមួយមានសង្គ្រាម និងវិបត្តិនយោបាយមកជាប្រទេសមួយប្រកបដោយសុខសន្តិភាពពេញលេញ និងប្រកបដោយចីរភាព។ សមិទ្ធផលរយៈពេលពីរទសវត្សរ៍ក្រោយនេះ ប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងសន្ធឹកសន្ធាប់គួរឱ្យកត់សម្គាល់ ការរីកចម្រើនទាំងអស់នេះមិនមែនកើតឡើងដោយឯកឯងទេ វាគឺជាលទ្ធផលនៃការគិតគូរទុកជាមុន ដោយដាក់ចេញនូវយុទ្ធសាស្ត្រ និងគោលនយោបាយផ្សេងៗ ព្រមជាមួយការប្រឹងប្រែងយ៉ាងស្វិតស្វាញពីសំណាក់រាជរដ្ឋាភិបាល និងមន្ត្រីជាច្រើនរូបទៀត។

អំឡុងចុងសតវត្សរ៍៩០ ក្រោមនយោបាយ "ឈ្នះ-ឈ្នះ" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានដឹកនាំប្រទេសតាំងពីប្រទេសកម្ពុជារួចផុតពីរបបប្រល័យពូជសាសន៍មកទល់បច្ចុប្បន្ននេះ កម្ពុជាមិនត្រឹមតែសម្រេចបានឯកភាពជាតិ ការធានាបានអធិបតេយ្យជាតិ បូរណភាពទឹកដី ស្មារតីមហាសាមគ្គីជាតិ និងសុខសន្តិភាពពេញលេញនៅក្នុងប្រទេសប៉ុណ្ណោះទេ។ សេដ្ឋកិច្ចក៏មានកំណើនខ្ពស់ជាមធ្យមមានចំនួន ៧% ក្នុងមួយឆ្នាំ ហើយជីវភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកាន់តែត្រូវបានលើកកម្ពស់យ៉ាងខ្លាំងក្លា និងអត្រានៃភាពក្រីក្រ ក៏ត្រូវបានកាត់បន្ថយជារៀងរាល់ឆ្នាំរហូតដល់ជាង២% ឯនោះ។ សមិទ្ធផលដែលទទួលបានមួយនេះពិតជាទីមោទនភាព ដែលប្រទេសមានការវិវឌ្ឍន៍ទាបជាច្រើនមិនអាចសម្រេចបានដូចប្រទេសកម្ពុជា។ ឈរលើវឌ្ឍនភាពជាបន្តបន្ទាប់ ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលកម្ពុជាកាន់តែមានឆន្ទៈដ៏មុះមុត ក្នុងការបន្តវឌ្ឍនការនៃកិច្ចអភិវឌ្ឍប្រទេស ដោយដាក់ចេញនូវចក្ខុវិស័យរបស់ខ្លួន ក្នុងគោលដៅអភិវឌ្ឍកម្ពុជាឱ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍក្នុងឆ្នាំ២០៥០។

ដើម្បីសម្រេចចក្ខុវិស័យដែលប្រកបដោយមហិច្ឆតាខាងលើ និងចលនានៃការបន្តអភិវឌ្ឍ

សង្គម-សេដ្ឋកិច្ច ឱ្យប្រកបដោយចីរភាពក្នុងបរិយាការណ៍ថ្មី រាជរដ្ឋាភិបាលកម្ពុជាបានស្វះស្វែងយ៉ាងមុតមាំ ទាំងការពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងមូលធន ទាំងការរិះរកបន្ថែមនូវគោលនយោបាយថ្មីៗឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយថវិកាជាឧបករណ៍ដ៏មានសារៈសំខាន់បំផុតសម្រាប់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហានានា និងសេចក្តីត្រូវការរបស់ប្រជាជន។ ដោយហេតុថាថវិកាជាប្រភពចំបងក្នុងការអភិវឌ្ឍ ដែលរាជរដ្ឋាភិបាលត្រូវគិតគូរជាចាំបាច់ ទើបរាជរដ្ឋាភិបាលបានប្រើគ្រប់យុទ្ធសាស្ត្រដើម្បីកៀរគរចំណូលឱ្យអស់ពីលទ្ធភាព និងសក្តានុពលប្រកបដោយគុណធមិផងដែរ ក្នុងគោលដៅបង្កើនភាពជាម្ចាស់ នៃការងារអភិវឌ្ឍរបស់ខ្លួនសម្រាប់ឆ្លើយតបទៅនឹងកំណើននូវតម្រូវការចំណាយ សម្រាប់ការអភិវឌ្ឍវិស័យអាទិភាពនានាដែលមានបញ្ជាក់ក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" ជាពិសេសធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំ ៧% ឱ្យប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងរក្សាភាពរឹងមាំជាមួយនឹងវិបត្តិនានា។

ដើម្បីធានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពទាំងនេះ ក្នុងគោលដៅប្រែក្លាយកម្ពុជាឱ្យទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ក៏ដូចជាដើម្បីធានាស្ថិរភាព និងចីរភាពថវិកាសម្រាប់បម្រើការនៃចំណាយសាធារណៈចាំបាច់នានាដូចជា ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការពង្រឹងវិស័យអប់រំ ការបណ្តុះបណ្តាលជំនាញដល់យុវជន និងយុវនារី ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល ការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសំណាញ់សុវត្ថិភាពសង្គម និងការពង្រឹងគុណភាពសេវាសាធារណៈ។ល។ ហេតុដូច្នេះហើយ ទើបរាជរដ្ឋាភិបាលកម្ពុជាបានគិតគូរ និងដាក់ចេញនូវ "យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨" ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ។

ក្នុងសារណាយើងខ្ញុំនឹងធ្វើការបកស្រាយពីប្រសិទ្ធិភាពនៃការប្រមូលសារពើពន្ធ និងការធ្វើកំណែទម្រង់ពន្ធដារនៃប្រទេសកម្ពុជា ក្នុងយុទ្ធសាស្ត្រដ៏ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥ ចាប់ពីឆ្នាំ២០១៤-២០១៨។ ដើម្បីទុកជាទុនមួយសម្រាប់ប្រជាពលរដ្ឋគ្រប់រូបធ្វើការស្វែងយល់ពីកំណែទម្រង់ពន្ធដារក្នុងអាណត្តិទី៥ និងបង្ហាញពីយុទ្ធសាស្ត្រកៀរគរពន្ធនានាដ៏មានប្រសិទ្ធភាព ដែលធ្វើឱ្យប្រទេសកម្ពុជាមានវឌ្ឍនភាពជាលំដាប់។

## ៣. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះនឹងផ្តោតសំខាន់ទៅលើផ្នែកពន្ធដារ ដែលកំពុងអនុវត្តជាក់ស្តែងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ចំណោទបញ្ហាដែលត្រូវចោទសួរនៅក្នុងប្រធានបទមួយនេះមានដូចខាងក្រោមៈ

- តើពន្ធដារជាអ្វី?
- ហេតុអ្វីចាំបាច់ប្រមូលពន្ធពីប្រជាពលរដ្ឋ?
- តើពន្ធដារស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា? មានរចនាសម្ព័ន្ធយ៉ាងដូចម្តេច?
- ហេតុអ្វីចាំបាច់ធ្វើកំណែទម្រង់ពន្ធដារ?
- តើក្នុងអាណត្តិទី៥ បានធ្វើកំណែទម្រង់ពន្ធដារផ្នែកអ្វីខ្លះ?
- តើរាជរដ្ឋាភិបាលមានយុទ្ធសាស្ត្រអ្វីខ្លះក្នុងអាណត្តិទី៥នេះ ដើម្បីឱ្យទទួលសមិទ្ធផលល្អក្នុងការប្រមូលពន្ធ?
- តើកំណែទម្រង់ពន្ធដាក្នុងអាណត្តិទី៥នេះ ទទួលបានលទ្ធផលល្អដែរឬទេ មកទល់ខែសីហា ឆ្នាំ២០១៨? ហើយជួបប្រទះបញ្ហាប្រឈមអ្វីខ្លះក្នុងកំឡុងពេលអនុវត្ត?

## ៤. គោលបំណងនៃការស្រាវជ្រាវ

កត្តាដែលជម្រុញទឹកចិត្តឱ្យយើងខ្ញុំទាំងពីរនាក់ សម្រេចជ្រើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ និងតាក់តែងជាសៀវភៅ ព្រោះយើងខ្ញុំយល់ឃើញថា វាមានសារៈសំខាន់ក្នុងសង្គមបច្ចុប្បន្ន ទាំងផ្នែកសិក្សា ការអនុវត្ត ជាពិសេសចំពោះបុគ្គលដែលចង់ស្វែងយល់ផ្នែកពន្ធដារដូចយើងខ្ញុំ។ លើសពីនេះទៅទៀតកម្មវត្ថុនៃការស្រាវជ្រាវ នឹងលើកមកបង្ហាញដូចខាងក្រោមៈ

-ស្វែងយល់អំពីចរិតលក្ខណៈនៃពន្ធដារ និងប្រភេទនៃពន្ធ

-ស្វែងយល់អំពីរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ

-វិភាគវែកញែក ឬសិក្សាពីការវិវឌ្ឍន៍នៃវិស័យពន្ធក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា

-បង្ហាញពីចំណុចសំខាន់ៗដែលរាជរដ្ឋាភិបាលបានធ្វើការកែប្រែក្នុងអាណត្តិនេះ

-ធ្វើសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីរួមចំណែកក្នុងការកែលំអ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទ ស្តីពី "**កំណែទម្រង់ពន្ធដារក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា**" បានផ្តោតសំខាន់ទៅលើ ការគ្រប់គ្រងសារពើពន្ធ និងអត្រាពន្ធនៅក្នុងប្រទេសកម្ពុជា ដែរស្ថិតក្នុងអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ ដោយគិតចាប់ពីឆ្នាំ២០១៣ រហូតមកដល់ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ (ដែលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៦ នឹងប្រារព្ធឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨)។ ប្រធានបទមួយនេះយើងខ្ញុំនឹងបង្ហាញអំពី ស្ថានភាពទូទៅនៃកំណែទម្រង់ក្របខណ្ឌកំណែទម្រង់ពន្ធដារ និងការធ្វើកំណែទម្រង់ពន្ធដាររបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥ នៃផ្នែកពន្ធដារ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ផលប្រយោជន៍ដែលទទួលបានក្រោយពីបញ្ចប់ការស្រាវជ្រាវប្រធានបទនេះមានដូចតទៅ៖

- ចេះស្វែងរកប្រភពឯកសារបានត្រឹមត្រូវ និងរៀបចំចងក្រងឯកសារបង្កើតជាសារណាបញ្ចប់ការសិក្សាមួយដែលស្ថាប័ននានាទទួលស្គាល់
- ចេះរៀបចំតាក់តែង និងដឹងពីរបៀបរបបនៃការសរសេរសារណា
- បន្សល់ទុកនូវស្នាដៃ ដែលល្អមួយក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានសិក្សាអស់រយៈពេល៤ឆ្នាំ ហើយក៏ជាប្រភពឯកសារបន្ថែមមួយទៀតដើម្បីស្វែងយល់ផ្នែកពន្ធដារ សម្រាប់ប្អូនៗជំនាន់ក្រោយ និងជនរួមជាតិទាំងឡាយ
- បណ្តុះគំនិត និងបំពេញចំណេះវិជ្ជាបន្ថែមផ្នែកពន្ធដារ នៃព្រះជាណាចក្រកម្ពុជា
- ចេះវែកញែកពីផែនការប្រមូលពន្ធ និងគោលបំណងពន្ធដារដែលរាជរដ្ឋាភិបាលកំពុងអនុវត្តនៅក្នុងអាណត្តិទី៥
- យល់ដឹងបន្ថែមផ្នែកគោលនយោបាយ ដែលរាជរដ្ឋាភិបាលអនុវត្តយ៉ាងមានប្រសិទ្ធភាពលើកំណែទម្រង់នេះ
- យល់ដឹងពាក្យគន្លឹះមួយចំនួន ដែលប្រើប្រាស់ក្នុងផ្នែកពន្ធ
- យល់ដឹងពីរចនាសម្ព័ន្ធនានានៃពន្ធដារ និងអគ្គនាយកដ្ឋានពន្ធដារ។

## ៧. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឲ្យការស្រាវជ្រាវមួយនេះទទួលបានប្រសិទ្ធិភាព និងគុណភាព យើងខ្ញុំបានសិក្សាស្រាវជ្រាវទៅលើឯកសារដែលពាក់ព័ន្ធជាច្រើន និងបានប្រមូលពត៌មានផ្សេងៗមកជាមូលដ្ឋាន និងមានការចុះដល់ អគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតនៅក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។ ឯកសារនានាសុទ្ធតែមានប្រភពច្បាស់លាស់ យើងបានបែងចែកជាពីរប្រភេទគឺៈ ឯកសារចម្បង និងឯកសារបន្ទាប់បន្សំ។

❖ ឯកសារចម្បងៈ

_ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

_ ច្បាប់ស្តីពី សារពើពន្ធ ឆ្នាំ១៩៩៧

_ ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ២០០៣

_ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៤

_ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៥

_ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៦

_ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៧

_ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៨

_ យុត្តិសាស្រ្តចតុកោណ-ដំណាក់កាលទី៣

_ យុទ្ធសាស្រ្តកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ឆ្នាំ២០១៥

_ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ឆ្នាំ២០១៤

_ ឯកសារច្បាប់ផ្សេងៗដូចជា ព្រះរាជក្រម ព្រះរាជក្រឹត្យ ឬលិខិតគតិយុត្តិផ្សេងៗទៀតដែលទាក់ទងនឹងពន្ធដារ។

❖ ឯកសារបន្ទាប់បន្សំៈ

_ ឯកសារមេរៀនដែលធ្លាប់បានសិក្សាជាមួយសាស្រ្តាចារ្យទាំងឡាយ

_ ឯកសារដែលទទួលបានពីសៀវភៅទាក់ទងនឹងពន្ធដារ

_ ឯកសារបានមកពីការស្រាវជ្រាវតាមប្រព័ន្ធអីនធឺណេត

_ ឯកសារដែលបានមកពីការណែនាំរបស់សាស្ត្រាចារ្យដឹកនាំ

_ ឯកសារដែលបានមកពីការណែនាំ និងពិភាក្សាជាមួយសាស្ត្រាចារ្យជំនាញផ្សេងៗទៀត។

### ៨. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

_ សេចក្តីផ្តើម

_ ជំពូកទី១ ស្ថានភាពទូទៅនៃកំណែទម្រង់ពន្ធដារ

_ ជំពូកទី២ កំណែទម្រង់មុខងាររដ្ឋបាលសារពើពន្ធសំខាន់ៗ

_ ជំពូកទី៣ កំណែទម្រង់សារពើពន្ធ និងសមិទ្ធិផល

_ សេចក្តីសន្និដ្ឋាន

_ អនុសាសន៍

_ ឯកសារយោង

_ ឧបសម្ព័ន្ធ

# ជំពូកទី១

# ស្ថានភាពទូទៅនៃ

# កំណែទម្រង់ពន្ធដារ

# ជំពូកទី១

# ស្ថានភាពទូទៅនៃកំណែទម្រង់ពន្ធដារ

## កថាខណ្ឌទី១ សញ្ញាណទូទៅ

### ១. ប្រវត្តិពន្ធដារនៅកម្ពុជា

ការប្រមូលពន្ធមានតាំងពីសម័យបុរាណកាលមកម្លេះ ចំពោះប្រទេសកម្ពុជាការប្រមូលពន្ធបានប្រសូតឡើងតាំងពីសតវត្សទី១ នៃគ្រិស្តសករាជ ពោលគឺសម័យហ្វូណន បន្ទាប់មកបានផ្លាស់ប្តូរពីមួយសម័យទៅមួយសម័យមួយបន្តបន្ទាប់ជាច្រើនទៀត ដូចជា សម័យចេនឡា សម័យអង្គរ សម័យលង្វែក សម័យឧត្តុង្គ សម័យចតុមុខជាដើម។ ការប្រមូលពន្ធនាសម័យកាលទាំងអស់នោះបានដោយសារតែជាង ១៥០០ឆ្នាំមុន ស្តេចនៅក្នុងសម័យនោះធ្វើការប្រគល់ដីធ្លីដល់ប្រជានុរាស្ត្រដើម្បីធ្វើការកាន់កាប់ និងប្រកបរបរចិញ្ចឹមជីវិត។ ចំណេរតមកប្រជាពលរដ្ឋមានមុខរបរ និងមានដីធ្លីកាន់កាប់ហើយ យើងសង្កេតឃើញថាព្រះរាជានៅសម័យនោះ បានធ្វើការប្រមូលពន្ធពីប្រជាពលរដ្ឋដើម្បីថែរក្សានូវផលប្រយោជន៍សាធារណៈ និងអភិវឌ្ឍប្រទេសជាតិរួមគ្នា។

ពាក្យថាពន្ធនេះ សំដៅលើការប្រមូលប្រាក់ពីប្រជាជនដោយបង្ខិតបង្ខំ ឬជាចាំបាច់ដោយខានពុំបានដែលរដ្ឋត្រូវតែយក ឬប្រមូលផ្អែកលើមូលដ្ឋាន ដែលកំណត់ដោយច្បាប់ និងមានទិសដៅបំពេញរាល់ការប្រើប្រាស់របស់រដ្ឋ ក៏ប៉ុន្តែការប្រមូលពន្ធនាសម័យនោះ មានការកំណត់អត្រាពន្ធមិនបានច្បាស់លាស់ សមធម៌ និងជាក់លាក់តាមច្បាប់កំណត់ គឺច្បាប់ទាំងអស់ស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ព្រះមហាក្សត្រ ឬបុគ្គលដែលមានអំណាចខ្លាំងក្លាតែប៉ុណ្ណោះ។ លុះមកដល់ឆ្នាំ១៨៦៣ ជាសម័យអាណានិគមនិយមបារាំង មេដឹកនាំបារាំងបានកៀបសង្កត់ប្រជាជនខ្មែរគ្រប់សារពើ ទាំងពន្ធដារ ទាំងការគៀងគរប្រជាពលរដ្ឋខ្មែរទៅធ្វើជាទាហាននៅប្រទេសបារាំង និងបង្ខំមិនឱ្យប្រជាជនខ្មែររៀនភាសាកំណើតរបស់ខ្លួនទៀត ទាំងនេះជាការបិទបាំងសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរទាំងស្រុង។ ការយកពន្ធនៅក្នុងសម័យអាណានិគមនិយមបារាំងនោះ មានបរិមាណខ្ពស់ជាងចំណូល ដែលរកបានរបស់ប្រជាពលរដ្ឋ អាចនិយាយបានថា រកប្រាក់មកដើម្បីចិញ្ចឹមរដ្ឋាភិបាលបារាំងតែប៉ុណ្ណោះ។

ឆ្នាំ១៩៥៣ ជាសម័យសង្គមរាស្ត្រនិយម ដែលរួចផុតពីរបបអាណានិគមនិយមបារាំង ប្រទេសជាតិមានភាពសម្បូរសប្បាយ និងប្រពលរដ្ឋរស់នៅដោយមានភាពសុខដុមរមនា ហើយក៏មានច្បាប់គ្រប់គ្រងយ៉ាងត្រឹមត្រូវផងដែរ។ ខណៈពេលនោះប្រទេសកម្ពុជា បានក្លាយទៅជាគ្រួសាររបស់ប្រព័ន្ធច្បាប់រ៉ូម៉ាំង (អាល្លឺម៉ង់) រួចទៅហើយ។ តាមវិបាកការគ្រប់គ្រងពន្ធដារមានឫសគល់ចេញពីច្បាប់បារាំង ដោយសាររបបអាណានិគមនិយមបារាំង ទើបធ្វើឱ្យប្រទេសកម្ពុជាមានប្រព័ន្ធគ្រប់គ្រងពន្ធដារ ទោទៅរកប្រព័ន្ធច្បាប់រ៉ូម៉ាំង។

ជាអកុសលប្រទេសកម្ពុជាត្រូវបានស្ថិតនៅក្រោមរបបប្រល័យពូជសាសន៍មួយអស់រយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ រាប់ចាប់ពីថ្ងៃទី ១៧ មេសា ១៩៧៥ ដល់ ៧ មករា ១៩៧៩ ដែលប្រទេសកម្ពុជាទាំងស្រុងត្រូវបានខ្ទិចខ្ទាំ ទាំងហេដ្ឋារចនាសម្ព័ន្ធ បញ្ញាវ័ន្ត សេដ្ឋកិច្ច ច្បាប់នានា និងសេចក្ដីសុខរបស់ប្រជាពលរដ្ឋ ហេតុដូច្នេះហើយប្រព័ន្ធគ្រប់គ្រងពន្ធដារក៏មិនមានការអនុវត្តដែរ ដោយប្រជាពលរដ្ឋគ្មានទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយអ្វីៗទាំងអស់ជារបស់អង្គការ។ អង្គការ គឺជាច្បាប់គ្រប់យ៉ាង និងជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិទាំងអស់។

មកដល់ឆ្នាំ ១៩៨០ យើងសង្កេតឃើញថា នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ ជាមួយការគ្រប់គ្រងតាមច្បាប់របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ទោះជាមានបែបនេះក៏ដោយក៏ការ-គ្រប់គ្រងពន្ធ ក៏មិនទាន់មានភាពរឹងមាំល្អប្រសើរនៅឡើយទេ។ ឆ្នាំ២០០៨ នាយកដ្ឋានពន្ធជាបានដំឡើងជាអគ្គនាយកដ្ឋានពន្ធដារ ដែលមានការិយាល័យនៅរាជធានីភ្នំពេញដូចនាពេលបច្ចុប្បន្ន។[1] រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២។ សមិទ្ធផលនៃកិច្ចអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងទៅនេះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជាឆ្ពោះទៅរកសន្តិភាពយូរអង្វែង និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ និងការពង្រឹងស្ថាប័នប្រជាធិបតេយ្យ ការធានាបាននូវអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ព្រមទាំង

[1] អនុក្រឹត្យស្តីពី ការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ ១៣៩ អនក្រ-បក, ១៥ កញ្ញា ២០០៨

កែលម្អជីវភាពប្រជាពលរដ្ឋ។ យុទ្ធសាស្ត្រចតុកោណចំនួន ពីរដំណាក់កាលត្រូវបានធ្វើបច្ចុប្បន្នភាព ហើយត្រូវបានអនុវត្តដោយជោគជ័យ និងកំពុងបន្តអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលនឹងត្រូវបញ្ចប់ក្នុងឆ្នាំ២០១៨ ក្នុងនោះក៏មានការពង្រឹងផ្នែកចំណូលសារធារណៈឱ្យកាន់តែប្រសើរ ពោលការគ្រប់គ្រងចំណូលពន្ធនានា និងការបង្កើតប្រសិទ្ធិភាពនៃការអនុវត្តផងដែរ។

## ២. គោលបំណងនៃកំណែទម្រង់

ប្រទេសកម្ពុជា គឺជាប្រទេសកំពុងអភិវឌ្ឍន៍ដែលប្រកាន់យកនូវរបបទីផ្សារសេរី តាំងពីឆ្នាំ ១៩៩៣ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃប្រទេសកម្ពុជាផងដែរ។ រាជរដ្ឋាភិបាលបានប្រើគ្រប់យុទ្ធសាស្ត្រដើម្បីឱ្យប្រទេសកម្ពុជាមានការរីកចម្រើនមកទល់សព្វថ្ងៃនេះ រួមទាំងមានការបើកឱ្យធ្វើឯកជនភាវូបនីយកម្ម[2]ផងដែរ។ ជាដំបូង យើងត្រូវយល់ពីគោលបំណងគោលនយោបាយលើពន្ធដារជាមុនសិន។ គោលនយោបាយពន្ធដារ គឺបង្កើតឡើងដើម្បីប្រមូលថវិកាតាមរយៈការ-បង់ពន្ធ ក្នុងគោលគំនិតទ្រទ្រង់ស្ថាប័នរដ្ឋ អភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិឱ្យកាន់តែមានការរីកចម្រើន និងផ្តល់សេវាសាធារណៈចំពោះសង្គមជាតិឱ្យកាន់តែល្អប្រសើរឡើង លើសពីនេះទៅទៀតក៏ជួយជំរុញការបែងចែកឡើងវិញនូវចំណូល និងចំណាយ ក៏ដូចជាកែតម្រូវអសុក្រឹតភាពទីផ្សារ។

ក្នុងការគ្រប់គ្រងគោលនយោបាយសារពើពន្ធឱ្យមានលំនឹង និងមានភាពកាន់តែល្អប្រសើរ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ក្នុងការកែលម្អប្រព័ន្ធពន្ធដារ ដែលរួមបញ្ចូលទាំងពន្ធក្នុងប្រទេស ពន្ធអាករនៃពាណិជ្ជកម្មអន្តរជាតិ កែលម្អរដ្ឋបាលសារពើពន្ធ និងបង្កើននូវប្រសិទ្ធិភាពនៃការប្រមូលពន្ធពីមួយឆ្នាំទៅមួយឆ្នាំតាមប្រព័ន្ធរតនាគារ និងពង្រឹងវិស័យសារពើពន្ធ។ ពន្ធដារនេះទៀតសោត មិនមែនជារឿងអ្វីដែលស្ថិតស្ថេរនោះទេ គឺជានិច្ចជាកាលចាំបាច់ត្រូវមានការផ្លាស់ប្តូរពីមួយសម័យកាលទៅមួយសម័យកាល ដើម្បីស្វែងរកភាពកាន់តែសុក្រឹត ក្នុងការអនុវត្តយុទ្ធសាស្ត្រសេដ្ឋកិច្ចនយោបាយ និងសង្គមដែលរដ្ឋាភិបាលដាក់ចេញគ្រប់ដំណាក់កាល។

កំណែទម្រង់ពន្ធដារ ត្រូវបានធ្វើឡើងក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ច បង្កើនធនធានថវិការជួសម្រាប់តម្រូវការបន្ទាន់នានា ប្រធានស័ក្តិ ឬវិបត្តិផ្សេងៗ ដែលរដ្ឋាភិបាលអាចជួបប្រទះ

[2] ឯកជនភាវូបនីយកម្ម គឺជាការបង្វែរកម្មសិទ្ធរបស់រដ្ឋទៅជាកម្មសិទ្ធរបស់ឯកជន។

នាពេលអនាគត ហើយក៏ដើម្បីពង្រឹងរដ្ឋបាលចំណូល កាត់បន្ថយនត្ថិភាពក្នុងការបែងចែកធនធានរវាងបុគ្គលក្រីក្រ និងបុគ្គលមានធនធានជាង។ ក៏ដូចជាពង្រីកលំហាថវិកា ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងប្រទេស និងគ្រប់គ្រងបំណុលឱ្យប្រកបដោយចីរភាព ក្នុងការកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស។

## ៣. មូលហេតុនៃការធ្វើកំណែទម្រង់

ជាធម្មតារាល់សកម្មភាពទាំងអស់កើតឡើងតែងតែមានដើមចមរបស់វា ចំពោះកំណែទម្រង់ពន្ធដារក៏មាននូវមូលហេតុជាច្រើនគួរយល់ដឹងផងដែរ។ បើយោងតាមស្ថានភាពជាក់ស្តែងក្នុងប្រទេសកម្ពុជា ការកៀរគរចំណូលរបស់រដ្ឋត្រូវបានប្រព្រឹត្តឡើងដោយវិធីបីយ៉ាងផ្សេងៗគ្នា ដើម្បីផ្គត់ផ្គង់វិស័យសាធារណៈ និងវិស័យផ្សេងៗទៀត មានដូចជា៖

១. ចំណូលសារពើពន្ធ

២. ចំណូលពុំមែនសារពើពន្ធ

៣. ចំណូលមូលធន។

ចំណូលចំបងរបស់រដ្ឋ គឺបានមកពីការប្រមូលសារពើពន្ធ ប៉ុន្តែតាមការពិនិត្យមើលហិរញ្ញវត្ថុសាធារណៈជារៀងរាល់ឆ្នាំក្នុងអាណត្តិទី៤ ចាប់ពីឆ្នាំ ២០០៨ ដល់ ២០១៣មក ការប្រមូលពន្ធនៅមានកម្រិត បទប្បញ្ញត្តិមួយចំនួននៅមានចន្លោះប្រហោង ធ្វើឱ្យការប្រមូលពន្ធនៅក្នុងប្រទេសកម្ពុជាស្ថិតក្នុងស្ថានភាពមួយមានកម្រិត និងមិនអស់ពីលទ្ធភាព។ បើយើងក្រឡេកមកមើលឱ្យបានច្បាស់ថានៅក្នុងអាណត្តិមុនៗការគ្រប់គ្រងផ្នែកពន្ធដារមានលក្ខណៈស្មុគស្មាញ និងស៊ាំញ៉ាំច្រើន ទាំងក្នុងផ្នែករដ្ឋបាលសារពើពន្ធ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងប្រតិបត្តិការផ្សេងៗ ដោយមូលហេតុថានៅក្នុងការគ្រប់គ្រង និងបញ្ចូលទិន្នន័យមិនមានលក្ខណៈបច្ចេកទេស និងទំនើបកម្មនោះទេ។

មូលហេតុបន្ទាប់នោះគឺ អស្ថេរភាពនៃកំណើនសេដ្ឋកិច្ច ដែលវាក៏ជាបញ្ហាប្រឈមមួយផងដែរពោលគឺដោយសារការបង្កើនអត្រាពន្ធ ទើបបង្កើតឱ្យមានគុណវិបត្តិជាច្រើនក្នុងសេដ្ឋកិច្ច និងឈានដល់កាត់បន្ថយបរិមាណជាក់ស្តែងនៃការបង់ពន្ធក្នុងសង្គម ដូចនេះចំណូលជាក់ស្តែងរបស់រដ្ឋក៏មានការធ្លាក់ចុះ ហេតុដូច្នេះ រដ្ឋមិនអាចគ្រប់គ្រងចំណាយបានល្អទៅតាមស្ថានភាពបន្ទាន់។

ហេតុផលមួយទៀតនោះ គឺអសមធម៌ក្នុងការបែងចែកធនធានសង្គម ពោលគឺ ជនក្រីក្រទទួលបន្ទុកធ្ងន់ធ្ងរច្រើនជាងអ្នកដែលមានជីវភាពប្រសើរ ដែលជាទូទៅអ្នកមានជីវភាពល្អប្រសើរបង់ពន្ធតិចតួចតែប៉ុណ្ណោះ ពីព្រោះចំណូលមួយថ្ងៃរបស់ពួកគេមិនមែនជាកម្រៃឈ្នួល ឬជាប្រាក់បៀវត្សន៍ដូចជាជនក្រីក្រភាគច្រើន តែជាចំណូលដែលបានមកពីការប្រកបការងារដោយខ្លួនឯង ឬចំណូលពីទំនិញមិនបានរាប់បញ្ចូលសម្រាប់យកពន្ធ ទើបរដ្ឋពិបាកក្នុងការកំណត់ឱ្យបុគ្គលទាំងនោះបង់ពន្ធជូនរដ្ឋ ម្យ៉ាងទៀតដោយសារតែការកំណត់ ឬការគ្រប់គ្រងរបស់រដ្ឋបាលពន្ធដារមានភាពខ្វះចន្លោះ និងខ្សោយ ទើបអ្នកទាំងអស់នោះអាចរួចពន្ធលើប្រាក់ចំណូលខ្លះផងដែរ។ ជាការពិតណាស់មានកាសែតសារព័ត៌មានមួយចំនួនចុះផ្សាយថា ប្រជាពលរដ្ឋជាច្រើនរូបតែងតែធ្វើការស្នើសុំលើកលែងពន្ធ ដោយលើកយកហេតុផលផ្សេងៗ និងមិនបានប្រតិបត្តិច្បាប់ឱ្យបានខ្ជាប់ខ្ជួន និងត្រឹមត្រូវតាមច្បាប់កំណត់ អ្វីទាំងអស់នេះហើយជាចំណុចខ្វះខាតក្នុងការអនុវត្តផែនការប្រមូលពន្ធជាក់ស្តែងក្នុងសង្គម។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការយកពន្ធលើក្រុមអ្នកមានទ្រព្យសម្បត្តិច្រើន ឬមានអំណាច ជារួមពុំសូវមានប្រសិទ្ធិភាពទេ ដោយសារការឃុបឃិត ឬការពុំអនុវត្តច្បាប់។ ប្រការនេះនាំឱ្យមានវិវាទរវាងអ្នកមាន និងអ្នកក្រកាន់តែឆ្ងាយឡើង ជាពិសេសនាំឱ្យមានអសមធម៌ក្នុងការរស់នៅ ដែលទីបំផុតនាំឱ្យមានបញ្ហាសង្គម កើនឡើងទ្វេដង បើសិនពុំមានកំណែទម្រង់នៃការបែងចែកនេះឱ្យបានច្បាស់លាស់ទេ។

បញ្ហាបន្ទាប់ដែលបណ្តាលឱ្យមានការធ្វើកំណែទម្រង់នេះ គឺបញ្ហារដ្ឋបាល ដែលតែងតែកើតមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយការគ្រប់គ្រងពន្ធនៅខ្សោយ ហើយបញ្ហាគេចវេសពន្ធ និងអំពើពុករលួយជាដើម មានលក្ខណៈធ្ងន់ធ្ងរ។ ភាពទន់ខ្សោយក្នុងការគ្រប់គ្រងពន្ធ កើតចេញមកពីកត្តាទំនាក់ទំនងទៅវិញទៅមកជាច្រើនរួមមាន ច្បាប់នៅក្នុងប្រទេស និងនីតិវិធីស្មុគស្មាញផ្សេងៗនៃសារពើពន្ធខ្លួនឯង ប្រព័ន្ធព័ត៌មានខ្សោយ មានអំពើពុករលួយ និងគ្មានឥទ្ធិពលនយោបាយគ្រប់គ្រាន់ក្នុងការគ្រប់គ្រងចំណូលពន្ធ និងចំណាយរបស់រដ្ឋ។ ការពង្រឹង និងពង្រីកការគ្រប់គ្រងពន្ធដែលទាមទារឱ្យបង្កលក្ខណៈងាយស្រួល ដល់ការកំណត់មូលដ្ឋានពន្ធ គឺជាគោលដៅទីបីនៃកំណែទម្រង់ពន្ធ។

បញ្ហាជាច្រើនដូចដែលបានរៀបរាប់ខាងលើនេះហើយ ទើបធ្វើឱ្យមានកំណែទម្រង់ពន្ធដារកើតឡើង ដើម្បីផ្តល់ភាពងាយស្រួល ភាពយុត្តិធម៌ និងសម្រាលបន្ទុកនានាជូនប្រជាពលរដ្ឋកម្ពុជា។

## **កថាខណ្ឌទី ២ ក្របខណ្ឌនៃកំណែទម្រង់ពន្ធដារ**

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងគោលនយោបាយរបស់ខ្លួន ដើម្បីអភិវឌ្ឍប្រទេស។ នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថារាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅក្នុងជួរមន្ត្រីរាជការ ប្រតិបត្តិការរដ្ឋបាល និងធ្វើកំណែទម្រង់ផ្សេងៗទៀត លើគ្រប់វិស័យទាំងអស់មានដូចជា វិស័យអប់រំ វិស័យតុលាការ ជាពិសេសវិស័យពន្ធដារតែម្តង ក្រោមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ប្រកបដោយគតិបណ្ឌិតរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងអាណត្តិទី៥នេះ អគ្គនាយកដ្ឋានពន្ធដារ បានធ្វើកំណែទម្រង់ពន្ធដារយ៉ាងសកម្មដោយផ្តោតលើ អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រចំនួនបួនយ៉ាងរបស់រាជរដ្ឋាភិបាលកម្ពុជាគឺះ

- មិនបង្កើនអត្រាពន្ធ ឬបង្កើតពន្ធថ្មី
- ពង្រឹងច្បាប់ និងបទប្បញ្ញត្តិស្តីពី ពន្ធដារដែលមានស្រាប់
- ពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធ ឱ្យអស់សក្តានុពល ដែលមានតាមរយៈអភិបាលកិច្ចល្អ
- ធានាឱ្យបាននូវភាពងាយស្រួល សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព និងតម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូល។[3]

បន្ថែមជាមួយនឹងគោលការណ៍សំខាន់ៗនៃកំណែទម្រង់ពន្ធដារចំនួនបួនទៀតគឺះ

- ការលើកកម្ពស់វប្បធម៌បង់ពន្ធ
- ការកែលម្អការផ្តល់សេវាបង់ពន្ធ
- ការកែលម្អរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ
- ការកែលម្អអភិបាលកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធ។[4]

[3] យុទ្ធសាស្ត្រកៀគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨

[4] យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨

ក្នុងអាណត្តិទី៥ កំណែទម្រង់ដែលបានដាក់ចេញមកនេះ បានគិតគូរយ៉ាងសំខាន់ទៅលើក្របខ័ណ្ឌនយោបាយ(១) និង ក្របខ័ណ្ឌគតិយុត្តិ (២)។ អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបង្កើតឡើងដោយមានរចនាសម្ព័ន្ធ (៣) មួយច្បាស់លាស់ ក្នុងការប្រមូលពន្ធ និងអាករក្នុងស្រុក និងចូលរួមក្នុងការរៀបចំគោលនយោបាយសារពើពន្ធ សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការប្រមូលពន្ធ និងអាករ។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានធ្វើកំណែទម្រង់ពេញលេញសំខាន់ៗចំនួនពីរលើក លើប្រព័ន្ធពន្ធដារ គឺក្នុងកំឡុងឆ្នាំ១៩៩៤ និងឆ្នាំ១៩៩៧ ព្រមទាំងការកែទម្រង់បន្ទាប់បន្សំមួយចំនួនទៀតលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។

## ១. ក្របខណ្ឌគោលនយោបាយ

កំណែទម្រង់ពន្ធដារបានផ្តោតសំខាន់ទៅលើគោលនយោបាយសារពើពន្ធ ដែលជាគន្លឹះមួយដ៏មានឥទ្ធិពលក្នុងការដោះស្រាយបញ្ហា និងដើម្បីពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលរបស់រដ្ឋ។ កំណែទម្រង់គោលនយោបាយសារពើពន្ធនេះ បានកំណត់នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តមួយចំនួនរួមមាន ការលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយត្រូវបានទទួលស្គាល់ និងអនុញ្ញាតឱ្យវិនិយោគ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការកែសម្រួល និងកំណត់ចំណាត់ថ្នាក់នៃប្រភេទអ្នកជាប់ពន្ធ ទៅតាមទំហំផលរបរ ដែលត្រូវជាប់នៅក្នុងរបបស្វ័យ-ប្រកាស និងការកំណត់អាត្រាអាករពិសេសលើមុខទំនិញសំខាន់ៗមួយចំនួនជាដើម។ តាមរយៈការសិក្សាទៅលើកំណែទម្រង់ពន្ធដារនៅក្នុងក្របខ័ណ្ឌគោលនយោបាយ បានឆ្លុះបញ្ចាំងពីការដាក់វិធានការណ៍កែលម្អ និងសម្រួលនៅក្នុងការអនុវត្តលើការប្រមូលចំណូលសារពើពន្ធមានដូចខាងក្រោម៖

- អាករពិសេសលើមុខទំនិញ និងសេវាមួយចំនួន
- ការអនុវត្តអាករលើតម្លៃបន្ថែម
- របបម៉ៅការ
- ការពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តពន្ធដារដល់គម្រោងវិនិយោគ
- ពន្ធលើអចលនទ្រព្យ

- កិច្ចព្រមព្រៀងអន្តរជាតិ ពិសេសការចរចារលើកិច្ចព្រមព្រៀងស្តីពីការចៀងវាងការយកពន្ធត្រួតគ្នា
- ពន្ធលើចំណូលរូបវន្តបុគ្គល
- ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ
- ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពន្ធដារមួយចំនួន ដើម្បីធានាភាពរលូនក្នុងការអនុវត្ត ។[5]

**ក. អាករពិសេសលើទំនិញ និងសេវាមួយចំនួន**

គោលដៅសំខាន់នៃយុទ្ធសាស្ត្រនេះគឺ ដើម្បីបង្កើនចំណូលពន្ធសម្រាប់គោលបំណងរួម និងប៉ះប៉ូវដល់ការបាត់បង់ចំណូលផ្សេងៗពីការលុបបំបាត់ ឬកាត់បន្ថយអត្រាពន្ធលើពាណិជ្ជកម្មអន្តរ-ជាតិដោយសារតែ ការអនុវត្តកិច្ចព្រមព្រៀងលំហូរពាណិជ្ជកម្មដោយសេរី នៅក្នុងបណ្តាប្រទេសសហគមន៍សេដ្ឋកិច្ចអាស៊ាន និងដៃគូពាណិជ្ជកម្មសំខាន់ៗមួយចំនួនទៀតរបស់កម្ពុជា មានដូចជាសហរដ្ឋអាមេរិក ប្រទេសចិន និងប្រទេសអឺរ៉ុបជាដើម។ ការកែសម្រួលអត្រាពន្ធលើអាករពិសេសធ្វើឡើងក្នុងគោលបំណងជម្រុញឱ្យមានការកាត់បន្ថយការប្រើប្រាស់ប្រភេទទំនិញ និងសេវាមួយចំនួន ដែលបង្កផលប៉ះពាល់ទៅដល់សុខភាព សង្គម បរិស្ថាន និងភាពប្រណិត ព្រមទាំងជម្រុញការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធពន្ធដារឱ្យប្រកបដោយគណនេយ្យភាព តម្លាភាព និងតុល្យភាព។ គោលនយោបាយដែលត្រូវបានដាក់ចេញគឺ សម្រាប់ដំណោះស្រាយរយៈពេលខ្លី និងរយៈពេលមធ្យម រួមមានការត្រួតពិនិត្យឡើងវិញលើបញ្ជីប្រភេទទំនិញ ដែលត្រូវជាប់អាករពិសេសមួយចំនួន ព្រមទាំងពិចារណាពីលទ្ធភាពនៃការតំឡើងអត្រាពន្ធ និងការកែប្រែមូលដ្ឋានគិតអាករពិសេសលើមុខទំនិញ ដែលប៉ះពាល់សុខភាពមួយចំនួនដូចជា បារី ស្រា ស្រាបៀរ និងភេសជ្ជៈមានជាតិអាល់-កុល។ ក្រៅពីនេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើការសិក្សាលើការកែប្រែយន្តការយកពន្ធតាមអត្រាទៅជាការយកពន្ធតាមឯកតាជាមួយនឹងការបង់អាករពិសេសចាប់ពីកម្រិតអប្បបរមាមួយ។

[5] យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨, ៤៩

### ខ. អាករលើតម្លៃបន្ថែម

អាករលើតម្លៃបន្ថែម ត្រូវបានដាក់ចេញផែនការអនុវត្តសម្រាប់រយៈពេលខ្លី ដោយកំណត់រៀបចំកែប្រែលើអនុក្រឹត្យស្តីពី អាករលើតម្លៃបន្ថែម ដោយធ្វើការបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសដែលជាប់ពន្ធតាមរបបស្វ័យប្រកាស (ពន្ធតូច ពន្ធមធ្យម និងពន្ធធំ) ដើម្បីពង្រីកមូលដ្ឋានគិតពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត។ ក្រៅពីនេះ នៅក្នុងគោលនយោបាយ ដែលត្រូវអនុវត្តរយៈពេលមធ្យម អគ្គនាយកដ្ឋានពន្ធដារដែលជាសេនាធិការនៃរាជរដ្ឋាភិបាលត្រូវបញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យទាំងឡាយណា ដែលពុំបានចែងនៅក្នុងច្បាប់ស្តីពីសារពើពន្ធ និងច្បាប់វិសោធនកម្ម និងច្បាប់ពិសេសដ៏ទៃទៀត និងត្រូវតែបង្កើតជាយន្តការបង្វិលសង ចំពោះការទិញទំនិញនាំចេញដោយជនបរទេសនៅអាកាសយានដ្ឋានអន្តរជាតិ។

### គ. របបមៅការ

អ្នកជាប់ពន្ធតាមរបបមៅការ គឺជាអ្នកជាប់ពន្ធតូចៗ ដែលមិនស្ថិតនៅក្នុងរបបពន្ធស្វ័យប្រកាស ដែលគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យមនោះទេ។ អ្នកជាប់ពន្ធតាមរបបមៅការត្រូវបង់អាករលើផលរបរ ២% និងបង់ប្រាក់ពន្ធលើប្រាក់ចំណេញតាមអត្រាកំណើតតាមថ្នាក់ពី 0%ទៅ ២០% ជារៀងរាល់ខែ។ ការប្រមូលពន្ធតាមរបបមៅការមានបញ្ហាប្រឈមមួយចំនួនៈ

- ការបង់ប្រាក់ពន្ធមិនមានតម្លាភាព
- កម្រិតផលរបរប្រចាំឆ្នាំជាប់ពន្ធតាមរបបស្វ័យប្រកាសខ្ពស់ធ្វើអោយចំនួនអ្នកជាប់ពន្ធក្នុងរបបមៅការច្រើន
- អ្នកជាប់ពន្ធមួយចំនួនដែលត្រូវជាប់នៅក្នុងរបបស្វ័យប្រកាស ពុំមានឆន្ទៈក្នុងការចុះបញ្ជីក្នុងរបបស្វ័យប្រកាសទេ។

ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ គោលនយោបាយដែលបានដាក់ចេញ និងអនុវត្តរួមមានរៀបចំបទប្បញ្ញត្តិ សម្រាប់អ្នកជាប់ពន្ធតាមរបបមៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ

រួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណូល, ធ្វើយុទ្ធនាការផ្ទេរអ្នកជាប់ពន្ធក្នុងរបបមៅការ ដែលមានកម្រិតផលរបរត្រូវជាប់ពន្ធក្នុងរបបស្វ័យប្រកាសអោយចូលក្នុងរបបនេះ ជាមួយនឹងការរៀបចំ និងដាក់អោយអនុវត្តនូវរបបស្វ័យប្រកាស និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ ។ ដោយរបប-មៅការកាន់បញ្ជីគណនេយ្យសាមញ្ញ ហើយរបបបំព្រួញមិនមានការអនុវត្តជាក់ស្តែងទេ ទើបរបបទាំងពីរនេះត្រូវបានលុបចោល។ ដោយឡែកក្នុងពេលបច្ចុប្បន្ន ការបង់ពន្ធត្រូវបានកម្រិតនៅក្នុងរបបស្វ័យប្រកាសតែមួយទេ តែចែកជាបីថ្នាក់គឺ អ្នកជាប់ពន្ធធំ មធ្យម និងតូច ហើយរបបស្វ័យ-ប្រកាស អនុវត្ត និងកាន់បញ្ជីគណនេយ្យតាមស្តង់ដាររួមមាន៖

- តារាងតុល្យការ
- របាយការណ៍លំហូរសាច់ប្រាក់
- របាយការណ៍លទ្ធផល
- ផ្សេងៗ។ល។

### ឃ. ការពិនិត្យឡើងវិញរបបលើកទឹកចិត្តផ្នែកពន្ធដារដល់គម្រោងវិនិយោគ

ដោយស្ថានភាពនៃការវិវត្តថ្មីៗរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន រួមមាន កំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបុគ្គល និងផលិតភាពពលករមានការរីក-ចម្រើនជាលំដាប់ ជាមួយនឹង ការរៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មក្នុងគោលដៅចាប់យកវិស័យឧស្សាហកម្ម ដែលមានតម្លៃបន្ថែម និងជំនាញខ្ពស់បានតម្រូវឱ្យមានការគិតគូរ និងរៀបចំឡើងវិញនូវគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធ ដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខាងលើវិធានការចាំបាច់ដែលត្រូវដាក់ចេញ គឺការពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគដោយបញ្ចូលការលើកទឹកចិត្តពន្ធក្នុងវិសោធនកម្មបទប្បញ្ញត្តិច្បាប់នានាពាក់ព័ន្ធនឹងផ្នែកពន្ធដារ ។

### ង. កិច្ចព្រមព្រៀងអន្តរជាតិ

រាល់ការគ្រប់គ្រងប្រទេស សុទ្ធតែត្រូវការវិនិយោគដើម្បីអភិវឌ្ឍរាល់វិស័យនានាក្នុងប្រទេសរបស់ខ្លួន។ ក្នុងអាណត្តិទី៥នេះ រាជរដ្ឋាភិបាលបានបង្វែរចំណាប់អារម្មណ៍មក រកយុទ្ធសាស្ត្រទាក់ទាញវិនិយោគិនបរទេសដោយផ្តោតលើការកិច្ចព្រមព្រៀងស្តីពី ការចៀសវៀងការយកពន្ធត្រួតគ្នា គឺជាកិច្ចព្រមព្រៀងទ្វេភាគីមានលក្ខណៈស្មុគស្មាញ ដែលធ្វើឡើងក្នុងគោលដៅមួយចំនួន រួមមានៈ

- លុបចោលនូវរបាំងពន្ធសម្រាប់ការធ្វើពាណិជ្ជកម្ម និងវិនិយោគឆ្លងប្រទេស
- លុបចោល ឬបន្ថយការយកពន្ធត្រួតគ្នាលើនិវាសនជន ដែលមាននិវាសដ្ឋាននៅក្នុងប្រទេសចុះកិច្ចសន្យាទាំងពីរ
- ទប់ស្កាត់ និងប្រឆាំងអំពើចៀសវាងពន្ធ និងគេចវេសពន្ធ
- បង្កើតយន្តការដោះស្រាយជម្លោះ ដែលកើតឡើងដោយការបង់ពន្ធត្រួតគ្នា
- ធ្វើឱ្យមានភាពប្រាកដប្រជាក្នុងការបង់ពន្ធ
- ធ្វើឱ្យមានការកាត់បន្ថយមូលដ្ឋាន និងអត្រាពន្ធមួយចំនួន
- ធ្វើឱ្យមានការថយចុះនៃចំណាយ ក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធ
- លើកទឹកចិត្តឱ្យមានការហូរចូលនៃការវិនិយោគបរទេស
- ផ្លាស់ប្តូរព័ត៌មានរវាងប្រទេសចុះកិច្ចព្រមព្រៀង
- បែងចែក និងកំណត់សិទ្ធិ និងអធិបតេយ្យយកពន្ធរវាងប្រទេស ដែលចុះកិច្ចព្រមព្រៀង ។ល។

វិធានការចាំបាច់បន្ទាប់សម្រាប់ប្រទេសកម្ពុជា ក្នុងការអនុវត្តកិច្ចព្រមព្រៀង ឱ្យមានប្រសិទ្ធិភាព និងស្វែងរកការវិនិយោគពីបរទេស រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការបង្កើតកិច្ចព្រមព្រៀងអន្តរជាតិនានាក្នុងឆ្នាំខាងមុខ ដោយបង្កើនចំនួនមន្ត្រី ក៏ដូចជាបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ដំណើរការចរចារលើកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ និងជំរុញក្រុមការងារអន្តរក្រសួង ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកនាំមុខ និងក្រុមការងារបច្ចេកទេសដើម្បីរៀបចំធ្វើ ការចរចារកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ជាពិសេសប្រទេសជាសមាជិកអាស៊ាន។

ចំណុចសំខាន់មួយទៀតគឺ រៀបចំបទប្បញ្ញត្តិដែលពាក់ព័ន្ធ ក្នុងគោលបំណង ធ្វើវិសោធនកម្មបទប្បញ្ញត្តិ ដែលខ្វះចន្លោះទាំងនោះ និងបន្តការពង្រឹងសមត្ថភាពស្ថាប័ន រួមទាំងធនធានមនុស្សផងដែរ។

### ច. ពន្ធលើអចលនទ្រព្យ

ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ត្រង់មាត្រា ១៣ បានចែងថាៈ ការប្រមូលពន្ធលើអចលនទ្រព្យមានវិសាលភាពអនុវត្តទូទាំងប្រទេសកម្ពុជា ចំពោះអចលនទ្រព្យណាដែលមានតម្លៃលើសពី ១០០ លានរៀល តាមអត្រាពន្ធ ០.១% និងមូលដ្ឋានគិតពន្ធត្រឹមតែ ៨០% នៃតម្លៃអចលនទ្រព្យសរុប។ ពន្ធនេះត្រូវបានអនុវត្តក្នុងគោលបំណងសម្រាប់ប្រើប្រាស់ជាថវិការាជធានី-ខេត្ត។ ប៉ុន្តែមកទល់នឹងពេលបច្ចុប្បន្ននេះ ការអនុវត្តពុំទាន់មានប្រសិទ្ធភាពខ្ពស់ និងមានវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជានៅឡើយទេ ដោយហេតុថា ពន្ធនេះត្រូវបានអនុវត្តជាក់ស្តែងតែនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងនៅតាមបណ្តាក្រុងនៃខេត្តតែប៉ុណ្ណោះ។ ថែមពីលើនេះ អចលនទ្រព្យមួយចំនួននៅមិនទាន់បានប្រកាសបង់ពន្ធនៅឡើយ ហើយប្រភេទពន្ធនេះពុំទាន់ត្រូវបានធ្វើសវនកម្ម និងមិនទាន់មានវិធានការដាក់ទោសទណ្ឌចំពោះម្ចាស់អចលនទ្រព្យដែលមិនប្រកាស និងមិនបានបង់ពន្ធនៅឡើយ។

ដើម្បីអនុវត្តផែនការគោលនយោបាយបង្កើនចំណូលសារពើពន្ធនេះ ពន្ធលើអចលនទ្រព្យត្រូវតែបង្កើនប្រសិទ្ធភាពក្នុងអនុវត្ត អគ្គនាយកដ្ឋានពន្ធដារដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមាន ការចុះធ្វើសវនកម្ម និងការអនុវត្តវិធានច្បាប់ឱ្យបានតឹងរឹងចំពោះម្ចាស់អចលនទ្រព្យណាដែលបានប្រកាសបង់ពន្ធមិនត្រឹមត្រូវ និងមិនទាន់ដាក់លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យរបស់ខ្លួន។ ការប្រមូលពន្ធត្រូវតែមានការពង្រីកកិច្ចសហការ ជាមួយនឹងក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងពង្រីកវិសាលភាពនៃការអនុវត្តឱ្យដល់គ្រប់ទីប្រជុំជនស្រុក ទីប្រជុំជនសំខាន់ៗ និងតំបន់អភិវឌ្ឍន៍តាមព្រំដែន និងបន្តបន្ទាប់ទូទាំងប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះត្រូវកែលម្អការផ្តល់សេវានិងផ្តល់ការសម្រួលដល់អ្នកជាប់ពន្ធ ជាពិសេសយន្តការបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមប្រព័ន្ធធនាគារ និងប្រព័ន្ធអេឡិចត្រូនិក។

### ឆ. ពន្ធលើចំណូលរូបវន្តបុគ្គល

ពន្ធលើចំណូលរូបវន្តបុគ្គល ដែលមានលក្ខណៈពេញលេញ គឺជាពន្ធផ្ទាល់ ដែលបង់តាមរបបស្វ័យប្រកាសប្រចាំឆ្នាំហើយតម្រូវឱ្យរូបវន្តបុគ្គលម្នាក់ៗធ្វើការគណនាប្រាក់ពន្ធ (ចំណូលជាប់ពន្ធគុណ និងអត្រាពន្ធ) និងដាក់លិខិតប្រកាសមករដ្ឋបាលសារពើពន្ធដោយខ្លួនឯង។ ចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គលកើតឡើងពីប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ ដែលបានធ្វើការកាត់កងចំណាយនានា និងត្រូវគណនាដោយដកចេញនូវការលើកលែងពន្ធ និងការបន្ធូរបន្ថយពន្ធដែលកំណត់ដោយច្បាប់។

ក៏ប៉ុន្តែមកដល់បច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានបទប្បញ្ញត្តិ និងយន្តការគាំទ្រ ដើម្បីអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលឱ្យបានពេញលេញនៅឡើយទេ ដែលជាហេតុធ្វើអោយប្រទេសកម្ពុជាបាត់បង់នូវសក្តានុពលចំណូលពីរូបវន្តបុគ្គលនេះ។

ជាដំណោះស្រាយឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ វិធានការចាំបាច់ដែលត្រូវដាក់ចេញនោះគឺការសិក្សាអំពីការរៀបចំបទប្បញ្ញត្តិ និងយន្តការគាំទ្រទាំងឡាយសម្រាប់ត្រៀមឱ្យអនុវត្តពន្ធលើចំណូលរូបវន្តបុគ្គលដែលមានលក្ខណៈពេញលេញ។

### ជ. ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ

ការយកពន្ធលើវិស័យប្រេងកាត និងធនធានរ៉ែដែលជាវិស័យថ្មីនេះ តម្រូវឱ្យមន្ត្រីពន្ធដារមានជំនាញខ្ពស់ និងមានបទប្បញ្ញត្តិគ្រប់គ្រាន់សម្រាប់ការអនុវត្ត។ ដោយមើលឃើញពីបញ្ហាទៅលើវិស័យថ្មីនេះ បទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ស្របតាមបទប្បញ្ញត្តិក្នុងជំពូកទី៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលបានបញ្ញត្តទាក់ទិននឹងប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ នៅក្នុងបូរណភាពទឹកដី និងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពស់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗ

ទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ។[6] ក្រៅពីបទប្បញ្ញត្តិទាំងនេះ យន្តការគាំទ្រទៅនឹងការអនុវត្តពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ក៏មានប្រកាសឱ្យប្រើដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៥៣៦ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត ក្នុងគោលបំណងដើម្បីធានានូវប្រសិទ្ធិភាពក្នុងការគ្រប់គ្រងប្រមូលពន្ធលើវិស័យប្រេងកាត និងធនធានរ៉ែ។[7]

### ឈ. ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពន្ធដារ

កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់ពេញលេញសំខាន់ៗចំនួនពីរលើកលើប្រព័ន្ធពន្ធដារក្នុងឆ្នាំ ១៩៩៤ និង ១៩៩៧ ព្រមទាំងកំណែទម្រង់បន្ទាប់បន្សំមួយចំនួនទៀតលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។ បច្ចុប្បន្នដោយសារសេដ្ឋកិច្ច មានការរីកចម្រើន និងបរិការណ៍នៃស្ថានភាពអភិវឌ្ឍន៍ប្រទេសមានការប្រែប្រួលគួរឱ្យកត់សម្គាល់បានទាមទារឱ្យអគ្គនាយកដ្ឋានពន្ធដារ ត្រូវធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពី សារពើពន្ធ ឱ្យសមស្របក្នុងគោលបំណងបំពេញបន្ថែមនូវចំណុចខ្វះខាត និងភាពមិនច្បាស់លាស់នៃមាត្រាមួយចំនួននៅក្នុងបទប្បញ្ញត្តិនានាទាក់ទងនឹងផ្នែកពន្ធដារនេះ។

## ២. គ្រប់ខណ្ឌគតិយុត្តិ

អនុលោមតាមមាត្រា ៥៧ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ចែងថា "ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់" បន្ថែមពីលើនេះទៀត មាត្រា ៩០ថ្មី(ពីរ) កថាខណ្ឌទី២ បានបញ្ញត្តិថា "រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និងការបង្កើត កែប្រែឬលុបចោលពន្ធដារ"។ ដែលសបញ្ជាក់ថាគោលការណ៍នីត្យានុកូលភាពនៃពន្ធដារទាំងអស់ ត្រូវអនុម័តដោយរដ្ឋសភា ដែលគោរពទៅតាមច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។

[6] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧

[7] ប្រកាសស្តីពីការណែនាំអនុវត្តបទប្បញ្ញត្តិពីពន្ធលើប្រតិបត្តិការប្រេងកាត, ០៤ មិថុនា ២០១៨, ប្រការ១

ពន្ធដារមានច្បាប់មួយសម្រាប់គ្រប់គ្រងផ្នែកសារពើពន្ធគឺ ច្បាប់ស្តីពី សារពើពន្ធ ឆ្នាំ១៩៩៣ និងបានធ្វើវិសោធនកម្មច្បាប់នេះនៅក្នុង ឆ្នាំ២០០៣។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានជាច្រើនស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន រួមទាំងអគ្គនាយកដ្ឋានពន្ធដារ ដូចនេះ អគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្ត និងគោរពនូវនីតិវិធីនានា ដែលក្រសួងបានរៀបរៀងឡើង ក៏ដូចជាបទដ្ឋានគតិយុត្តិដែលចូលជាធរមាននានា។ ចំណេរតមក សមទ្ធផលនៃការប្រមូលពន្ធមិនមានការវិវឌ្ឍន៍ ហើយអត្រាពន្ធនេះទៀតសោត ត្រូវមានការកែសម្រួលជាចាំបាច់ ទៅតាមសភាពជាក់ស្តែងនៃស្ថានភាពប្រទេស ដើម្បីបំពេញតម្រូវការចំណាយរបស់រដ្ឋក្នុងការអភិវឌ្ឍប្រទេស។ ដូច្នេះហើយទើបរាជរដ្ឋាភិបាល ត្រូវធ្វើការកែប្រែនូវគោលនយោបាយ និងបទដ្ឋានគតិយុត្តិមួយចំនួនទាក់ទងនឹងពន្ធដារ ស្របពេលដែលបទបញ្ជា និងបទប្បញ្ញត្តិថ្មីៗមួយភាគត្រូវបានបន្ថែម។ ក្នុងគោលបំណងធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលចំណូលពន្ធ ហើយទទួលបានលទ្ធផលតាមគោលដៅ ដែលបានគ្រោងទុក និងដើម្បីធានាឱ្យបាននូវការគ្រប់គ្រងចំណូលពន្ធកាន់តែមានតម្លាភាព និងគណនេយ្យភាព ព្រមទាំងដើម្បីផ្តល់ការលើកទឹកចិត្តដល់សហគ្រាសតូចៗ ពិសេសសម្រាលបន្ទុកប្រជាពលរដ្ឋ និងប្រជាកសិករ ដែលមានប្រាក់ចំណូលទាប នៅក្នុងអាណត្តិទី៥នេះ។

បទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីសារពើពន្ធត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ដោយមូលហេតុថា ការធ្វើវិសោធនកម្មច្បាប់ ស្តីពីសារពើពន្ធមួយទាំងមូល មាននីតិវិធីស្មុគស្មាញច្រើន ចំណាយពេលច្រើន បទប្បញ្ញត្តិដែលត្រូវកែសម្រួលមានតិចតួចក្នុងការសម្របតាមបរិបទសង្គមតែប៉ុណ្ណោះ ដូច្នេះវាការបន្លាយពេលវេលា ធ្វើឱ្យមិនអាចអនុវត្តបានទាន់ពេលវេលា។ ទើបធ្វើឱ្យការកែសម្រួលវាក្យសព្ទ ការកែសម្រួលមាត្រាមួយចំនួន និងការបន្ថែមឬលុបចោលបទបញ្ញត្តិនានាត្រូវមកចែងនៅក្នុង ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំនីមួយៗ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុវិញ ដើម្បីពន្លឿនការអនុវត្ត ឱ្យបានឆាប់រហ័ស និងងាយស្រួល។ ឧទាហរណ៍ៈ ឆ្នាំ២០១៥ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ មាត្រា១១ ចែងពីការកែសម្រួល ប្រាក់បៀវត្សប្រចាំខែត្រូវជាប់ពន្ធ នៃមាត្រា៤៧ នៃច្បាប់ស្តីពីសារពើពន្ធ ហើយអ្នកជាប់ពន្ធទាំងអស់ត្រូវអនុវត្តតាម មាត្រា១១ នៃច្បាប់នេះផងដែរ។

បន្ថែមលើនេះទៀត អត្រាពន្ធ និងប្រតិបត្តិការផ្សេងៗនៃរដ្ឋបាលសារពើពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារត្រូវអនុវត្តតាមច្បាប់ និងបទបញ្ញានានាដែលចូលជាធរមានរបស់អគ្គនាយកដ្ឋាន និង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបទបញ្ញារបស់រាជរដ្ឋាភិបាល រួមទាំងបទប្បញ្ញត្តិគតិយុត្តិជាធរមាននានានៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិផងដែរ។ នៅក្នុងប្រទេសកម្ពុជាមានកិច្ចព្រៀងផ្នែកពន្ធដារជាច្រើន ដែលបានធ្វើការចុះកិច្ចព្រមព្រៀងជាមួយប្រទេសមួយចំនួន ចំពោះការមិនយកពន្ធត្រួតគ្នា ជាមួយប្រទេសថៃ វៀតណាមជាដើម។ ឧទាហរណ៍៖ ក្នុងឆ្នាំ២០១៦កន្លងទៅនេះ ប្រទេសកម្ពុជា បានចុះកិច្ចព្រមព្រៀងជាមួយនឹងប្រទេសសឹង្ហបុរី ស្ថិតក្រោមប្រធានបទ ចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល នៃបុគ្គលនិវាសនជននៃរដ្ឋទាំងពីរ ដែលជាភាគី ។

## ៣. រចនាសម្ព័ន្ធគ្រប់គ្រងនៃអគ្គនាយកដ្ឋានពន្ធដារ

នាយកដ្ឋានពន្ធដារ ត្រូវបានតម្លើងជា អគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងឆ្នាំ២០០៨ ហើយនៅក្នុងអាណត្តិទី៥នេះ អគ្គនាយកដ្ឋានពន្ធដារក៏មានការបន្ថែមនាយកដ្ឋានថ្មីមួយចំនួនផងដែរ។[8]

ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារត្រូវបានបន្ថែមនាយកដ្ឋានថ្មី ដោយរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារនាពេលបច្ចុប្បន្នមាននាយកដ្ឋានចំណុះចំនួន ១១ នៅក្នុងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ដែលមានដូចខាងក្រោម៖

- ថ្នាក់កណ្តាល៖
  - នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
  - នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក

[8] អនុក្រឹត្យ ស្តីពី ការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ ១៣៤ អនក្រ-បក, ១៥ កញ្ញា ២០០៨

- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

❖ អង្គភាពមូលដ្ឋាន៖

- នៅខណ្ឌនានានៃរាជធានីភ្នំពេញ និងខេត្តនីមួយៗ មានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួន មានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ។
- នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យនៃសាខាពន្ធដារខេត្ត-ខណ្ឌ និងដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ជាជំនួយការ



*ប្រភព៖ ប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ,*

*លេខ ១២៣២ សហវ.ប្រក, ៣០ វិច្ឆិកា ២០១៧*

# ជំពូកទី២

# កំណែទម្រង់មុខងារ

# រដ្ឋបាលសារពើពន្ធ

# សំខាន់ៗ

# ជំពូកទី២

# កំណែទម្រង់មុខងាររដ្ឋបាលសារពើពន្ធសំខាន់ៗ

គ្រប់សកម្មភាពទាំងអស់នៃរដ្ឋបាលសារពើពន្ធ ជាផ្នែកសំខាន់បំផុតដែលត្រូវយកចិត្តទុកដាក់ជាចំបង ប្រតិភូរាជរដ្ឋាភិបាលនៃអគ្គនាយកដ្ឋានពន្ធដារ ក៏មិនបានព្រងើយកណ្តើយលើចំណុចនេះដែរ ដោយចាប់ផ្តើមធ្វើកំណែទម្រង់លើ មុខងារប្រតិបត្តិការស្នូល (កថាខណ្ឌទី១) និងមុខងារបន្ទាប់បន្សំផ្សេងៗទៀត (កថាខណ្ឌទី២)។

## កថាខណ្ឌទី១ មុខងារប្រតិបត្តិការស្នូល

មុខងារប្រតិបត្តិការស្នូល គឺជាប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងសេវាផ្សេងៗនៅក្នុងការប្រព្រឹត្តទៅនានា ដូចជា ការចុះបញ្ជី (១) ការផ្តល់សេវា (២) ការចាត់ថៃង (៣) សវនកម្ម (៤) ការប្រមូលបំណុល និងការដោះស្រាយវិវាទសារពើពន្ធ (៥)។

### ១. ការចុះបញ្ជីរបស់អ្នកជាប់ពន្ធ

ប្រសិទ្ធភាពនៃការចុះបញ្ជី និងការគ្រប់គ្រងបញ្ជីអ្នកជាប់ពន្ធពីមុននៅមានកម្រិត ដោយសារបញ្ហាប្រឈមមួយចំនួនដូចជា ការបញ្ជូនទិន្នន័យលើការចុះបញ្ជីអ្នកជាប់ពន្ធមកថ្នាក់កណ្តាលនៅមិនទាន់មានលក្ខណៈស្វ័យប្រវត្តិ និងទាន់ពេលវេលា ដោយសារគម្រោងទី២ នៅមិនទាន់បញ្ចប់នៅឡើយ។ ហើយព័ត៌មានអំពីក្រុមហ៊ុនមួយចំនួនមានភាពមិនត្រឹមត្រូវ (ដូចជា អាសយដ្ឋានរបស់ក្រុមហ៊ុនពុំមានកំណត់ច្បាស់លាស់) ដោយសារការផ្តល់ព័ត៌មានមិនមានភាពច្បាស់លាស់ពីក្រសួងពាណិជ្ជកម្ម និងក្រសួង ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ និងបញ្ហានៃការខកខានមិនបានលុបចេញពីបញ្ជីអ្នកជាប់ពន្ធ (Deregistration) បន្ទាប់ពីបានធ្វើការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីចំនួនពីរលើកក្នុងឆ្នាំ ២០០២ និង២០០៥ ចំពោះក្រុមហ៊ុនមួយចំនួនដែលបានបាត់ខ្លួន ឬមិនបានដកលិខិតប្រកាស។

ប្រព័ន្ធនៃការចុះបញ្ជីអ្នកជាប់ពន្ធពេញលេញមួយ ដែលគ្រប់គ្រងទិន្នន័យបានត្រឹមត្រូវ និងផ្តល់លេខអត្តសញ្ញាណកម្មសារពើពន្ធតែមួយ មានសារៈសំខាន់សម្រាប់រដ្ឋបាលសារពើពន្ធ ដើម្បីធ្វើជាមូលដ្ឋានក្នុងការចាត់ថៃងលិខិតប្រកាស ការធ្វើសវនកម្ម ការប្រមូលបំណុលពន្ធ និងការត្រួត-ពិនិត្យផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាពទៅលើអ្នកជាប់ពន្ធ។ សហគ្រាសនីតិបុគ្គល ឬក្រុម

អាជីវកម្ម ឬសហគ្រាសឯកបុគ្គលថ្មីទាំងឡាយ ដែលមិនទាន់ដំណើរការសកម្មភាពសេដ្ឋកិច្ច ឬចាប់ផ្តើមសកម្មភាពសេដ្ឋកិច្ចតិចជាង១៥ថ្ងៃ នៃថ្ងៃធ្វើការ ហើយមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ត្រូវស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ (នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ-ការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី) ដោយបច្ចុប្បន្នបច្ចេកវិទ្យាកាន់តែទំនើប បុគ្គលទាំងនោះអាចធ្វើការសុំចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីគឺ ប្រព័ន្ធអេឡិចត្រូនិច (E-registration) ក្នុងគេហទំព័រ www.cambodia.tax.gov.kh ដែលដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០១៦ ដោយផ្តល់ភាពងាយស្រួលសម្រាប់ភាគីទាំងសងខាង។[9] ទន្ទឹមនឹងនេះ ដើម្បីពង្រឹងប្រព័ន្ធនៃការចុះបញ្ជីអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានដំឡើងបណ្តាញតភ្ជាប់តំបន់ទូលាយ (Wide Area Network-WAN) ដើម្បីបញ្ជូនព័ត៌មាន និងទិន្នន័យអ្នកជាប់ពន្ធពីសាខាពន្ធដារខណ្ឌចំនួន៧ (គម្រោងទី១) និងខេត្តចំនួន១៦ (គម្រោងទី២) មកប្រមូលផ្តុំនៅអគ្គនាយកដ្ឋានពន្ធដារ។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនានានៃការចុះបញ្ជីរបស់អ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុវត្តវិធានការមួយចំនួនដូចជា៖

- បង្កើតប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីក្រុមហ៊ុនតាមរយៈប្រព័ន្ធប្រមូលផ្តុំទិន្នន័យនៅថ្នាក់កណ្តាល
- ធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ពិសេសបន្តការងារលុបឈ្មោះចេញពីបញ្ជី ចំពោះសហគ្រាសដែលបានបាត់ខ្លួន ឬសហគ្រាសមិនដាក់លិខិតប្រកាសបន្ទាប់ពីបានធ្វើការពិនិត្យរួច ការងារទាំងនេះត្រូវធ្វើជាប្រចាំដើម្បីគ្រប់គ្រងចំនួនសហគ្រាសដែលជាប់ពន្ធ
- ធ្វើការចុះត្រួតពិនិត្យ ដល់ទីតាំងរបស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីពន្ធដារ និងធ្វើយុទ្ធនាការទូទាំងប្រទេស ដើម្បីប្រមូលព័ត៌មានចុះបញ្ជីឱ្យបានច្បាស់លាស់ ដោយចុះអង្កេតស្រាវជ្រាវទិន្នន័យពីតតិយជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដើម្បីបញ្ចូលអ្នកជាប់ពន្ធទៅក្នុងបញ្ជី ឬ

[9] ប្រកាសស្តីពី ការចុះបញ្ជីពន្ធដារ, លេខ៤៩៦សហវ, ០៦ មេសា ២០១៦

ដើម្បីពិនិត្យផលរបរដែលត្រូវផ្ទេរពីរបបមៅការទៅរបបស្វ័យប្រកាស ដោយធ្វើជារៀងរាល់មួយត្រីមាសម្តង

- ធ្វើបច្ចុប្បន្នកម្មវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម(អតប) ដែលបានចេញ និងត្រៀមផ្តល់ជូនថ្មីដែលមានសុវត្ថិភាពជាងមុន
- ចូលរួមអនុវត្តយន្តការ "ដំបូលតែមួយ" ជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងពាណិជ្ជកម្ម ព្រមទាំងក្រសួងពាក់ព័ន្ធសម្រាប់កិច្ចការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម (SMEs)។

## ២. ការផ្តល់សេវាជូនអ្នកជាប់ពន្ធ

អគ្គនាយកដ្ឋានពន្ធដារ នៅមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធគឺ កង្វះផែនការយុទ្ធសាស្ត្ររួមដែលបង្ហាញពីទិសដៅ និងកម្មវិធីជាក់លាក់នៃការលើកកម្ពស់ដល់ការយល់ដឹងជាសាកលនៃវប្បធម៌បង់ពន្ធ ក៏ដូចជាការផ្តល់និងការបែងចែកធនធាននៅមិនទាន់គ្រប់គ្រាន់សម្រាប់សកម្មភាពសេវាអ្នកជាប់ពន្ធ និងនត្ថិភាពនៃការិយាល័យពិគ្រោះយោបល់ពន្ធតាមទូរស័ព្ទ ទើបធ្វើឱ្យមានការកាត់បន្ថយលទ្ធភាពក្នុងការទទួលបានព័ត៌មានលម្អិតទាក់ទងនឹងការបង់ពន្ធ ហើយប្រជាជនជាច្រើនមិនអាចទទួលបានព័ត៌មានច្បាស់លាស់។ ចំនួន និងសមត្ថភាពរបស់មន្ត្រីមិនទាន់ឆ្លើយតបទៅនឹងទំហំ នៃការងារផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធិភាពនៅឡើយ។

ការផ្តល់សេវាដល់អ្នកជាប់ពន្ធក៏ជាមុខងារសំខាន់មួយដែរ ក្នុងការជួយពង្រឹងការគោរពច្បាប់និងវប្បធម៌បង់ពន្ធ ព្រមទាំងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលពន្ធ។ បច្ចុប្បន្នការផ្តល់សេវាអ្នកជាប់ពន្ធ មានវឌ្ឍនភាពតាមរយៈការអនុវត្តផែនការពង្រឹងសេវាអ្នកជាប់ពន្ធ ដូចជារៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីពន្ធដារ ឆ្លើយសំណួរផ្ទាល់មាត់ ធ្វើជាលាយលក្ខណ៍អក្សរទៅអ្នកជាប់ពន្ធ បណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជននៅសាលាជាតិពន្ធដារ។ ព្រមទាំងការផ្តល់ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងផ្សេងៗ បទប្បញ្ញត្តិស្តីពីពន្ធដារ និងសៀវភៅណែនាំមួយចំនួន និងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ទន្ទឹមនឹងនេះ ដើម្បីបន្តពង្រឹងអភិបាលកិច្ច អគ្គនាយកដ្ឋានពន្ធដារ បានបិទផ្សាយជាសាធារណៈ ជាពិសេសនៅ

កន្លែងផ្តល់សេវា នូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈ ព្រមទាំងបានរៀបចំឱ្យមានកន្លែងទទួល ឬប្រអប់សំបុត្រទទួលបណ្តឹង ចំពោះករណីមានការអនុវត្តខុសឆ្គងពីស្តង់ដារសេវា ការយកកម្រៃលើសពីការកំណត់ ឬការយឺតយ៉ាវជាដើម។

មួយវិញទៀត ដោយឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ដែលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ យល់ឃើញថាម៉ោងធ្វើការនៃបុគ្គលិកអគ្គនាយកដ្ឋានពន្ធដារផ្តល់ភាពពិបាកដល់បុគ្គលជាប់ពន្ធមួយចំនួន ទើបឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលធ្វើការកែសម្រួលម៉ោងធ្វើការរបស់បុគ្គលិកអគ្គនាយកដ្ឋានពន្ធដារ កាលពីមុនម៉ោងធ្វើការចាប់ពីម៉ោង ៧ព្រឹក ដល់១១ព្រឹក សម្រាកបរិភោគអាហារថ្ងៃត្រង់ ទើបចូលធ្វើការម៉ោង ២ល្ងាច ដល់៥ល្ងាច ដល់ពេលបច្ចុប្បន្ននេះ ត្រូវចាប់ផ្តើមធ្វើការពីម៉ោង៨ព្រឹក ដល់ ៤:៤៥នាទីល្ងាចវិញ ដោយឈប់បរិភោគអាហារថ្ងៃត្រង់ឆ្លាស់វេនគ្នា គឺមានន័យថាត្រូវតែមានអ្នកបម្រើសេវាគ្រប់ពេលដល់អ្នកជាប់ពន្ធមកប្រើប្រាស់សេវា។[10] វាជាវិធីមួយសម្រាប់សម្រួលដល់អ្នកជាប់ពន្ធដែលគ្មានពេលវេលាគ្រប់គ្រាន់ ដើម្បីកុំឱ្យពួកគេខាតពេលវេលា ដែលមកអង្គុយចាំយ៉ាងយូរហើយពេលដល់វេនខ្លួនបែរជាម៉ោងបុគ្គលិកសម្រាកពេលថ្ងៃត្រង់ ទាំងខ្លួនក៏មានការងារត្រូវធ្វើនៅម៉ោងបន្ទាប់។

អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយបញ្ហាទាំងអស់នោះតាមវិធានការ ដូចខាងក្រោម៖

- រៀបចំ និងដាក់ឱ្យអនុវត្តផែនការផ្តល់សេវាអ្នកជាប់ពន្ធធំបំផុតចំនួន១៥០
- រៀបចំបញ្ជីសំណួរចម្លើយ ដែលត្រូវបានសួរញឹកញាប់ និងចងក្រងដាក់ចូលក្នុងសៀវភៅណែនាំ និងដាក់ក្នុងគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ
- រៀបចំបង្កើតការិយាល័យផ្តល់ព័ត៌មានតាមទូរស័ព្ទ និងការិយាល័យទំនាក់ទំនងសាធារណៈនៅនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ និងបង្កើតកន្លែងពិគ្រោះយោបល់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ
- បង្កើនចំនួនមន្ត្រីទទួលបន្ទុកសេវាអ្នកជាប់ពន្ធ និងផ្តល់ធនធាន និងមធ្យោបាយបន្ថែមសម្រាប់ការងារផ្តល់សេវាអ្នកជាប់ពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ

---

[10] ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល គង់ វិបុល (ប្រធានអគ្គនាយកដ្ឋានពន្ធដារ), បទសម្ភាសដោយBTV, http://www.tax.gov.kh/videos.php?Id=5 , នាទី ៥០

ដើម្បីបំពេញបន្ថែមនូវតម្រូវការជាក់ស្តែង និងផ្តល់សេវាអ្នកជាប់ពន្ធឱ្យមានប្រសិទ្ធិភាព ដែលមានប្រកាសជ្រើសរើសមន្ត្រីក្របខណ្ឌ និងជាប់កិច្ចសន្យាជាច្រើននាក់ប៉ុន្មានឆ្នាំកន្លងមកនេះ ទាំងទិដ្ឋភាពជាក់ស្តែងនាយកដ្ឋានថ្មី ២ ឬ៣ត្រូវបានបង្កើតបន្ថែមនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ

- បន្តអនុវត្ត និងពង្រឹងការបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈ
- បន្តរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតាមរយៈ ប្រអប់សំបុត្រ ទូរស័ព្ទ ឬអ៊ីម៉ែល ដែលមានប្រសិទ្ធភាព និងងាយស្រួលជាងមុន
- រៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំស្តីពីសេវាអ្នកជាប់បន្ធ និងសៀវភៅណែនាំស្តីពីប្រភេទពន្ធនីមួយៗ
- រៀបចំ និងផ្សព្វផ្សាយដល់សាធារណជន តាមរយៈការរៀបចំសិក្ខាសាលា សារព័ត៌មាន វិទ្យុ ទូរទស្សន៍ គេហទំព័រ ផ្ទាំងផ្សព្វផ្សាយ និងខិត្តបណ្ណផ្សព្វផ្សាយ ដើម្បីបញ្ច្រាបវប្បធម៌បង់ពន្ធ
- ពង្រឹងសមត្ថភាព និងកិច្ចសហការជាមួយផ្នែកឯកជន គណនេយ្យករ សវនករជំនាញ អ្នកច្បាប់ និងភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីពង្រឹងការគោរពច្បាប់ និងស្វែងយល់ពីតម្រូវការរបស់អ្នកជាប់ពន្ធ
- រៀបចំ និងដាក់ឱ្យអនុវត្ត នូវយុទ្ធសាស្ត្រពង្រឹងសេវាអ្នកជាប់ពន្ធ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងនោះរួមមានយន្តការសម្របសម្រួលរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន កម្មវិធីផ្តល់សេវាអ្នកជាប់ពន្ធ ការបណ្តុះបណ្តាលក្រុមមន្ត្រីបង្គោល ដែលមានជំនាញសេវាអ្នកជាប់ពន្ធ និងការផ្សព្វផ្សាយ។ល។

### ៣. ការចាត់ចែងលិខិតប្រកាសពន្ធ

អ្នកជាប់ពន្ធដែលបានចុះបញ្ជីរួច មានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ។ បញ្ហាប្រឈមមួយចំនួនគឺថា ការប្រមូលពន្ធចំពោះអ្នកជាប់ពន្ធមួយចំនួន ទាំងអ្នកជាប់ពន្ធជាប់ពន្ធធំនៅក្នុងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងអ្នកជាប់ពន្ធតូច និងមធ្យម នៅក្នុងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់មធ្យម និងតូច មិនបានដាក់លិខិតប្រកាសពន្ធ ហើយមួយចំនួនទៀតបានដាក់

លិខិតប្រកាសតែប្រកាសថា "គ្មានសកម្មភាព" ។ លើសពីនេះ ដំណើរការនៃការដាក់លិខិតប្រកាសនៅមានភាពស្មុគស្មាញច្រើន និងយឺតយ៉ាវ ដែលមិនអាចគ្រប់គ្រងហានិភ័យបានទាន់ពេលវេលា ដោយសារការដាក់លិខិតប្រកាសជាទម្រង់ក្រដាស នត្ថិភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់កំណត់ហានិភ័យនៅដំណាក់កាលដំបូង ដើម្បីធ្វើការចុះធ្វើសវនកម្មចំពោះអ្នកជាប់ពន្ធដែលមានហានិភ័យឱ្យបានទាន់ពេលវេលា បញ្ហាមួយទៀតនោះគឺ ចំនួន និងសមត្ថភាពនៃមន្ត្រីនៅក្នុងការិយាល័យចាត់ចែងលិខិតប្រកាសនៅមានកម្រិត។

អគ្គនាយកដ្ឋានពន្ធដារ បានដោះស្រាយបញ្ហា នៃការចាត់ចែងលិខិតប្រកាសពន្ធទាំងនោះ ដោយអនុវត្តវិធានមួយចំនួនដូចខាងក្រោម៖

- រៀបចំស្តង់ដារនៃរបាយការណ៍ដាក់លិខិតប្រកាសប្រចាំខែ ចំពោះគ្រប់ប្រភេទពន្ធសម្រាប់អង្គភាពនីមួយៗ
- កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាសឱ្យបានខ្ពស់ជាអតិបរិមា បន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- អនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ខែ ជាប់គ្នា
- បង់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (e-payment) ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ។
- រៀបចំយន្តការឱ្យអ្នកជាប់ពន្ធ អាចដាក់លិខិតប្រកាសពន្ធ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (e-filling) ចាប់ពីឆ្នាំ២០១៦ អគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធបង់ប្រាក់ពន្ធ និងប្រព័ន្ធទទួលប្រាក់ពន្ធថ្មី បង្កើតឡើងក្នុងគោលបំណងផ្តល់សេវាជូនអ្នកជាប់ពន្ធកាន់តែប្រសើរ និងសម្រួលដល់ការបង់ប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធកាន់តែឆាប់រហ័សជាងមុន។ អគ្គនាយកដ្ឋានពន្ធដារ បានបញ្ចូលគ្នានូវលិខិតប្រកាសប្រចាំខែ និងប្រចាំឆ្នាំដាក់លិខិតប្រកាសពន្ធ លើគេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh

ដែលអ្នកជាប់ពន្ធអាចទាញយកមកប្រើបាន ឬទៅបំពេញទម្រង់ P101 នៅឯធនាគារ គ្រាន់តែចំណាយពេលបន្តិច និងបង់ប្រាក់២០០០៛ ក្នុងការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ។ ហើយក៏អាចបំពេញព័ត៌មានក្នុងប្រព័ន្ធប្រកាសបង់ប្រាក់ពន្ធ Online របស់អគ្គនាយកដ្ឋានពន្ធដារជាមុន ហើយបោះពុម្ពលិខិតស្នើសុំបង់ប្រាក់ពន្ធដែលមាន Barcode អាចឱ្យធនាគារទាញយកព័ត៌មានដោយស្វ័យប្រវត្តិ មិនចាំបាច់ចំណាយពេលវេលាក្នុងការបញ្ចូលទិន្នន័យទៀតឡើយ។

**៤. សវនកម្មពន្ធដារ**

សវនកម្ម គឺជាការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធគ្រប់គ្រងលើទិន្នន័យរបាយការណ៍កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់សហគ្រាសមួយ ដែលធ្វើដោយនាយកដ្ឋានសវនកម្មសហគ្រាសរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងគោលបំណងកំណត់ប្រាក់ពន្ធ។ កិច្ចការសវនកម្ម ដើរតួនាទីដ៏សំខាន់ក្នុងចំណោមកិច្ចការចម្បងៗក្នុងរដ្ឋបាលសារពើពន្ធ ដែលត្រូវបានប្រើប្រាស់ក្នុងការពិនិត្យបញ្ជាក់ពីភាពស្មោះត្រង់ និងភាពត្រឹមត្រូវក្នុងការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធ របស់អ្នកជាប់ពន្ធក្នុងរបបស្វ័យប្រកាស។ សវនកម្មត្រូវបានបែងចែកជាបីប្រភេទគឺៈ[11]

- សវនកម្មលិខិតស្នាម គឺជាការពិនិត្យវិនិច្ឆ័យលើលិខិតប្រកាសសារពើពន្ធប្រចាំខែ ឬប្រចាំឆ្នាំដែលមានភាពមិនត្រឹមត្រូវ ភាពមិនប្រក្រតី និងភាពមិនស៊ីសង្វាក់គ្នានៃលិខិតប្រកាសសារពើពន្ធប្រចាំខែ និងប្រចាំឆ្នាំ។
- សវនកម្មមានកម្រិត គឺជាប្រភេទសវនកម្មដែលវិសាលភាពរបស់វាមានកម្រិត និងត្រូវធ្វើនៅទីកន្លែងអាជីវកម្មរបស់សហគ្រាស ដែលអនុវត្តដោយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខេត្ត-ខណ្ឌ និងត្រូវធ្វើឡើងក្នុងឆ្នាំចរន្តថ្មី (រយៈពេល ១២ខែ) ដោយផ្តោតលើប្រភេទពន្ធជាក់លាក់មួយចំនួន។

[11] សេចក្តីពន្យល់គតិយុត្តិស្តីពី សវនកម្មពន្ធដារ, ក្រុមការងារផ្នែកច្បាប់ និងការងារនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC), មិនបានបញ្ជាក់កាលបរិច្ឆេទ https://gmac-cambodia.org/publication_pdf_km/1505143020.pdf

- សវនកម្មពេញលេញ គឺជាសវនកម្មរួមលើពន្ធប្រាក់ចំណេញ អាករលើតម្លៃបន្ថែម អាករពិសេស និងប្រភេទពន្ធអាករផ្សេងទៀតក្នុងឆ្នាំសារពើពន្ធនីមួយៗ ដែលអ្នកជាប់ពន្ធមានកាតព្វកិច្ចត្រូវបង់តាមបទប្បញ្ញត្តិស្ដីពីពន្ធដារ។

កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានខិតខំពង្រឹងប្រសិទ្ធិភាពនៃការធ្វើសវនកម្ម តាមរយៈការកំណត់ហានិភ័យ សម្រាប់ធ្វើសវនកម្មតាមវិស័យ វិភាគហានិភ័យផ្អែកលើលិខិតប្រកាសពន្ធ របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស សហគ្រាសដែលមានឥណទានយោងខ្ពស់ ការផ្ទៀងផ្ទាត់លើវិក្កយបត្រអាករលើតម្លៃបន្ថែម ការផ្ទៀងផ្ទាត់ព័ត៌មានពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ស្ថានភាពសេដ្ឋកិច្ច និងវដ្ដរកាលអាជីវកម្ម។

ទោះជាមានការកែលម្អមួយចំនួន និងកិច្ចប្រឹងប្រែងលើការងារសវនកម្មយ៉ាងណាក៏ដោយ ក៏មានបញ្ហាប្រឈមមួយចំនួនទៀតគឺ ពុំទាន់មានសេចក្ដីណែនាំជាផ្លូវការរួមមួយក្នុងការកំណត់វិធីសាស្ត្រវាយតម្លៃហានិភ័យ និងការជ្រើសរើសអ្នកជាប់ពន្ធ ដើម្បីធ្វើសវនកម្មប្រកបដោយប្រសិទ្ធិភាព។ មិនទាន់មានផែនការរួមមួយសម្រាប់ដោះស្រាយហានិភ័យ ដែលមានលក្ខណៈខុសៗគ្នាទៅតាមវិស័យ និងមិនទាន់មានការវិភាគ និងការសិក្សាលម្អិតបន្ថែមអំពីក្រុមហ៊ុនធំៗ និងក្រុមហ៊ុន ដែលប្រកាសខាតច្រើនឆ្នាំតែមិនក្ស័យធន ហើយព័ត៌មានសម្រាប់វិភាគហានិភ័យស្ថិតនៅរាយប៉ាយគ្រប់អង្គភាពរបស់អគ្គនាយកដ្ឋានពន្ធដារ ជាមួយនឹងយន្តការលើកទឹកចិត្តមិនទាន់សមរម្យចំពោះសវនករ ដែលសម្រេចបានលទ្ធផលសវនកម្មល្អ។

ការដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តវិធានការដូចតទៅៈ

- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើសវនកម្ម និងរៀបចំសារាចរណែនាំ ដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួមដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម
- រៀបចំ និងអនុវត្តយន្តការលើកទឹកចិត្តដល់សវនករ ដោយផ្អែកលើលទ្ធផលសវនកម្មពិតប្រាកដ

- ជ្រើសរើសបន្ថែមសវនករ ទាំងក្នុងមុខងារសវនកម្មពេញលេញ និងសវនកម្មមានកម្រិត ដើម្បីបំពេញតម្រូវការជាក់ស្តែងនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌសម្រាប់ឆ្លើយតបនឹងកំណើនចំនួនសហគ្រាស និងប្រសិទ្ធិភាពការធ្វើសវនកម្ម
- រៀបចំសារាចរណែនាំចំនួន១៥ ទាក់ទិននឹងការធ្វើសវនកម្ម
- រៀបចំសៀវភៅណែនាំស្តីពី សិទ្ធិ និងកាតព្វកិច្ច របស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងសវនកម្ម ដើម្បីឱ្យអ្នកជាប់ពន្ធយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងពេលធ្វើសវនកម្ម
- រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យមុនពេលចុះសវនកម្មកន្លងមក សម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ(ដូចជាការគោរពច្បាប់ កំហុសអចេតនាការអនុវត្តខុសពីច្បាប់ ការប្រកាសពន្ធខ្វះ ការគេចវេសពន្ធធ្ងន់ធ្ងរ-ល-)
- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម
- ពង្រឹងការទទួលព័ត៌មានអ្នកជាប់ពន្ធ ឱ្យមានលក្ខណៈស្វ័យប្រវត្តិពី អង្គភាពផ្ទៃក្នុង និងស្ថាប័នពាក់ព័ន្ធ
- រៀបចំសារាចរណែនាំស្តីពី ការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួនរួមមាន ធនាគារ សំណង់ ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុង ការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធិភាពសវនកម្ម
- រៀបចំសារាចរណែនាំស្តីពី ការផ្ទេរថ្លៃ (Transfer Pricing)
- មានការបង្កើតកម្មវិធីស្មាតហ្វូនមួយឈ្មោះ GDT Audit Check ក្នុងឆ្នាំ២០១៨ សម្រាប់ជួយបណ្តាអ្នកជាប់ពន្ធក្នុងការបញ្ជាក់ពីឯកសាររបស់ពួកគេ ថាជាឯកសារពិត ឬមិនពិត?[12] ទាំងនេះហើយជាភាពរីកចម្រើនដែលគួរឱ្យកត់សម្គាល់ក្នុងការធ្វើសវនកម្មនៃអាណត្តិទី៥នេះ។

[12] "នាយកដ្ឋានពន្ធដារបង្កើត app សម្រាប់ត្រួតពិនិត្យលិខិតសវនកម្ម", ភ្នំពេញប៉ុស្តិ៍, ២៧ មីនា ២០១៨, https://www.postkhmer.com/របាយការណ៍ពិសេស/នាយកដ្ឋានពន្ធដារបង្កើត-app-សម្រាប់ត្រួតពិនិត្យលិខិតសវនកម្ម (បានមើលចុងក្រោយ ១៨ មេសា ២០១៨)

## ៥. ការប្រមូលបំណុលពន្ធ និងការដោះស្រាយវិវាទសារពើពន្ធ

កន្លងមកបុគ្គលមួយចំនួនធំមានការគេចវេសពន្ធ ដោយមានការឃុបឃិតនានា ទើបចំណូលពន្ធមិនអាចប្រមូលបានគ្រប់ចំនួនតាមផែនការ ដោយឡែកក្នុងអាណត្តិទី៥ ចំណូលពីការប្រមូលបំណុលពន្ធមានការកើនឡើងជាលំដាប់ ដោយសារអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការមួយចំនួនដូចជា ការគ្រប់គ្រងអ្នកជាប់ពន្ធលក្ខណ:ទំនើបច្បាស់លាស់ មិនអនុញ្ញាតឱ្យចុះបញ្ជីបង្កើតក្រុមហ៊ុនថ្មី មិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ចុះផ្សាយឈ្មោះអ្នកជំពាក់បំណុលពន្ធនៅលើទំព័រសារព័ត៌មាន សហាការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីកាត់ប្រាក់ទូទាត់បំណុលពន្ធ សហាការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីឃាត់ទុកទំនិញ និងសហាការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការឱ្យអ្នកជំពាក់បំណុលពន្ធមកទូទាត់បំណុលពន្ធ។

អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងបំណុលពន្ធ តាមវិធានការដូចខាងក្រោម៖

- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យយ៉ាងច្បាស់លាស់
- រៀបចំសៀវភៅណែនាំស្តីពី ការគ្រប់គ្រងប្រមូលបំណុលពន្ធ
- កំណត់គោលដៅប្រមូលបំណុលពន្ធនៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ និងអនុវត្តវិធានការទាមទារចំពោះអ្នកជំពាក់បំណុលពន្ធធំៗ ដែលមិនតវ៉ា និងមានបំណុលពន្ធថ្មីៗ
- នីតិវិធីទាមទារបំណុលពន្ធ មានលក្ខណ:ល្អប្រសើរ ដោយមានការអនុគ្រោះការប្រាក់ក្នុងឆ្នាំដំបូង ដោយគិតការប្រាក់ចាប់ពីឆ្នាំទីពីរទៅ ជាមួយនិងវិធានការសងបំណុលរំលោះ នេះជាការលើកទឹកចិត្តដើម្បីឱ្យអ្នកជាប់ពន្ធមានលទ្ធភាពសងបំណុលពន្ធរួច និងមិនសូវមានហានិភ័យនានាកើតឡើងជាយថាហេតុ ដែលអាចបណ្តាលឱ្យគ្រឹះស្ថាន ឬសហគ្រាសក្ស័យធនឡើយ

និងវេបសាយ, www.tax.gov.kh/en/videos.php?ld=13

- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការទាមទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជា ការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ
- កែប្រែប្រកាសស្តីពី វិធាន និងនីតិវិធី នៃការដោះស្រាយបណ្តឹងតវ៉ា ដើម្បីផ្តល់តម្លាភាព អព្យាក្រឹត្យភាព យុត្តិធម៌ នីត្យានុកូលភាពហិរញ្ញវត្ថុ និងភាពជឿទុកចិត្តបាន។ អ្នកជាប់ពន្ធទាំងអស់មានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ចំពោះវិវាទ គយ រដ្ឋាករ និងពន្ធដារ។[13] នីតិវិធីងាយស្រួល និងមានប្រសិទ្ធិភាពជាងអាណត្តិមុនៗ ដែលវាជួយកាត់បន្ថយហានិភ័យជាច្រើនសម្រាប់អ្នកជាប់ពន្ធ ក្នុងព្រះរាជាកម្ពុជា ដែលនីតិវិធីដាក់ពាក្យបណ្តឹង និងនីតិវិធីដោះស្រាយត្រូវបានបកស្រាយយ៉ាងលម្អិតនៅក្នុងប្រកាស លេខ ១៤៧០ សហវ.ប្រក ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## កថាខណ្ឌទី២ មុខងារបន្ទាប់បន្សំ

មុខងារបន្ទាប់បន្សំ ឬមុខងារគាំទ្រ គឺជាប្រភេទមុខងារពាក់ព័ន្ធការរៀបចំរចនាសម្ព័ន្ធចាត់តាំងការងារ និងការរៀបចំផែនការទូទៅរបស់អង្គភាព ដូចជា ផែនការគ្រប់គ្រងធនធាន រួមទាំងធនធានជាសម្ភារៈឧបករណ៍បច្ចេកវិទ្យា និងធនធានមនុស្សដែលជាមុខងារគន្លឹះក្នុងការគាំទ្រ និងពង្រឹងប្រសិទ្ធិភាពនៃការបំពេញមុខងារប្រតិបត្តិការស្នូល។ មុខងារបន្ទាប់បន្សំក្នុងអត្ថបទនេះសំដៅលើៈ ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ (១) ការគ្រប់គ្រងធនធានមនុស្ស (២) និង បច្ចេកវិទ្យាព័ត៌មាន (៣)។

### ១. ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ

ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ គឺជាការងារចាំបាច់សម្រាប់ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចប្រតិបត្តិការទូទៅ និងការប្រមូលចំណូលពន្ធ។ នៅក្នុងន័យនេះ អគ្គនាយកដ្ឋានពន្ធដារបានកែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងជាច្រើន ដែលរួមមានការបង្កើតការិយាល័យគ្រប់គ្រងប្រមូលពន្ធតាមរបបពិតនៅឆ្នាំ១៩៩៤ អង្គភាពប្រមូលអាករលើតម្លៃបន្ថែមនៅឆ្នាំ១៩៩៦ ការពង្រីករបប-

[13] អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណកម្មាធិការដោះស្រាយវិវាទសារពើពន្ធ, លេខ ០៣ អនក្រ.បក, ០៦ មករា ២០១៦

ស្វ័យប្រកាសនៅទូទាំងប្រទេស និងការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំនៅឆ្នាំ១៩៩៩។ នៅឆ្នាំ ២០០៥ នាយកដ្ឋានពន្ធដារបានកែទម្រង់រចនាសម្ព័ន្ធម្តងទៀត ដោយផ្តោតលើចក្ខុវិស័យ បេសកកម្ម តួនាទី និងភារកិច្ច។ ក្នុងឆ្នាំ២០១៥ មានការបង្កើតនូវគណកម្មាធិការដោះស្រាយវិវាទសារពើពន្ធ បន្ទាប់មកឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារ ត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារ ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមាននាយកដ្ឋានថ្នាក់កណ្តាលចំនួន ៧ ដែលត្រូវបានកែប្រែក្នុងឆ្នាំ២០១៧គឺ នាយកដ្ឋានកណ្តាលមានចំនួន ៩បន្ថែម ដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ និងរៀបចំឱ្យកាន់តែមានសណ្តាប់ធ្នាប់ក្នុងការគ្រប់គ្រង ។

ជាមួយនឹងវឌ្ឍនភាពខាងលើ កំណែទម្រង់នៅមិនទាន់គ្រប់គ្រាន់ និងមិនអាចឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងលឿនរបស់សេដ្ឋកិច្ចជាតិ តម្រូវការរបស់អ្នកជាប់ពន្ធ និងការអភិវឌ្ឍន៍នាថ្ងៃអនាគតនៅឡើយទេ។ ផ្នែកពន្ធមានចរិតលក្ខណៈជំនាញ ឯកទេសស្មុគស្មាញ ចាំបាច់ត្រូវបញ្ជាក់ និងផ្សព្វផ្សាយពីចក្ខុវិស័យរយៈពេលវែង និងកំណត់ពីគោលដៅជាក់លាក់មួយ ដើម្បីជំរុញឱ្យមានសង្គតិភាពនៃការរៀបចំរចនាសម្ព័ន្ធ និងការធ្វើផែនការ និងអនុវត្តយុទ្ធសាស្ត្រឱ្យស្របតាមចក្ខុវិស័យរយៈពេលវែង។ ជាមួយគ្នានេះ នាយកដ្ឋានមួយចំនួនមិនទាន់មានការិយាល័យសំខាន់ៗ ដូចជា ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ ការិយាល័យសវនកម្មផ្ទៃក្នុង ការិយាល័យផ្តល់ព័ត៌មានតាមទូរស័ព្ទ ការិយាល័យទំនាក់ទំនងសាធារណៈ និងការិយាល័យស្រាវជ្រាវនិងវិភាគប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

សវនកម្មផ្ទៃក្នុងត្រូវបានទទួលស្គាល់ថា មានមុខងារសំខាន់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យក្នុងស្ថាប័ន ហើយការធ្វើសវនកម្មផ្ទៃក្នុងនេះ អាចជួយលើកកម្ពស់សេចក្តីថ្លៃថ្នូរជូនស្ថាប័ន និងផ្តល់ទំនុកចិត្តដល់អ្នកជាប់ពន្ធ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានបង្កើតការិយាល័យត្រួតពិនិត្យនៅក្នុងនាយកដ្ឋានត្រួតពិនិត្យ ដែលមានតួនាទី និងភារកិច្ចដូចសវនកម្មផ្ទៃក្នុងដែរ ប៉ុន្តែការិយាល័យនេះមិនបានអនុវត្តមុខងារសវនកម្មផ្ទៃក្នុង ប្រកបដោយបច្ចេកទេស និងស្តង់ដារ ហើយជាធម្មតា គឺមិនសូវមានសកម្មភាព។ កង្វះប្រសិទ្ធភាពក្នុងការធ្វើសវនកម្មផ្ទៃក្នុង ទើបធ្វើឱ្យតួនាទី និងភារកិច្ចរបស់នាយកដ្ឋានត្រួតពិនិត្យ មានការលំបាកដល់ការពិនិត្យតាមដាន និងវាយតម្លៃប្រតិបត្តិការរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ។

ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការគ្រប់គ្រងប្រតិបត្តិការនានានៃពន្ធដារនេះ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុវត្តវិធានការ ដូចខាងក្រោម៖

- កំណត់ និងផ្សព្វផ្សាយនូវចក្ខុវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ ដល់គ្រប់មន្ត្រីពន្ធដារ និងសាធារណជន
- ពិនិត្យឡើងវិញនូវផែនការប្រតិបត្តិរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ និងកំណត់គោលដៅអាទិភាព និងពេលវេលាសម្រេចបាន
- កែសម្រួលរចនាសម្ព័ន្ធការងាររបស់អង្គភាពពន្ធដារនីមួយៗ និងបង្កើតការិយាល័យមួយចំនួនបន្ថែមទៀត នៅតាមនាយកដ្ឋានថ្នាក់កណ្តាល និងតាមសាខាពន្ធដារខេត្ត ដើម្បីដំណើរការការងារ និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាព
- បន្តពង្រឹង និងកែសម្រួលតួនាទី និងភារកិច្ចរបស់ការិយាល័យសវនកម្មផ្ទៃក្នុងនៃនាយកដ្ឋានត្រួតពិនិត្យ
- បង្កើតគណៈកម្មការ ឬក្រុមការងារគ្រប់គ្រងកំណែទម្រង់អចិន្ត្រៃយ៍ ដោយជ្រើសរើសមន្ត្រីដែលមានបទពិសោធន៍ រួមទាំងមានការផ្តល់ការលើកទឹកចិត្តឱ្យបានសមរម្យ
- បានបង្កើតនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ និងមានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ
- រៀបចំនីតិសម្បទាជូនមន្ត្រីពន្ធដារជានគរបាលយុត្តិធម៌
- បន្តរៀបចំកែលម្អរចនាសម្ព័ន្ធ និងបង្កើតនាយកដ្ឋាន និងការិយាល័យថ្មីមួយចំនួនតាមការចាំបាច់របស់អគ្គនាយកដ្ឋានពន្ធដារ
- រៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ន។

**២. ការគ្រប់គ្រងធនធានមនុស្ស**

ការគ្រប់គ្រងធនធានមនុស្ស គឺចាំបាច់សម្រាប់គ្រប់វិស័យទាំងអស់ រួមទាំងផ្នែកពន្ធដារនេះ ដោយអគ្គនាយកដ្ឋានពន្ធដារបានខិតខំយកចិតទុកដាក់អនុវត្ត តាមរយៈការជ្រើសរើសមន្ត្រីបន្ថែម ការបណ្តុះបណ្តាលមន្ត្រីនៅក្នុងនិងក្រៅប្រទេស ការរៀបចំវិន័យនិងក្រមសីលធម៌មន្ត្រី ការពង្រឹងវិជ្ជាជីវៈ និងការដាក់ទោសទណ្ឌមន្ត្រីដែលប្រព្រឹត្តខុស។ល។ ក្នុងខណៈដែលអគ្គនាយកដ្ឋានពន្ធដារ

កំពុងរៀបចំឱ្យមានយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស បញ្ហាជាច្រើនក៏បានលេចរូបរាងឡើងគឺ មន្ត្រីដែលមានជំនាញ និងបទពិសោធន៍ច្រើន មានចំនួនតិច និងត្រូវបានចាត់តាំងឱ្យទទួលបន្ទុក កិច្ចការជាច្រើន ដែលមិនមែនជាភារកិច្ចចំបងរបស់ខ្លួន ដូចជា ការរៀបចំគោលនយោបាយ សារពើពន្ធ និងកិច្ចការបន្ទាន់ផ្សេងៗ ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធ ហើយមន្ត្រីមួយភាគធំនៅតាមសាខាពន្ធដារខណ្ឌ-ខេត្ត ត្រូវបានចាត់តាំងឱ្យប្រមូលចំណូលពន្ធ តូចៗ រីឯប្រភេទចំណូលពន្ធធំៗវិញ គឺមានចំនួនមន្ត្រីទទួលបន្ទុកនៅមានកម្រិត ដែលបញ្ហាប្រឈម នេះនឹងមានភាពស្មុគស្មាញកាន់តែខ្លាំង នៅពេលមានការកែប្រែប្រមូលពន្ធតាមរបបមៅការមកជា របបស្វ័យប្រកាស ការកើនឡើងអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស និងការកើនឡើងចំនួនសហ គ្រាសថ្មី ក៏ដូចជាការធ្វើនិទានកម្មលើរង្វាន់លើកទឹកចិត្តនាពេលបច្ចុប្បន្ន ដែលផ្តល់ជូនមន្ត្រីពន្ធដារ គ្រប់រូបមិនបានបែងចែកកម្រិតនៃប្រាក់រង្វាន់ ដោយផ្អែកលើលទ្ធផលការងាររបស់មន្ត្រីម្នាក់ៗនៅ ឡើយ។

ដើម្បីគ្រប់គ្រងធនធានមនុស្ស ឱ្យបានកាន់តែប្រសើរជាមួយនឹងគោលនយោបាយរបស់ រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធដារបាននឹងកំពុងរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស ដោយផ្តោតលើ៖

- ធ្វើសនិទានកម្មរបបរង្វាន់លើកទឹកចិត្ត ដែលត្រូវពឹងផ្អែកលើលទ្ធផលការងារជាមូលដ្ឋាន បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រីពន្ធដារគ្រប់កម្រិត និងកែលម្អកម្មវិធីសិក្សារបស់សាលា ជាតិពន្ធដារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- ធ្វើការជ្រើសរើសមន្ត្រីពន្ធដារឱ្យបានឆាប់រហ័សស្របតាមតម្រូវការជាក់ស្តែងរបស់អង្គភាព ពន្ធដារនីមួយៗ
- មានការរៀបចំលក្ខខណ្ឌការងារ និងមានការទទួលខុសត្រូវខ្ពស់លើមុខងារនៃមន្ត្រីនីមួយៗ ដែលត្រូវប្រកបដោយក្រមសីលធមិខ្ពស់ និងវិន័យល្អ។ ឧទាហរណ៍ ការអនុវត្តជាក់ស្តែង នាពេលបច្ចុប្បន្នគឺ មន្ត្រីទាំងអស់ត្រូវស្កេនម្រាមដៃ និងកាត ចេញចូលដើម្បីបញ្ជាក់ពីវត្តមាន របស់ខ្លួននៅកន្លែងធ្វើការ នោះថ្នាក់លើនឹងអាចកំណត់បាន បុគ្គលណាមកធ្វើការ និង

មិនមកធ្វើការ លើសពីនេះទៅទៀត មន្ត្រីក្នុងអគ្គនាយកដ្ឋានពន្ធដារ ត្រូវតម្រូវឱ្យសរសេររបាយការណ៍ប្រចាំថ្ងៃថាខ្លួនបានធ្វើអ្វីខ្លះក្នុងថ្ងៃនេះ និងរាយការណ៍ទៅថ្នាក់លើ។[14]

- បញ្ចប់សេចក្តីព្រាងស្តីពីក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ និងរៀបចំសេចក្តីណែនាំស្តីពីវិន័យ និងការដាក់ទណ្ឌកម្មដែលបញ្ជាក់អំពីនីតិវិធីអនុវត្តច្បាស់លាស់
- រៀបចំបទដ្ឋានគោលការណ៍ឱ្យបានច្បាស់លាស់សម្រាប់ការផ្លាស់ប្តូរមន្ត្រី
- រៀបចំគម្រោងចំណាយថវិការបស់អង្គភាពពន្ធដារ ដើម្បីទទួលបានថវិកាគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់គាំទ្រការអនុវត្តការងារប្រមូលចំណូលពន្ធ និងការកែទម្រង់ពន្ធដារឱ្យមានប្រសិទ្ធភាព។

### ៣. បច្ចេកវិទ្យាព័ត៌មាន

បច្ចេកវិទ្យាព័ត៌មាន ក៏មានបញ្ហាដូចផ្នែកផ្សេងៗដែរ ហើយត្រូវបានដោះស្រាយ នៅក្នុងអាណត្តិទី៥នេះ ដោយរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មានពន្ធដារតាមដំណាក់កាលនៃការអនុវត្ត តម្រូវការរបស់អ្នកប្រើប្រាស់ និងតម្រូវការធនធានសម្ភារៈបរិក្ខារ និងរៀបចំផែនការធ្វើលទ្ធកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយផ្អែកទៅតាមផែនការយុទ្ធសាស្ត្រសម្រាប់គាំទ្រដល់ការងារសេវាអ្នកជាប់ពន្ធ ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្ម និងការគ្រប់គ្រងបំណុលពន្ធ។

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈទំនើបមានសារៈសំខាន់ក្នុងការគាំទ្រដល់ការងារចុះបញ្ជីអ្នកជាប់ពន្ធ សេវាអ្នកជាប់ពន្ធ ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្ម ការគ្រប់គ្រងបំណុលពន្ធ និងការសន្សំពេលវេលា តាមរយៈការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងទិន្នន័យ និងចំនួនមន្ត្រីតាមរយៈការផ្លាស់ប្តូរពីការងារ ដែលប្រតិបត្តិដោយដៃមកជាការប្រតិបត្តិដោយប្រព័ន្ធកុំព្យូទ័រ។ ទើបធ្វើឱ្យមាន ការជ្រើសរើសបន្ថែមនូវមន្ត្រីជំនាញបច្ចេកវិទ្យាព័ត៌មានគ្រប់អង្គភាពពន្ធដារទាំងអស់ ដើម្បីគាំពារដល់ផែនការទំនើបភាវូបនីយកម្ម និងស្វ័យប្រវត្តិកម្មពន្ធដារ។

[14] ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល គង់ វិបុល, កិច្ចសម្ភាសជាមួយBTV, http://www.tax.gov.kh/videos.php?Id=5 , នាទី ៥៥

ដោយយើងដឹងថា ផលប្រយោជន៍នៃប្រព័ន្ធបច្ចេកវិទ្យាមានច្រើន ទើបអគ្គនាយកដ្ឋានពន្ធដារក៏បានសម្រេចចិត្តប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើប ដើម្បីជួយសម្រួលដល់ប្រតិបត្តិការនានារបស់អគ្គនាយកដ្ឋាន ដូចជាទូរក្សាទុកឯកសារមានលក្ខណៈទំនើប ក៏ដូចជាធ្វើបច្ចុប្បន្នភាពព័ត៌មានថ្មីៗលើគេហទំព័រ និងផ្លាស់ប្តូរបង្កាន់ដៃ ដែលធ្លាប់សរសេរដោយដៃមកជាលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធបោះពុម្ពចេញដោយកុំព្យូទ័រ (ពន្ធរបបស្វ័យប្រកាស និងពន្ធលើអចលនទ្រព្យជាដើម) ហើយនឹងការដាក់លិខិតប្រកាសពន្ធតាមរយៈប្រព័ន្ធអីនធឺណេតបាន។ល។

អគ្គនាយកដ្ឋានពន្ធដារបានដំឡើងបណ្តាញភ្ជាប់ទូលាយ (Wide Area Network-WAN) ដើម្បីបញ្ជូនព័ត៌មាន និងទិន្នន័យអ្នកជាប់ពន្ធពីសាខាពន្ធដារខណ្ឌចំនួន ៧ (ជំហានទី១) និងខេត្តចំនួន១៦ (ជំហានទី២) មកប្រមូលផ្តុំនៅថ្នាក់កណ្តាល។ មិនត្រឹមតែប៉ុណ្ណោះ អគ្គនាយកដ្ឋានពន្ធដារក៏បានបង្កើតវេបសាយ ផេក និងគណនីផ្សេងៗទៀតតាមប្រព័ន្ធ Facebook, YouTubeជាដើម ដើម្បីចែករំលែកព័ត៌មាននានា ទាក់ទងនឹងពន្ធដារឱ្យមានភាពកាន់តែទូលំទូលាយជាងមុន ដូច្នេះប្រជាពលរដ្ឋនឹងមានភាពងាយស្រួលស្វែងយល់ពីពន្ធដារនៅក្នុងប្រទេសកម្ពុជា។ ហើយអគ្គនាយកដ្ឋានពន្ធដារក៏មានការបើកឱ្យចោទសួររាល់ចម្ងល់ និងការរិះគន់ផ្សេងៗ ដើម្បីស្តាបនា ហើយរាល់ព័ត៌មាន និងចម្លើយនានា មានការបកស្រាយនៅក្នុងវេបសាយផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារនានាយ៉ាងក្បោះក្បាយ (www.tax.gov.kh) ។ លើសពីនេះទៅទៀត អគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យដំណើរការនូវ CALL CENTER ដើម្បីផ្តល់ការពិគ្រោះយោបល់ និងសេវាដល់អ្នកជាប់ពន្ធ អង្គភាពពន្ធដារដ៏ទៃទៀត និងផ្នែកឯកជននានា ដោយមានទទួលការហៅចូលរបស់អ្នកជាប់ពន្ធ និងសាធារណៈជនតាមរយៈទូរស័ព្ទ HOTLINE លេខ៖

- ១២៧៧
- ០២៣ ៨៨៦ ៦៦៨។

ការផ្តល់ព័ត៌មាន និងឆ្លើយចម្ងល់របស់អ្នកជាប់ពន្ធអាចនឹងមិនគ្រប់គ្រាន់ ដូចនេះហើយអគ្គនាយកដ្ឋានពន្ធដារក៏បានបញ្ចេញ នូវកម្មវិធីទូរស័ព្ទថ្មីមួយឈ្មោះថា TAX LIVE CHAT ដែលអាចទាញយកបានតាមរយៈស្មាតហ្វូន (Smart Phone) មានទាំងប្រព័ន្ធប្រតិបត្តិការណ៍ Android និង

IOS។ TAX LIVE CHAT គឺជាកម្មវិធីទូរស័ព្ទមួយសម្រាប់ឱ្យសាធារណៈជន ជជែកអំពីបញ្ហាពន្ធគ្រប់ប្រភេទ គ្រាន់តែបង្កើតគណនីក្នុងនោះជាការស្រេច ដោយពុំមានការគិតសេវានានាទេ។ ទាំងនេះជាភាពងាយស្រួលមួយបែបទៀតសម្រាប់សាធារណៈជន ក្នុងការស្វែងរកដំណោះស្រាយ លើចម្ងល់របស់ខ្លួនទាក់ទងនឹងពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី៣

# កំណែទម្រង់សារពើពន្ធ

# និង

# សមិទ្ធផល

# ជំពូកទី៣

# កំណែទម្រង់សារពើពន្ធ និងសមិទ្ធផល

អាណត្តិទី៥នៃរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមឡើងក្នុងឆ្នាំ២០១៤ នឹងបញ្ចប់ក្នុងឆ្នាំ២០១៨ ដែលរាជរដ្ឋាភិបាលមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុង ការធ្វើកំណែទម្រង់ក្នុងវិស័យនានា ជាពិសេសអភិវឌ្ឍសេដ្ឋកិច្ចឱ្យកាន់តែមានការរីកចម្រើនឡើង និងបង្កើនចំណូលជាតិ ក៏ដូចជាគ្រប់គ្រងចំណាយរដ្ឋផងដែរ។ អគ្គនាយកដ្ឋានពន្ធដារចំណុះឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានធ្វើបច្ចុប្បន្នភាព ដោយមានការកែសម្រួលនូវ ប្រភេទពន្ធមួយចំនួន និងបន្ថែមចំណុចខ្វះខាតនានា ដើម្បីឱ្យសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ច និងយុទ្ធសាស្ត្រកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥នេះ។

## កថាខណ្ឌទី១ កំណែទម្រង់សារពើពន្ធ

យោងទៅតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនាប្រាំឆ្នាំចុងក្រោយនេះ បានប្បញ្ញត្តិពីវិសោធនកម្មទៅលើមាត្រាមួយចំនួនដែលទាក់ទងទៅនឹងប្រភេទពន្ធ នៅក្នុងច្បាប់ស្តីពីសារពន្ធ និងមានការបន្ថែមចំណុចថ្មីមួយចំនួន ដែលមានដូចជា ពន្ធលើប្រាក់ចំណូល(១) ពន្ធលើប្រាក់បៀវត្ស (២) ពន្ធអាករលើតម្លៃបន្ថែម (៣) ពន្ធប៉ាតង់ (៤) ពន្ធប្រថាប់ត្រា (៥) ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ (៦) ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយាន្តជំនិះគ្រប់ប្រភេទ (៧) ពន្ធលើដីធ្លីមិនប្រើប្រាស់ (៨) និងពន្ធសត្តឃាត (៩)។

### ១. ពន្ធលើប្រាក់ចំណូល

ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលសុទ្ធ[15]បានមកពីលទ្ធផលទាំងអស់នៃប្រតិបត្តិការអាជីវកម្មគ្រប់ប្រភេទ រួមបញ្ចូលទាំងចំណូលមូលធន ដែលសម្រេចបានក្នុងពេលកំពុងប្រកបអាជីវកម្ម ឬនៅពេលបញ្ចប់អាជីវកម្មព្រមទាំងប្រាក់ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ ឬទ្រព្យសកម្មវិនិយោគ ការប្រាក់ថ្លៃឈ្នួល និងសួយសារផង។ កំណែទម្រង់ប្រភេទពន្ធលើប្រាក់ចំណូលមាន

[15] ប្រាក់ចំណូលសុទ្ធ សំដៅដល់លទ្ធផលបានមកពីការយកប្រាក់ចំណូលដុលកាត់កងនូវចំណាយនានាដែលអនុញ្ញាតដោយច្បាប់។

ដូចជា អត្រាពន្ធនិងប្រាក់ពន្ធត្រូវបង់សម្រាប់អ្នកជាប់ពន្ធទាំងអស់ ពន្ធអប្បរមា ពន្ធកាត់ទុក និង កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ។[16]

❖ អត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំមានដូចតទៅ៖

- ២០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។
- ៣០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធ ដែលសម្រេចបានក្រោមកិច្ចសន្យាបែងចែកផលិតផលប្រេងកាត និងឧស្ម័នធម្មជាតិ ឬសម្រេចបានពីការធ្វើអាជីវកម្មលើធនធានធម្មជាតិ រួមទាំង ព្រៃឈើ រ៉ែ មាសឬត្បូងថ្មមានតម្លៃនានា។
- ០ ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធរបស់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលស្ថិតនៅក្នុងរយៈពេលលើកលែងពន្ធដែលកំណត់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។
- តាមតារាងអត្រាពន្ធកំណើនតាមថ្នាក់ខាងក្រោម ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល៖

| ភាគនៃប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២ ០០០ ០០០ ៛ | ០% |
| ពី | ១២ ០០០ ០០១៛ | ដល់ | ១៨ ០០០ ០០០ ៛ | ៥% |
| ពី | ១៨ ០០០ ០០១៛ | ដល់ | ១០២ ០០០ ០០០ ៛ | ១០% |
| ពី | ១០២ ០០០ ០០១៛ | ដល់ | ១៥០ ០០០ ០០០ ៛ | ១៥% |
| | | លើសពី | ១៥០ ០០០ ០០០ ៛ | ២០% |

[16] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ នស/រកម/១២១៦/០១៩, ២២ វិច្ឆិកា ២០១៦, មាត្រា១០ (មាត្រា២០ថ្មី-មាត្រា៣០ថ្មី)

❖ ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រងត្រូវបានកំណត់ដូចតទៅ៖

- ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា ពន្ធលើប្រាក់ចំណូលត្រូវបានកំណត់ស្មើនឹង ៥ ភាគរយ នៃបុព្វលាភធានារ៉ាប់រងដុល ដែលទទួលបាននៅក្នុងឆ្នាំជាប់ពន្ធ។
- ចំពោះសកម្មភាពធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើជីវិតដែលមានលក្ខណៈសន្សំ និងសកម្មភាពដទៃទៀតក្រៅពីធានារ៉ាប់រង ឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗ និងពន្ធលើប្រាក់ចំណូលកំណត់តាមមាត្រា ២០ថ្មី (មួយ) នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

វិធាន និងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

❖ ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសត្រូវបានកំណត់ដូចខាងក្រោម៖

- ប្រាក់ចំណូលដែលសម្រេចបានពីប្រភពកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមមាត្រា ២០ថ្មី (មួយ) នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធចរន្ត សាខាក្រុមហ៊ុនបរទេសណាមួយ ធ្វើការផ្ទេរប្រាក់ចំណូលប្រភពកម្ពុជាទៅក្រៅប្រទេស ប្រាក់ចំណូលនោះ៖
  - មិនត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមមាត្រា២៣ថ្មី (មួយ)នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូល តាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា ២០ថ្មី(មួយ) នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧
  - ត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែម លើការបែងចែកភាគលាភតាមកថាខណ្ឌ១ នៃមាត្រា ២៣ថ្មី(មួយ) នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ប្រសិនបើប្រាក់ចំណូល ដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើ

ប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ថ្មី(មួយ) នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

- ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា២៦ថ្មី(មួយ)នៃច្បាប់ស្ដីពីសារពើពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌ១០ នៃមាត្រា៣៣ថ្មីនៃច្បាប់ស្ដីពីសារពើពន្ធ។[17]

វិធាន និងនីតិវិធីនៃការបង់ពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

❖ ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ ត្រូវបានកំណត់ដូចតទៅ៖

- រាល់ការបែងចែកភាគលាភ ត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែម លើការបែងចែកភាគលាភ។ ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភសម្រាប់ឆ្នាំជាប់ពន្ធណាមួយត្រូវបានកំណត់ស្មើនឹងលម្អៀង រវាងប្រាក់ពន្ធត្រូវបង់តាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា ២០ថ្មី(មួយ) នៃច្បាប់ស្ដីពីសារពើពន្ធ និងប្រាក់ពន្ធលើប្រាក់ចំណូលដែលអ្នកជាប់ពន្ធបានបង់ជាក់ស្តែងសម្រាប់ឆ្នាំជាប់ពន្ធនេះ។
- ប្រសិនបើសហគ្រាសណាមួយបានទទួលភាគលាភបានបង់ពន្ធតាមកថាខណ្ឌ១ (ខាងលើនេះ) ពីសហគ្រាសមួយទៀតត្រូវកត់ត្រាចំនួនប្រាក់ភាគលាភនោះទៅក្នុងគណនីភាគលាភរបស់ខ្លួន។ ពេលសហគ្រាសនោះបែងចែក ជាបន្តទៀតទៅអ្នកចូលហ៊ុនរបស់ខ្លួន ទឹកប្រាក់បែងចែក ដែលត្រូវដកចេញពីគណនីភាគលាភ មិនត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភទេ។

❖ ពន្ធអប្បបរមា[18] ត្រូវបានកំណត់ស្មើនឹង ១ភាគរយ នៃផលរបរប្រចាំឆ្នាំ រួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម និងត្រូវបង់សម្រាប់ឆ្នាំជាប់ពន្ធណាមួយ អាចត្រូវបានកាត់បន្ថយដោយពន្ធលើប្រាក់ចំណូលដែលបានបង់ជាក់ស្តែងក្នុងឆ្នាំជាប់ពន្ធនោះ តាមវិធានដែលមានចែងក្នុងមាត្រា៣៧ថ្មី មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ អនុម័តឆ្នាំ២០១៦ ចំណុចនេះនៅដដែលទេ។ ប៉ុន្តែចំពោះការកំណត់លើ

[17] ច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ នស/រកម/១២១៦/០១៩, ២២ វិច្ឆិកា ២០១៦

[18] ពន្ធអប្បរមាជាពន្ធមួយដាច់ដោយឡែក និងផ្សេងពីពន្ធលើប្រាក់ចំណេញ។

អ្នកជាប់ពន្ធអប្បរមា ត្រូវបានកំណត់ជាថ្មី គឺកំណត់លើសហគ្រាសទាំងឡាយណាដែលមិនកាន់បញ្ជិកាគណនេយ្យបានត្រឹមត្រូវតែប៉ុណ្ណោះ ដោយមិនកំណត់លើអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចអាណត្តិមុនៗនោះទេ។ លក្ខណៈវិនិច្ឆ័យនៃការកាន់បញ្ជិកាគណនេយ្យមិនត្រឹមត្រូវ និងនីតិវិធីក្នុងការបង់ពន្ធអប្បរមា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

❖ ពន្ធកាត់ទុក ដែលអ្នកជាប់ពន្ធនិវាសនជន[19]ប្រកបអាជីវកម្ម រួមទាំងគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជន ដែលធ្វើការទូទាត់ប្រាក់ចំណូលប្រភពកម្ពុជាដូចមានចែងក្នុងមាត្រា ៣៣ថ្មីនៃច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ស្តីពី សារពើពន្ធ ឆ្នាំ២០០៣ ឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន[20] ត្រូវកាត់ទុក និងបង់នូវប្រាក់ពន្ធតាមអត្រា១៤ភាគរយនៃប្រាក់ត្រូវបើក។ ពន្ធកាត់ទុកនេះ មិនត្រូវអនុវត្តចំពោះបុព្វលាភធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជានោះទេ។

❖ អ្នកជាប់ពន្ធលើប្រាក់ចំណូលនេះ ត្រូវមានកាតព្វកិច្ចទៅតាមទំហំនៃការជាប់ពន្ធរបស់ខ្លួនដែលបានកំណត់ដោយច្បាប់ចំពោះពន្ធលើប្រាក់ចំណូលៈ

- អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំត្រូវមានកាតព្វកិច្ចដូចជាៈ
    - អនុវត្តកាតព្វកិច្ចបញ្ជិកាគណនេយ្យដូចមានចែងក្នុងមាត្រា ៦ថ្មីនៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជូលរដ្ឋាភិបាលសារពើពន្ធ ក្នុងរយៈពេល៣ខែ ក្រោយពីជំណាច់ឆ្នាំជាប់ពន្ធនីមួយៗដោយភ្ជាប់ជាមួយតារាងតុល្យការ គណនីលទ្ធផល និងព័ត៌មានបន្ថែម។

---

[19] អ្នកជាប់ពន្ធនិវាសនជនគឺជាៈ

- រូបវន្តបុគ្គលដែលមាននិវាសនដ្ឋាន ឬមានកន្លែងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជាលើសពី១៨២ថ្ងៃ នៅក្នុងរយៈពេល ១២ខែ ណាមួយដែលបានបញ្ចប់ក្នុងឆ្នាំសារពើពន្ធចរន្ត។
- នីតិបុគ្គល ឬក្រុមអាជីវកម្ម (pass-through) ដែលត្រូវបានបង្កើត ឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

[20] អ្នកជាប់ពន្ធអនិវាសនជនគឺជាៈ

- រូបវន្តបុគ្គលដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន ប៉ុន្តែទទួលប្រាក់ចំណូលប្រភពកម្ពុជា។
- នីតិបុគ្គល ឬក្រុមអាជីវកម្ម (pass-through) ដែលមិនមែនជាអ្នកជាប់ពន្ធនិវាសនជន និងមានគ្រឹះស្ថានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទ និងក្នុងរយៈពេលពេលដូចគ្នាដែរ។

_ អ្នកជាប់ពន្ធតូចត្រូវមានកាតព្វកិច្ចដូចខាងក្រោមៈ

- ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំក្នុងរយៈពេល ៣ខែ ក្រោយដំណាច់ឆ្នាំប្រតិទិននីមួយៗតាមគំរូដែលរដ្ឋបាលសារពើពន្ធបានផ្តល់ជូន។
- ក្នុងករណីមិនបានកាន់កត់ត្រាបញ្ជីចំណូលចំណាយតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ចំនួនប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យ និងគណនាតាមអត្រាចំណូលទៅតាមមុខរបរអាជីវកម្មដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២. ពន្ធលើប្រាក់បៀវត្ស

ពន្ធលើប្រាក់បៀវត្ស គឺជាពន្ធប្រចាំខែដែលត្រូវបានកាត់ដោយនិយោជកពីប្រាក់បៀវត្សរបស់និយោជិតដែលបំពេញការងារ។ ពន្ធនេះអនុវត្តលើបុគ្គលពីរប្រភេទគឺៈ

_ អ្នកជាប់ពន្ធនិវាសនជន ពន្ធត្រូវបានកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជា និងពីប្រាក់បៀវត្សប្រភពបរទេស។

_ អ្នកជាប់ពន្ធអនិវាសនជន ពន្ធត្រូវកាត់ទុកពីប្រាក់បៀវត្សប្រភពកម្ពុជា។

ចំណែកឯនៅក្នុងអាណត្តិទី៥នេះ ពន្ធលើប្រាក់បៀវត្សត្រូវបានកែសម្រួលលើពីរចំណុចគឺប្រាក់នៃការកាត់បន្ថយមូលដ្ឋានកំណត់ពន្ធ និងភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ។

❖ ប្រាក់បៀវត្សជាប់ពន្ធប្រចាំខែរបស់និយោជិតនិវាសនជន ត្រូវបានរាប់បញ្ចូល ទាំងប្រាក់បៀវត្សដែលទទួលបានពីប្រភពកម្ពុជា ប្រភពបរទេស និងប្រាក់បុរេប្រទាន ប្រាក់ឱ្យខ្ចី ឬប្រាក់រំដោះដែលនិយោជកបានបើឱ្យនិយោជិត ត្រូវបូកបន្ថែមលើបៀវត្សជាប់ពន្ធនៃខែ ដែលប្រាក់ទាំងនោះបានបើកហើយត្រូវកាត់បន្ថយពីប្រាក់បៀវត្សក្នុងខែដែលនិយោជិតបានបង់សងវិញ។

ក្នុងនោះក៏មានការអនុគ្រោះ ផ្អែកលើស្ថានភាពគ្រួសារ និយោជិតនិវាសនជន ដែលមានកូនស្ថិតនៅក្នុងបន្ទុក និងសហព័ទ្ធជាមេផ្ទះ ក្នុងពេលត្រូវបង់ពន្ធត្រូវបានទទួលការកាត់បន្ថយមូលដ្ឋាន

កំណត់ពន្ធចំនួន ៧៥ ០០០រៀលនៃបុគ្គលម្នាក់ៗ។ ឧទាហរណ៍ បើមានកូនពីរនាក់ រួមជាមួយសហព័ទ្ធជាមេផ្ទះម្នាក់ដូចច្នេះបីនាក់ យើងត្រូវយក ៧៥ ០០០៛ គុណនឹង៣ ដូច្នេះលទ្ធផលនេះហើយ ជាទឹកប្រាក់នៃការកាត់បន្ថយមូលដ្ឋានកំណត់ពន្ធរបស់គ្រួសារនោះ។ ប៉ុន្តែចាប់ពីឆ្នាំ២០១៧មក ការកាត់បន្ថយមូលដ្ឋានកំណត់ពន្ធចំពោះកូន និងសហព័ទ្ធជាមេផ្ទះត្រូវបានតម្លើងដល់ ១៥០ ០០០៛ (មួយរយហាសិបពាន់រៀល)។[21] ចំណែកឯអ្នកជាប់ពន្ធអនិវាសនជន ត្រូវបានកំណត់ដដែលគឺ ប្រាក់បៀវត្សជាប់ពន្ធរួមមានប្រាក់បៀវត្សប្រភពកម្ពុជា ដែលកំណត់តាមច្បាប់ជាធរមាននានា។

- ❖ ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធនេះ ត្រូវបានកែប្រែ ២ទៅ៣ដំណាក់កាលរួចមកហើយ ចុងឆ្នាំ២០១៧សម្រាប់និយោជិតនិវាសនជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជកតាមអត្រាកំណើនតាមថ្នាក់ ត្រូវបានប្រតិបត្តិតាមប្បញ្ញត្តិថ្មីដូចតទៅ៖[22]

| ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ | | | | អត្រាពន្ធ |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១ ២០០ ០០០ ៛ | ០% |
| ពី | ១ ២០០ ០០១៛ | ដល់ | ២ ០០០ ០០០ ៛ | ៥% |
| ពី | ២ ០០០ ០០១៛ | ដល់ | ៨ ៥០០ ០០០ ៛ | ១០% |
| ពី | ៨ ៥០០ ០០១៛ | ដល់ | ១២ ៥០០ ០០០ ៛ | ១៥% |
| | | លើសពី | ១២ ៥០០ ០០០ ៛ | ២០% |

### ៣. អាករលើតម្លៃបន្ថែម

អាករលើតម្លៃបន្ថែម គឺជាអាករកំណត់ទៅលើការចំណាយទិញរបស់អ្នកប្រើប្រាស់ អាករនេះត្រូវប្រមូលពីការប្រកអាជីវកម្ម និងការនាំចូល។ ការប្រកបអាជីវកម្មភាគច្រើនទាក់ទិនទៅនឹងការផ្គត់ផ្គង់ទំនិញឬសេវា។

[21] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ នស/រកម/១២១៦/០១៩, ២២ វិច្ឆិកា ២០១៦, មាត្រា៩ (៧)

[22] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧, មាត្រា១០ (មាត្រា៤៧ថ្មី(ពីរ))

ការប្រកបអាជីវកម្មទាំងនោះ ត្រូវជាប់ អាករលើតម្លៃបន្ថែមប្រសិនបើការផ្គត់ផ្គង់៖

- ធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើឡើងដោយបុគ្គលជាប់អាករ
- ធ្វើឡើងក្នុងដំណាក់កាលប្រកបអាជីវកម្ម ឬដំណាក់កាលពង្រីកអាជីវកម្ម
- គ្មានបញ្ជាក់ច្បាស់លាស់ថាមិនជាប់អាករតាមមាត្រា ៥៧ នៃច្បាប់ស្តីពីពន្ធដារ ឬជាប់អាករតាមអត្រា 0%។

❖ ការផ្គត់ផ្គង់មិនជាប់អាករត្រូវបានកែប្រែនៅក្នុងឆ្នាំ២០១៧ ដោយមានការបន្ថែមនូវទំនិញ ឬសេវា ៤ប្រភេទទៀត ចាប់ពីលេខ៨-១១។ ការផ្គត់ផ្គង់មិនជាប់អាករ មានដូចជា៖[23]

១. សេវាប្រៃសណីយ៍សាធារណៈ

២. សេវារបស់មន្ទីរពេទ្យ និងគ្លីនិក សេវាខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រ និងការលក់ទំនិញបន្ទាប់បន្សំខាងវេជ្ជសាស្ត្រ និងទន្តសាស្ត្រដែលទាក់ទិននឹងការបំពេញសេវាទាំងនេះ

៣. សេវាដឹកជញ្ជូនអ្នកដំណើរដោយប្រព័ន្ធដឹកជញ្ជូនសាធារណៈ ដែលជាកម្មសិទ្ធិទាំងស្រុងរបស់រដ្ឋ

៤. សេវាធានារ៉ាប់រង

៥. សេវាជាមូលដ្ឋានខាងហិរញ្ញវត្ថុ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦. ការនាំចូលសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនដែលរួចពន្ធគយ ក្នុងកម្រិតតម្លៃដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៧. សកម្មភាពមិនស្វែងរកចំណេញ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ដែលទទួលស្គាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[23] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ នស/រកម/១២១៦/០១៩, ២២ វិច្ឆិកា ២០១៦, មាត្រា១០ (មាត្រា៥៧)

៨. សេវាសិក្សាអប់រំ

៩. ថាមពលអគ្គិសនី និងទឹកស្អាត

១០. ផលិតផលកសិកម្មមិនទាន់កែច្នៃ

១១. សេវាប្រមូល ឬសម្អាតកាកសំណល់រឹង-រាវ។

## ៤. ពន្ធប៉ាតង់

ពន្ធប៉ាតង់ ជាពន្ធកំណត់លើផលរបរសរុបប្រចាំឆ្នាំ ដែលត្រូវបង់ក្នុងកំឡុងឆ្នាំពេលចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនាជារៀងរាល់ឆ្នាំ។ សម្រាប់សហគ្រាសឬក្រុមហ៊ុន ដែលទើបចាប់ផ្តើមប្រកបអាជីវកម្ម ត្រូវបង់ពន្ធប៉ាតង់ពេញមួយឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែដើមឆ្នាំឬបង់ពន្ធប៉ាតង់ពាក់កណ្តាលឆ្នាំ ប្រសិនបើចាប់ផ្តើមប្រកបអាជីវកម្មក្នុងរយៈពេល៦ខែចុងឆ្នាំ។ សហគ្រាសឬក្រុមហ៊ុន ដែលមានសាខា, ឃ្លាំង, រោងចក្រ, រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយ នៅក្នុងខេត្ត/ក្រុងតែមួយ មិនចាំបាច់បង់ពន្ធប៉ាតង់ផ្សេងគ្នាទេ ប៉ុន្តែបើមានមុខរបរអាជីវកម្មខុសគ្នា ឬស្ថិតនៅក្នុងខេត្ត/ក្រុងផ្សេងគ្នា ត្រូវបង់ពន្ធប៉ាតង់ទៅតាមមុខរបរនីមួយៗ និងទៅតាមខេត្ត/ក្រុងដោយឡែកៗពីគ្នា។ ពន្ធប៉ាតង់ដែលកំណត់ក្នុងច្បាប់ស្តីពី សារពើពន្ធ ត្រូវបានកែប្រែចំណុចមួយចំនួនចំពោះការកំណត់ប្រាក់ពន្ធប៉ាតង់។

❖ ប្រាក់ពន្ធប៉ាតង់ត្រូវបានកំណត់ដោយផ្អែកលើប្រភេទអ្នកជាប់ពន្ធដូចខាងក្រោម៖[24]

- អ្នកជាប់ពន្ធតូច ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ៤០០ ០០០រៀល (បួនរយពាន់រៀល)
- អ្នកជាប់ពន្ធមធ្យម ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំចំនួន ១ ២០០ ០០០រៀល (មួយលានពីររយពាន់រៀល)
- អ្នកជាប់ពន្ធធំ ត្រូវបង់ប្រាក់ពន្ធប៉ាតង់ប្រចាំឆ្នាំជាអប្បរមាចំនួន ៣ ០០០ ០០០ រៀល (បីលានរៀល) និងជាអតិបរមាចំនួន ៥ ០០០ ០០០ រៀល (ប្រាំលានរៀល)។

[24] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦, លេខ នស/រកម/១២១៥/០១៦, ៣០ វិច្ឆិកា ២០១៥, មាត្រា១២

ពន្ធប៉ាតង់ត្រូវបានកំណត់លើសកម្មភាពអាជីវកម្មនីមួយៗរបស់អ្នកជាប់ពន្ធ។ សកម្មភាពជាឧបសម្ព័ន្ធនានានៃសកម្មភាពអាជីវកម្មត្រូវបានចាត់ទុកថាជាសកម្មភាពអាជីវកម្មតែមួយ។ អ្នកជាប់ពន្ធដែលមានសាខា ឃ្លាំង រោងចក្រ រោងជាង សម្រាប់មុខរបរអាជីវកម្មតែមួយនៅក្នុងរាជធានី ខេត្តតែមួយត្រូវបង់ពន្ធប៉ាតង់តែមួយ។ វិធាន និងនីតិវិធីអនុវត្តការបង់ពន្ធប៉ាតង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៥. ពន្ធប្រថាប់ត្រា

ពន្ធប្រថាប់ត្រា គឺពន្ធដែលអនុវត្តចំពោះសកម្មភាពមួយចំនួនដែលមានដូចជា៖[25]

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និងផ្ទេរកម្មសិទ្ធិនិងសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្ត (ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន)។

❖ ពន្ធប្រថាប់ត្រា ត្រូវបានលើកលែង និងអនុគ្រោះ បានកែប្រែនៅក្នុងឆ្នាំ២០១៧ លើចំណុចមួយចំនួនដូចជា៖[26]

- ត្រូវបានលើកលែងពន្ធប្រថាប់ត្រាចំពោះ៖
    - ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល
    - ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងវង្វង់ញាតិ
    - ការទទួលកម្មសិទ្ធិទោចក្រយានយន្ត ត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០សេះ។

[25] ប្រកាសស្តីពី ការប្រមូលពន្ធប្រថាប់ត្រា, ២៦ មេសា ២០១៧, ប្រការ២

[26] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ នស/រកម/១២១៦/០១៩, ២២ វិច្ឆិកា ២០១៦, មាត្រា១១

- ត្រូវបានអនុគ្រោះពន្ធប្រថាប់ត្រា ចំពោះការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យក្នុងរង្វង់ញាតិ។

វិធាន និងនីតិវិធីស្ដីពីការលើកលែង និងអនុគ្រោះពន្ធ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៦. ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ

ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ គឺជាពន្ធថ្មីមួយដែលអគ្គនាយកដ្ឋានពន្ធដារទើបបញ្ចេញក្នុងឆ្នាំ២០១៨ ដោយបន្ថែមនៅក្នុងច្បាប់ស្ដីពីសារពើពន្ធ ជាជំពូកទី៦ ដោយលើកជំពូកទី៦ ស្ដីពីអវសានប្បញ្ញត្តិ ប្តូរទៅជាជំពូកទី៧ ដែលក្នុងនោះមាត្រា ១៤១ ត្រូវប្តូរជាមាត្រា ១៥៤ និងមាត្រា ១៤២ ត្រូវប្តូរជាមាត្រា ១៥៣។

- ❖ ការប្រតិបត្តិការប្រេងកាត[27] និងធនធានរ៉ែ[28] គឺជាការរុករក ឬស្វែងរកឃើញនៅក្នុងបូរណភាពទឹកដី និងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងបាតសមុទ្រ និងស្រទាប់ដីក្រោមបាទសមុទ្រនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងតំបន់ខ្ពង់រាបបាតសមុទ្រ ព្រមទាំងតំបន់ផ្សេងៗទៀតដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិអធិបតេយ្យ ដែលធ្វើឡើងដោយស្របច្បាប់ក្នុងការធ្វើអាជីវកម្ម។ បុគ្គលដែលបានធ្វើប្រតិបត្តិការទាំងពីរនេះ ត្រូវបំពេញកាតព្វកិច្ចនានាដែលកំណត់ដោយច្បាប់។
- ❖ ចំពោះអត្រាពន្ធ និងប្រាក់ពន្ធត្រូវបង់ត្រូវបានអនុវត្តដូចខាងក្រោម៖[29]
  - អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងអ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ

[27] ប្រេងកាត សំដៅលើប្រេងឆៅ ឧស្ម័នធម្មជាតិ ឬអ៊ីដ្រូការបូរផ្សេងទៀត ទោះជាស្ថិតក្នុងសភាពរឹង រាវ ឧស្ម័ន ក្នុងស្ថានភាពធម្មជាតិ និងរាល់សារធាតុផ្សេងទៀតដែលជាសមាសធាតុផ្សំជាមួយអ៊ីដ្រូកាបូរនោះ យោងតាមកថាខណ្ឌ ១ ចំណុច ក មាត្រា១៤២ នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ អនុម័តឆ្នាំ២០១៧

[28] ធនធានរ៉ែ សំដៅដល់សារធាតុទាំងឡាយ ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័ន ដែលកើតឡើងដោយធម្មជាតិតាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាទសមុទ្រ មានជាអាទិ៍ ត្បូងថ្ម ថ្មុងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ និងដីឥដ្ឋ ដែលមិនរាប់បញ្ចូលប្រេងកាតនោះទេ យោងតាមកថាខណ្ឌ ២ ចំណុច ក នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ អនុម័តឆ្នាំ២០១៧

[29] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧, មាត្រា១១ (មាត្រា១៤៣)

ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ៣០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។ "ប្រាក់ចំណូលជាប់ពន្ធ" ក្នុងចំណុចនេះសំដៅដល់ ប្រាក់ចំណូលសុទ្ធដែលបានមកពីការយកចំណូលដុលសម្រេចបានពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែ ដកចំណាយនានាដែលអនុញ្ញាតដោយច្បាប់។

- បន្ថែមលើអត្រាពន្ធខាងលើនេះ អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រាកំណើនតាមថ្នាក់ដូចមានចែងក្នុងតារាងអត្រាពន្ធលើប្រាក់ចំណូលលើសកម្រិតខាងក្រោមចំណុចទី៣ ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត។ សមាមាត្រនៃប្រាក់ចំណូល លើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែករវាងទឹកប្រាក់បូកបង្គរនៃចំណូល និងទឹកប្រាក់បូកបង្គរនៃចំណាយពីប្រតិបត្តិការប្រេងកាត ឬធនធានរ៉ែ មកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។
- អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត មានដូចក្នុងតារាង៖

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | | | | អត្រាពន្ធ |
|---|---|---|---|---|---|
| ១ | | ០៖ | ដល់ | ១,៣ | ០% |
| ២ | លើសពី | ១,៣ | ដល់ | ១,៦ | ១០% |
| ៣ | លើសពី | ១,៦ | ដល់ | ២ | ២០% |
| ៤ | លើសពី | ២ | ឡើងទៅ | | ៣០% |

វិធីគណនាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត ប្រាក់ចំណូលលើសកម្រិតពន្ធលើប្រាក់ចំណូលលើសកម្រិត និង វិធាននិងនីតិវិធីនៃការគ្រប់គ្រងការប្រមូលពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- អ្នកជាប់ពន្ធត្រូវបានលើកលែងពីការបង់ពន្ធអប្បរមាដែលមានចែងក្នុងមាត្រា២៤ថ្មី (ពីរ)[30]។

[30] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧

❖ ចំពោះប្រតិបត្តិការទាំងពីរនេះ ក៏មានការកាត់កងដូចទៅនឹងពន្ធលើប្រាក់ចំណូលដែរ ហើយការកាត់កងត្រូវបានបញ្ញត្តយ៉ាងច្បាស់លាស់នៅក្នុងមាត្រានីមួយៗនៃជំពូកទី៦នេះមានដូចជា៖[31]

- ចំណាយដែលត្រូវបានអនុញ្ញាតឱ្យកាត់កង ដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធរបស់អ្នកជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធ
- អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់តាមវិធានសមាមាត្រចំណូល ៣ ធៀបនឹងដើមទុន
- កាត់កងនូវប្រាក់បម្រុងសម្រាប់ចំណាយរុះរើបោសសម្អាត ឬចំណាយស្តារបរិស្ថាន
- ក៏ដូចជាមានវិធីរំលស់សម្រាប់ប្រតិបត្តិការប្រេងកាត និងធនធានរ៉ែផងដែរ។

❖ ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកក្នុងកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាប័ណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែ តាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលទទួលបន្ត ត្រូវអនុវត្តទៅតាមនីតិវិធីច្បាប់។[32]

❖ ករណីពិសេស មានការផ្តល់ការលើទឹកចិត្តផ្នែកសារពើពន្ធចំពោះកិច្ចព្រមព្រៀងប្រេងកាត ឬអាជ្ញាបណ្ណ ឬកិច្ចព្រមព្រៀងធនធានរ៉ែណាមួយ ដែលបានធ្វើឡើងមុនពេលចូលជាធរមាននៃបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ត្រូវអនុញ្ញាតឱ្យកំណត់ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៧. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

❖ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលកំណត់ដោយមាត្រា១៤ នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ និងមាត្រា១១ នៃច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ត្រូវបាននិរាករណ៍ និងអនុវត្តនូវយន្តការណ៍ថ្មី នៅឆ្នាំ២០១៦ ដោយមានការលុបចោលការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះ៖[33]

---

[31] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧, មាត្រា១១ (មាត្រា១៤៥-១៤៩)

[32] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧, មាត្រា១១ (មាត្រា១៥០)

[33] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦, លេខ នស/រកម/១២១៥/០១៦, ៣០ វិច្ឆិកា ២០១៥, មាត្រា១៣

_ ទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ

_ ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល

_ ជលយានយន្តគ្រប់ប្រភេទ ដែលមានកម្លាំងដល់១៥០សេះ។

ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទចំពោះមធ្យោបាយដឹកជញ្ជូន ត្រូវបានកំណត់ដូចក្នុងតារាងខាងក្រោម៖

ឯកតា៖ រៀល

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និងយានជំនិះ** | **កម្រិតប្រាក់ពន្ធសម្រាប់ ១ ឆ្នាំក្នុងមួយគ្រឿង** |
|---|---|
| **រថយន្តដឹកទំនិញមានទម្ងន់សរុប[ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញ និងមនុស្ស)]៖** | |
| ក. ដល់ ៣តោន | ២០០ ០០០ |
| ខ. លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| គ. លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| ឃ.លើសពី ២០តោន | ២ ០០០ ០០០ |
| **រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រមក និងទម្ងន់ផ្ទុក)៖** | |
| ក. ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| ខ. លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| គ. លើសពី ២០តោន | ២ ០០០ ០០០ |

ចំពោះប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះដ៏ទៃទៀត ត្រូវបានរក្សាទុកដ៏ដែល។ វិធាន និងនីតិវិធីលម្អិតសម្រាប់គ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ៨. ពន្ធលើដីធ្លីមិនប្រើប្រាស់

ចំណុចដែលបានកែប្រែនោះគឺ លក្ខខណ្ឌនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ត្រូវបង់ដោយកម្មសិទ្ធិករ ចំពោះដីដែលពុំមែនជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យ។[34]

### ៩. ពន្ធសត្តឃាត

ច្បាប់ស្តីពីការបង្កើតពន្ធសត្តឃាត ឆ្នាំ១៩៩១ ត្រូវបាននិរាករណ៍នៅក្នុងឆ្នាំ២០១៨ គឺមានន័យថា ត្រូវបានលុបប្រភេទ ពន្ធសត្តឃាតចោល ដោយមិនអនុវត្តទៀតចាប់ពីឆ្នាំ២០១៨ទៅ។[35]

## កថាខណ្ឌទី២ សមិទ្ធផលនៃកំណែទម្រង់ពន្ធដារ

### ១.បញ្ហាប្រឈមក្នុងពេលកំណែទម្រង់

បញ្ហាប្រឈមជាច្រើន បានកើតឡើងនៅក្នុងរយៈពេលធ្វើកំណែទម្រង់ពន្ធដារនៃអាណត្តិទី៥ ប៉ុន្តែបញ្ហាប្រឈមដែលយើងគួរឱ្យកត់សម្គាល់នោះមានបីផ្នែកគឺ ធនធានមនុស្ស (១.១) ធនធានហិរញ្ញវត្ថុ (១.២) និងបទដ្ឋានគត្តិយុត្ត (១.៣)។

១.១ ធនធានមនុស្ស

យោងតាមប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាបានជួបនូវវិបត្តិជាច្រើនបន្តបន្ទាប់គ្នាមានទាំងស្ថិតនៅក្នុងអាណានិគមនិយមបារាំងអស់ជិត មួយសតវត្សរ៍ និងរបបប្រល័យពូជសាសន៍ជាដើម ដែលរចនាសម្ព័ន្ធនៅក្នុងប្រទេស ស្ទើរតែទាំងស្រុងត្រូវបានបំផ្លិចបំផ្លាញ ប្រជាជនជាច្រើនលាននាក់ត្រូវបានបាត់បង់ជីវិតនៅក្នុងរបបដ៏ឃោរឃៅនោះផងដែរ។

ប្រទេសកម្ពុជាទើបតែទទួលបានឯករាជ្យភាព ពាក់កណ្តាលសតវត្សរ៍ជាងមកនេះទេ ដែលគ្រប់វិស័យទាំងអស់ត្រូវបានយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល រួមទាំងវិស័យពន្ធដារទៀតផង ហើយបញ្ហាប្រឈមជាច្រើនក៏បានកើតមានឡើង ស្របពេលធ្វើកំណែទម្រង់វិស័យមួយនេះ។

[34] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥, លេខ នស/រកម/១២១៣/០២៦, ២៨ វិច្ឆិកា ២០១៤, មាត្រា១២
[35] ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧, មាត្រា៩

ផ្នែកធនធានមនុស្សបានជួបនូវវិបត្តិធ្ងន់ធ្ងរបំផុតគឺ កង្វះបុគ្គលមានសមត្ថភាព និងចំណេះដឹងខ្ពស់ផ្នែកពន្ធដារ ទាំងការរៀបចំគោលនយោបាយ ការធ្វើសវនកម្មពន្ធដារ ការវាយតម្លៃហានិភ័យផ្សេងៗ និងផ្នែកបច្ចេកវិទ្យាផងដែរ។ កង្វះបុគ្គលមានសមត្ថភាពសម្រាប់បម្រើការងារ ដែលជារៀងរាល់ឆ្នាំក៏មានមន្ត្រីពន្ធដារជាច្រើន ត្រូវបានដាក់ឱ្យចូលនិវត្តន៍ទៀត ហើយធនធានបម្រុងមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការជំនួសតំណែងបាន ទើបធ្វើឱ្យមានវិបត្តិរឹតតែធ្ងន់ធ្ងរ។ ទោះជាមានបញ្ហាកង្វះធនធានមនុស្សបែបនេះក៏ដោយ ក៏ចំនួនប្រាក់ខែរបស់មន្ត្រីពន្ធដារនៅតែមានកម្រិតទាប និងមិនសូវមាននូវគោលការណ៍លើកទឹកចិត្ត ចំពោះបុគ្គលបំពេញកាតព្វកិច្ចបានល្អ ដែលជាមូលហេតុនាំឱ្យមិនអាចអនុវត្តបាននូវគោលនយោបាយអភិបាលកិច្ចល្អ ហើយអំពើពុករលួយក៏នៅតែកើតឡើងផងដែរ។

បញ្ហាមួយទៀតនោះគឺ ក្រុមហ៊ុន សហគ្រាស មួយចំនួនបានធ្វើការគេចវេសការបង់ពន្ធ ដោយរដ្ឋមិនអាចគ្រប់គ្រងទិន្នន័យលើប្រាក់ចំណូលរបស់ពួកគេបាន ទើបធ្វើឱ្យមានប្រតិបត្តិការមួយចំនួនត្រូវបានក្លែងបន្លំ និងមានការប្រកាសថាខ្លួនខាតបង់ក្នុងការរកស៊ី ឬប្រកាសទិន្នន័យក្លែងក្លាយទាំងដែលពួកគេទទួលបានប្រាក់ចំណូលជាច្រើនជារៀងរាល់ឆ្នាំ។

១.២ ធនធានហិរញ្ញវត្ថុ

មិនត្រឹមតែផ្នែកធនធានមនុស្សប៉ុណ្ណោះទេ ការធ្វើកំណែទម្រង់ពន្ធដារនេះ ក៏មានបញ្ហាប្រឈមផ្នែកធនធានហិរញ្ញវត្ថុដូចគ្នាដែរ។ វាកើតឡើងដោយសារតែ ការប្រមូលចំណូលពន្ធគ្មានលក្ខណៈបច្ចេកទេស កំណត់ត្រាពន្ធផ្សេងៗត្រូវធ្វើតាមសៀវភៅបញ្ជីនានា ដែលបណ្តាលឱ្យមានការលួចបន្លំ គេងប្រវ័ញ្ច និងមិនអាចកំណត់ពីចំនួនតួលេខច្បាស់លាស់នៃការប្រមូលចំណូលពន្ធបាន។ ចំណែកការត្រួតពិនិត្យចំណូលពន្ធ មិនមានភាពរឹងមាំ និងម៉ត់ចត់ ដោយហេតុថាទិន្នន័យទាំងអស់ មិនបានសរុបនៅការិយាល័យកណ្តាលមួយទេ គឺត្រូវចុះទៅតាមខេត្តនីមួយៗ ព្រោះបច្ចេកទេសនានាមិនអនុវត្តតាមប្រព័ន្ធកុំព្យូទ័រ ត្រូវសរសេរ និងតម្កល់ឯកសារជាក្រដាស់ ទើបអគ្គនាយកដ្ឋានពន្ធមិនអាចគ្រប់គ្រងទិន្នន័យបាន និងបាត់បង់ចំណូលមួយភាគធំផងដែរ។

មួយវិញទៀត រាជរដ្ឋាភិបាលមិនមានឯកសារលាយលក្ខណ៍អក្សរច្បាស់លាស់ លើចំនួនសហគ្រាស ឬនីតិបុគ្គលដែលជាប់បំណុលពន្ធ មានន័យថាមិនអាចក្តោបក្តាប់ទិន្នន័យនៃបុគ្គលជាប់

បំណុលពន្ធបាន បណ្ដាលឱ្យអ្នកជាប់បំណុលពន្ធមានចំនួនច្រើនអាចដល់ ៥០%នៃប្រាក់ចំណូលសរុប ហេតុផលទាំងនេះធ្វើឱ្យចំណូលពន្ធរបស់រដ្ឋមានកម្រិតទាប។ ចំណូលពន្ធ មានចំនួនតិចជាងចំណាយរបស់រដ្ឋ ទើបធ្វើឱ្យមានបញ្ហាកង្វះថវិកាសម្រាប់គាំទ្រការអនុវត្តផែនការនានា ដែលមានរួចមកហើយរបស់នាយកដ្ឋាននីមួយៗ ហើយក៏បណ្ដាលឱ្យដំណើរការរបស់នាយកដ្ឋានទាំងនោះមានការកកស្ទះ និងមានភាពយឺតយ៉ាវ។

១.៣ បទដ្ឋានគតិយុត្តិ

បទដ្ឋានគតិយុត្តិក៏ជាបញ្ហាប្រឈមមួយដ៏ខ្លាំងក្លា ដែលអគ្គនាយកដ្ឋានពន្ធដារបានយកចិត្តទុកដាក់ធ្វើវិសោធនកម្មបទប្បញ្ញត្តិជាច្រើនលើកច្រើនសារមកហើយ នៅក្នុងកំឡុងពេល៨ឆ្នាំកន្លងមកនេះ បញ្ហាប្រឈមដែលគួរឱ្យកត់សម្គាល់មានដូចជា បទប្បញ្ញត្តិច្បាប់ស្ដីពីសារពើពន្ធមួយចំនួនមានលក្ខណៈចាស់កម្រិល អនុវត្តទៅមិនសូវមានប្រសិទ្ធភាពចំពោះបច្ចុប្បន្នកាល និងសាកសមសម្រាប់ការអនុវត្តក្នុងសង្គមជាក់ស្ដែង។ បន្ថែមលើនេះ ការបង្កើត និងអនុវត្តបទប្បញ្ញត្តិនីមួយៗនៃពន្ធដារមានលក្ខណៈយឺតយ៉ាវ ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ការប្រមូលចំណូលពន្ធរបស់រដ្ឋយ៉ាងខ្លាំងក្លា។ វាក៏ជាមូលហេតុបណ្ដាលឱ្យមាន កង្វះខាតបទប្បញ្ញត្តិ ក្នុងការប្រមូលពន្ធឱ្យអស់ពីលទ្ធភាពលើវិស័យសំខាន់ៗមួយចំនួនដូចជា ធនធានធម្មជាតិ ទូរគមនាគមន៍ កាស៊ីណូ ក៏ដូចជាបទប្បញ្ញត្តិគ្រប់គ្រងបំណុលពន្ធឱ្យកាន់តែមានប្រសិទ្ធភាព និងការពង្រឹងលើបទប្បញ្ញត្តិដែលមានស្រាប់។

បទប្បញ្ញត្តិចែងពីការរកស៊ីផ្នែកធនធានធម្មជាតិ ដែលប៉ះពាល់ផលប្រយោជន៍សាធារណៈខ្លាំងក្លា ឃើញថាទើបតែមានចែងជាបទប្បញ្ញត្តិថ្មី និងច្បាស់លាស់ក្នុងឆ្នាំ២០១៨នេះ គឺពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ដែលប្រតិបត្តិការទាំងអស់នេះមានផលប៉ះពាល់ខ្លាំងលើធនធានធម្មជាតិ ចំណែកឯ ច្បាប់ស្ដីពីកាស៊ីណូវិញ ស្ថិតនៅសេចក្ដីព្រាងច្បាប់នៅឡើយ អត្រាពន្ធលើប្រតិបត្តិការដែលមានផលប៉ះពាល់ធ្ងន់ធ្ងរ តែប្រមូលចំណូលពន្ធបានទាបនៅឡើយ។ ប៉ុន្តែបើក្រឡេកទៅមើលបទប្បញ្ញត្តិ នៃអត្រាពន្ធមួយចំនួន នៅមិនទាន់សមរម្យ និងសមស្របតាមវិស័យ ឬតាមរបបអាជីវកម្មនៅឡើយ ការកំណត់ពន្ធទាប តែផលប៉ះពាល់ខ្ពស់ សំដៅទៅលើទំនិញប្រណិតមួយចំនួនដូចជា ថ្នាំជក់ និងគ្រឿងសង្ហារឹមឈើជាដើម។

ប្រទេសកម្ពុជា ពុំសូវមានកិច្ចព្រមព្រៀងអន្តរជាតិ ទាក់ទងនឹងផ្នែកពន្ធដារច្រើននោះទេ ដោយមានតែកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួនប៉ុណ្ណោះទាក់ទងនឹង ការមិនយកពន្ធត្រួតគ្នា ជាមួយនឹងប្រទេសសឹង្ហបុរី ប្រទេសថៃ ប្រទេសវៀតណាជាដើម។ ទើបធ្វើឱ្យចំនួនវិនិយោគិនបរទេសនៅក្នុងប្រទេសកម្ពុជាមានតិច បើធៀបនឹងប្រទេសជិតខាង ដូចជា ប្រទេសថៃមានកិច្ចព្រមព្រៀងអន្តរជាតិស្តីពីពន្ធដារ ជាង១០០ឯណោះ ដែលធ្វើឱ្យចំនួនវិនិយោគិនបរទេសមានច្រើន ហើយធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើនខ្លាំងក្លា។

ចំណែកឯបទប្បញ្ញត្តិខ្លះដែលចែងពី នីតិវិធីនៃការបង់ពន្ធមានលក្ខណៈស្មុគស្មាញច្រើន និងបទប្បញ្ញត្តិដែលដាក់ទណ្ឌកម្មដល់ក្រុមហ៊ុន សហគ្រាស ឬបុគ្គលមួយចំនួនដែល បង់ពន្ធយឺតយ៉ាវឬគេចវេសពន្ធ ពុំសូវមានឥទ្ធិពលគ្រប់គ្រាន់លើបុគ្គលទាំងនោះ។ ឧទាហរណ៍ អ្នកមានអំណាច ឬមន្ត្រីមានអំណាច ឬអ្នកមានទ្រព្យមួយចំនួនមិនព្រមបង់ជូនរដ្ឋ វាជាការពិបាកមួយដែលប្រជាជនមិនគោរពតាមបទប្បញ្ញត្តិច្បាប់។[36]

## ២. សមិទ្ធផល

### ២.១ ផ្នែករដ្ឋបាល

អគ្គនាយកដ្ឋានពន្ធដារបានប្រែមុខមាត់ថ្មី មានភាពទំនើបកម្មជាងមុន ដែលមានការគ្រប់គ្រងប្រព័ន្ធទិន្នន័យរឹងមាំ ការផ្តត់ផ្គង់សេវាមានភាពឆាប់រហ័ស មានប្រសិទ្ធភាពខ្ពស់ជាងមុន និងផ្តល់ភាពងាយស្រួល ដល់អ្នកជាប់ពន្ធជាច្រើនដូចជា ការបង្កើតប្រព័ន្ធព័ត៌មាន ទាក់ទងនឹងពន្ធដារកាន់តែមានភាពទូលំទូលាយ ការប្រកាសពន្ធមានលក្ខណៈទំនើប អាចធ្វើការប្រកាសតាមប្រព័ន្ធអីនធើណេតបាន កន្លែងបង់ពន្ធមានដាក់នូវប្រព័ន្ធចាប់លេខ ដែលផ្តល់ភាពងាយស្រួល និងប្រកបដោយយុត្តិធម៌ចំពោះប្រជាជនជាប់ពន្ធគ្រប់រូប។

ភាពស្មុគស្មាញជាច្រើន ក្នុងការបង់ពន្ធត្រូវបានកាត់បន្ថយអស់មួយចំនួនធំ ឧទាហរណ៍៖ ពីមុនដើម្បីដាក់លិខិតប្រកាសពន្ធត្រូវធ្វើច្រើនដំណាក់កាលយ៉ាងតិច ៦ដំណាក់កាល ដោយពេលបច្ចុប្បន្ន បុគ្គលជាប់ពន្ធគ្រាន់តែចូលវេបសាយបំពេញព័ត៌មាន យកប្រាក់ទៅបង់នៅធនាគារ ជា

[36] ភ្នំពេញ, ២០១៥, ការបង់ពន្ធអចលនទ្រព្យ នៅតែជួបបញ្ហាប្រឈម ,Everyday, ២៩ មករា, http://www.everyday.com.kh/article/36331.html (បានចូលមើលចុងក្រោយ ២៧ ឧសភា ២០១៨)

ចុងបញ្ចប់យកឯកសារទៅអគ្គនាយកដ្ឋានពន្ធដារជាការស្រេចដែលវាមានភាពឆាប់រហ័ស និងងាយស្រួលជាងពីអាណត្តិមុនៗ។ បន្ទាប់ពីការគ្រប់គ្រងបានល្អហើយ បំណុលពន្ធក៏ត្រូវបានកាត់បន្ថយដែលធ្វើឱ្យមានកំណើននៃចំណូលពន្ធ។

ចំពោះការគ្រប់គ្រងធនធានមនុស្ស មានការរើសបុគ្គលិកថ្មី និងកែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុងជាច្រើនដើម្បីឱ្យការបម្រើការនានាដើរទាន់នូវភាពទំនើបកម្មនៃវឌ្ឍនភាពនេះ។ កំណត់ម៉ោងធ្វើការនៃបុគ្គលិកប្រសើរជាងមុន និងមានការប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើប ដើម្បីកំណត់វត្តមានរបស់បុគ្គលិកក៏ដូចជាវិន័យតឹងរឹងជាងមុន និងល្អប្រសើរផងដែរ។

ដំណើរការប្រព្រឹត្តិទៅរបស់នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានពន្ធដារ មានមុខងារកាន់តែមានភាពច្បាស់លាស់ជាងមុន និងការអនុវត្តកាន់តែមានប្រសិទ្ធភាពខ្ពស់ ចំណែកឯប្រជាពលរដ្ឋកាន់តែមានទំនុកចិត្តចំពោះការផ្តត់ផ្គង់សេវារបស់អគ្គនាយកដ្ឋានពន្ធផងដែរ។

២.២ ការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

បើយើងពិនិត្យទៅលើទិន្នន័យពីមួយឆ្នាំទៅមួយឆ្នាំក្នុងរូបទីមួយ យើងនឹងអាចសម្គាល់បានថាការប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងអាណត្តិទី៥នេះ គឺមានការកើនឡើងជារៀងរាល់ឆ្នាំ ហើយកើនឡើងយ៉ាងខ្ពស់ផងដែរ ដោយចាប់ពី ៣ ៦០៥.៨៩ ពាន់លានរៀល (ប្រមាណជា ៩០១.២២ លានដុល្លារ) ក្នុងឆ្នាំ២០១៣ ដល់ ៧,៧៥៥.៨១ ពាន់លានរៀល (ប្រមាណជា ១,៩៣៨.៧១ លានដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៧ បើធៀបនឹងឆ្នាំ២០១៦ ការប្រមូលពន្ធក្នុងឆ្នាំ២០១៧ មានការកើនឡើងចំនួន ២៧.៨៩% (រូបភាពទី១) មានន័យថាយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលពិតជាមានប្រសិទ្ធិភាពខ្ពស់ពិតមែន។[37] លទ្ធផលដែលសម្រេចបានទាំងអស់នេះ បានសបញ្ជាក់ឱ្យឃើញថាក្នុងអាណត្តិទី៥ រយៈពេល៥ឆ្នាំជាងកន្លងមកនេះចំណូលពន្ធកើនឡើងក្នុងកម្រិតខ្ពស់ ដែលធ្វើឱ្យប្រទេសដ៏ទៃទៀតមានការភ្ញាក់ផ្អើល និងស្ញប់ស្ញែងដល់អគ្គនាយកដ្ឋានពន្ធដារ និងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្រេច

[37] សេចក្តីប្រកាសព័ត៌មានស្តីពី កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០១៧ ព្រមទាំងទិសដៅសម្រាប់ការអនុវត្តបន្តឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានពន្ធដារសាលាជាតិពន្ធដារ ថ្ងៃព្រហស្បត្តិ៍ ០៩កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨, ២៥ មករា ២០១៨

បានសមិទ្ធផលដ៏ល្អមួយនេះ។ រាជរដ្ឋាភិបាលក៏នៅតែបន្តរិះរកគោលការណ៍ និងយុទ្ធសាស្ត្រថ្មីៗ ដើម្បីធ្វើយ៉ាងណាឱ្យការកើនឡើងនូវការប្រមូលចំណូលពន្ធនេះ នៅតែបន្តជារៀងដរាបតរៀងទៅ ហើយវាក៏បានសបញ្ជាក់ឱ្យឃើញថាសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាមានវឌ្ឍនភាព ដូច្នេះជីវភាពរបស់ប្រជាជនកាន់តែមានភាពល្អប្រសើរជាងមុនផងដែរ។ បំណុលពន្ធទៀតសោត អគ្គនាយកដ្ឋានពន្ធដារធ្វើបានកាន់តែល្អប្រសើរចំពោះការប្រមូលបំណុលពន្ធនេះ ដែលនីតិវិធីមានប្រសិទ្ធភាពខ្ពស់ជាងមុន។

រូបភាពទី១៖ សមិទ្ធផលនៃការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារឆ្នាំ២០១១ ដល់២០១៧




*(ប្រភពមកពី៖ វីដេអូមួយមានចំណងជើងថា* "Call Center and Live Chat"*, វេសាយផ្លូវការនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ០៥ មករា ២០១៨,* http://www.tax.gov.kh/videos.php?Id=*12* )

ស្របគ្នានេះផងដែរ កាលណារដ្ឋប្រមូលបានថវិកាច្រើន ចំណូលក៏កើនឡើង ការស្ថាបនា ការអភិវឌ្ឍន៍លើវិស័យនានា ក៏រីកដុះដាលដូចផ្សិត ជាងនេះទៅទៀតអ្វីដែលប្រជាជនត្រូវការ គឺ ប្រាក់ចំណូល ពោលប្រាក់ខែមន្ត្រីរាជការត្រូវបានតម្លើងជាបន្ទាប់បន្ទាប់ ហើយប្រាក់បៀវត្សនៃ មន្ត្រីរាជការក៏បានតម្លើងខ្ពស់នាប៉ុន្មានឆ្នាំកន្លងមកនេះ ហើយលើសពីនេះទៅទៀតរាជរដ្ឋាភិបាលក៏ មានគម្រោងនឹងផ្តល់ប្រាក់បៀវត្សចំពោះកម្មករ កម្មការនីនាពេលឆាប់ៗខាងមុខ។

ទាំងអស់នេះបានមក ដោយសារតែកំណើន ផ.ស.ស ដ៏រឹងមាំ ៥ឆ្នាំកន្លងមកនេះ ហើយក្នុង អាណត្តិទី៥នេះ រាជរដ្ឋាភិបាលនូវតែអាចរក្សាបាននូវកំណើន ផ.ស.ស ក្នុងរង្វង់ ៧% ដ៏ដែល ក្នុងឆ្នាំ ២០១៧ (រូបភាពទី២) ផ.ស.ស ត្រូវប៉ាន់ស្មានថា ផ.ស.ស សម្រាប់មនុស្សម្នាក់អាចនឹងកើនឡើង ដល់ ១,៤៣៤ ដុល្លាអាមេរិក។ ជាមួយគ្នានេះផងដែរ អត្រាប្តូរប្រាក់នៅតែបន្តមានស្ថេរភាពជាមួយ ការរំពឹងទុកថា ប្រាក់រៀលនឹងនៅបន្តរក្សាបាននូវតម្លៃប្រមាណ ៤,០៣៧ រៀល ក្នុង១ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១៧។

រូបភាពទី២៖ កំណើន ផ.ស.ស និងការចូលរួមចំណែកដល់កំណើនតាមវិស័យនីមួយៗ




*(ប្រភពមកពី៖ "សូចនាករម៉ាក្រូសេដ្ឋកិច្ច" វេបសាយផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* https://www.mef.gov.kh/ *, ១៦ មករា ២០១៧)*

សមិទ្ធផលមួយទៀត ដែលយើងគួរផ្តោតការចាប់អារម្មណ៍នោះគឺ បំណុលសាធារណៈដែលរាជរដ្ឋាភិបានធ្វើកម្ចីពីប្រទេសដ៏ទៃៗមានទឹកប្រាក់សរុបចំនួន ៧,៦៥៩.៩០ លានដុល្លារអាមេរិកគិតត្រឹមឆ្នាំ២០១៧ ដែរជាតួលេខមួយដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បញ្ជាក់ថា ប្រទេសកម្ពុជានៅអាចគ្រប់គ្រងបំណុលសាធារណៈបានល្អ និងមិនមានហានិភ័យនោះទេ បើយកតួលេខនោះទៅធៀបនឹងចំនួនប្រជាជនកម្ពុជាសរុបចំនួនប្រហែលជា ១៥លាននាក់ មានន័យថាប្រជាជនម្នាក់ៗជំពាក់បំណុលបរទេសជាង ៥០០ ដុល្លារតែប៉ុណ្ណោះ ដែលបញ្ជាក់ថាប្រទេសកម្ពុជាមានចំណូលខ្លួនឯងដែលអាចធ្វើការទប់ទល់នឹងចំណាយបាន និងអាចអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើនទៀតផង។[38] បំណុលទាំងនោះត្រូវបានធ្វើការខ្ចី ដើម្បីគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល សំដៅក្នុងការចូលរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនរយៈពេលវែង និងបង្កើនផលិតភាពសេដ្ឋកិច្ច។

[38] "តើបំណុលកម្ពុជាជំពាក់បរទេសស្ថិតក្នុងកម្រិតហានិភ័យហើយឬនៅ", VOD, ០៨ វិច្ឆិកា ២០១៧, https://vodhotnews.com/08/11/2017/is-cambodias-foreign-debt-risky/ (បានមើលចុងក្រោយ ២៧ ឧសភា ២០១៨)

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការស្តារស្ថានភាពប្រទេស ឱ្យមានភាពរឹងមាំរយៈពេល២ទស្សវត្សកន្លងទៅនេះ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រទេសគ្រប់វិស័យទាំងអស់ ដូចជា ការអប់រំ ការវិនិយោគ ការស្តារហេដ្ឋារចនាសម្ព័ន្ធ និងកំណែទម្រង់នានាជាដើម។ ជាពិសេស ការពង្រឹងចំណូលនៃប្រទេសកម្ពុជានេះតែម្តង ដែលអនុវត្តតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ ស្របទៅតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ សម្រាប់នីតិកាលទី៥ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។

ឈរមូលដ្ឋានកំណែទម្រង់ពន្ធដារក្នុងអាណត្តិទី៥នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានរចនាដាក់ចេញមក ដើម្បីឆ្លើយតបទៅនឹង បេសសកម្មធំៗពីរគឺៈ ទីមួយ-ការពង្រឹងប្រសិទ្ធភាព នៃការអនុវត្តការងារ និងការបង្កើនចំណូលពន្ធនៅក្នុងអគ្គនាយកដ្ឋានពន្ធដារ និងទីពីរ-ការបន្តដំណើរទៅមុខក្នុងជំនឿយ៉ាងមុតមាំ ដោយសម្រេចឱ្យបានពេញលេញ នូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ព្រមទាំងសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងអាណត្តិនេះតាមយុទ្ធសាស្ត្រចតុកោណនីតិកាលទី៣។ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ដើម្បីឱ្យស្របតាមការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល អគ្គនាយកដ្ឋានពន្ធបានធ្វើកំណែទម្រង់យ៉ាងច្រើន ដោយផ្តោតលើចំណុចសំខាន់ធំៗពីរគឺៈ កំណែទម្រង់លើផ្នែករដ្ឋបាល និងកំណែទម្រង់សារពើពន្ធ។ ជាការពិតណាស់រាល់ការផ្លាស់ប្តូរនូវអ្វីមួយ វាមានការពិបាកទាំងការស្វែងរកយុទ្ធសាស្ត្រថ្មីមកធ្វើការផ្លាស់ប្តូរ បន្ទាប់ពីផ្លាស់ប្តូរហើយក៏មានការពិបាកក្នុងការអនុវត្តទៀត ព្រោះត្រូវចំណាយពេលក្នុងការផ្សាំនឹងភាពថ្មី ក៏ដូចជាការកំណែទម្រង់ថ្មីនៃអគ្គនាយកដ្ឋានពន្ធដារ ដែលជាកិច្ចការមានភាពលំបាក ស្មុគស្មាញ មានលក្ខណៈជាប្រព័ន្ធ និងជួបនូវបញ្ហាប្រឈមជាច្រើន ដែលទាមទារឱ្យក្រសួង ស្ថាប័ន និងបុគ្គលផ្សេងៗ ដែលពាក់ព័ន្ធទាំងអស់នៅក្នុងសង្គមដោយមានការចូលរួមសហការដោយយកចិត្តទុកដាក់ ដើម្បីសម្រេចនូវចក្ខុវិស័យ គោលដៅ និងគោលបំណងដែលបានកំណត់ ក្នុងការអភិវឌ្ឍន៍ប្រទេសទាំងអស់គ្នា ដោយប្រកាន់ភ្ជាប់នូវគោលការណ៍ ៤សំខាន់ៗ ដែល

ត្រូវបានដាក់ចេញមកដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** គឺ "ប្រមូលចំណូលឱ្យអស់លទ្ធភាព មិនបង្កើតប្រភេទពន្ធថ្មី មិនដំឡើងអត្រាពន្ធនិងអាករ និងចុងក្រោយត្រូវធានាឱ្យបាននូវភាពងាយស្រួល សមធម៌ យុត្តិធម៌ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធ"។ សមិទ្ធផលសំខាន់ៗដ៏គួរឱ្យកត់សម្គាល់ក្នុងការធ្វើកំណែទម្រង់នេះរួមមាន៖ ដំណើរការនៃការផ្លាស់ប្តូរពី បរិមាណទៅគុណភាព នៅក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធ ការបង្កើនផលិតភាពការងារ ដោយផ្តល់សារៈសំខាន់កាន់តែខ្លាំងឡើង លើការវិនិយោគ "មូលធនពុទ្ធិ" ពោលគឺការអភិវឌ្ឍន៍ធនធានមនុស្ស ពិសេសលើយុវជនដែលមានសមត្ថភាពក្នុងវិស័យពន្ធដារនេះតែម្តង ដែលមានការផ្តល់ឱកាសឱ្យប្រលងជាមន្ត្រីក្របខណ្ឌ និងកិច្ចសន្យាជាច្រើនរូប ឱ្យស្របនឹងស្ថានភាពជាក់ស្តែងនាសម័យបច្ចេកវិទ្យាជឿនលឿននាពេលបច្ចុប្បន្ន ហើយស្ត្រីភេទក៏ត្រូវបានទទួលនូវសិទ្ធិអាទិភាពខ្ពស់ផងដែរ។ ដូច្នេះហើយ ការគ្រប់គ្រងតាមប្រព័ន្ធអេឡិចត្រូនិច និងបច្ចេកវិទ្យាទំនើបផ្សេងៗទៀត ដែលធ្វើឱ្យការប្រមូលចំណូលពន្ធកាន់តែមានភាពងាយស្រួល ម៉ត់ចត់ និងច្បាស់លាស់ ដែលជាហេតុបណ្តាលឱ្យ ការប្រមូលពន្ធមានប្រសិទ្ធភាពជាងកាលកន្លងទៅ។ ការបង្កើនវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈឱ្យកាន់តែប្រសើរឡើងនេះហើយ ទើបអគ្គនាយក-ដ្ឋានពន្ធដារទទួលបាននូវការគាំទ្រ និងជឿទុកចិត្តកាន់តែខ្លាំងឡើង ពីសំណាក់ប្រជាជន និងអ្នកជាប់ពន្ធនានា។ កំណែទម្រង់ទាំងនេះហើយ ទើបធ្វើឱ្យសម្រេចបាននូវកំណើនចំណូលពន្ធខ្ពស់ប្រកបដោយចីរភាព ក្នុងអត្រាប្រមាណជាមធ្យម២០% ក្នុងមួយឆ្នាំលើសពីការកំណត់នៃផែនការច្បាប់ ក្នុងរយៈពេលពាក់កណ្តាលទសវត្សរ៍ចុងក្រោយនេះ។ វាក៏ជាហេតុផលមួយ បណ្តាលឱ្យមានការកាត់បន្ថយអត្រានៃភាពក្រីក្រនៃប្រជាជនក្នុងប្រទេស ដោយរាជរដ្ឋាភិបាលសម្រេចបានលើស ១%ក្នុងមួយឆ្នាំ។

ផ្អែកលើសមិទ្ធផលសម្រេចបាន សក្តានុពលដ៏ធំធេងនៃព្រះរាជាណាចក្រកម្ពុជា ឆន្ទៈដ៏មុះមុត និងទេពកោសល្យរបស់ប្រជាជនកម្ពុជា ព្រមទាំងការតម្រឹម ការបន្សាំ និងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព រាជរដ្ឋាភិបាលបានកំណត់គោលដៅ ឱ្យប្រទេសកម្ពុជាប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។

# ឧបសម្ព័ន្ធ

# អនុសាសន៍

៙៙📖៙៙

បន្ទាប់ពីបានធ្វើការសិក្សាយ៉ាងម៉ត់ចត់ពី កំណែទម្រង់ពន្ធដារ ក្នុងអាណត្តិទី៥នៃរាជរដ្ឋាភិបាលកម្ពុជារួចមក សបញ្ជាក់ថា ប្រទេសកម្ពុជាមានវឌ្ឍនភាពយ៉ាងខ្លាំងក្លាតាំងពីចាប់ផ្តើមនៃកំណែទម្រង់ រហូតមកដល់ បច្ចុប្បន្នភាពដែលចំណូលសារពើពន្ធមានការកើនឡើងលើសពីផែនការកំណត់ជារៀងរាល់ឆ្នាំ។ សមិទ្ធផលទាំងនេះគឺកើតចេញពីយុទ្ធសាស្ត្រដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងយន្តការគាំទ្រនានាដែលអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ទទួលភារកិច្ចប្រមូលពន្ធបញ្ចូលទៅក្នុងចំណូលជាតិ ដើម្បីអភិវឌ្ឍប្រទេស ក៏ដូចជាសេដ្ឋកិច្ចប្រទេសឱ្យមានការកើនឡើងជាលំដាប់។

ថ្វីបើយុទ្ធសាស្ត្រដែលកំពុងអនុវត្តដូចជា យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ឆ្នាំ ២០១៤-២០១៨ មានប្រសិទ្ធភាពមែនពិត ប៉ុន្តែដោយបរិការណ៍នៃសេដ្ឋកិច្ច និងតម្រូវការនៃការអភិវឌ្ឍន៍ប្រទេសជាតិខ្ពស់ រាជរដ្ឋាភិបាលគួរតែដាក់ចេញនូវយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត ដោយផ្អែកលើការប្រមូលចំណូលជាតិ ឱ្យកាន់តែកើនឡើងខ្ពស់ថែមមួយកម្រិតទៀត។ ដូច្នេះ ក្រុមយើងខ្ញុំសូមធ្វើការផ្តល់ជាមតិមួយចំនួន ក្នុងន័យជាធាតុបន្ថែមសម្រាប់យុទ្ធសាស្ត្របង្កើនចំណូលជាតិឱ្យកាន់តែកើនឡើង សម្រាប់បំពេញបន្ថែមនូវចន្លោះខ្វះខាតនានា។

គួរតែមានការបង្កើតប្រភេទពន្ធបន្ថែម ដូចជាពន្ធលើផលប៉ះពាល់បរិស្ថានជាដើម អនុវត្តចំពោះបុគ្គល ដែលធ្វើឱ្យប្រទេសមានភាពកង្វក់ អាចជាការបំពុលខ្យល់ បំពុលទឹក ឬផ្សេងៗ ដែលប៉ះពាល់ដល់បរិយាកាសធម្មជាតិ។ ចំពោះអត្រាពន្ធវិញ ក៏គួរតែមានចំនួនច្រើនទ្វេដង ដើម្បីឱ្យបុគ្គលទាំងនោះមានការរាងចាល និងភ្ញាក់រលឹកពីកំហុសដ៏ធ្ងន់ធ្ងរ របស់ខ្លួនចំពោះមនុស្សជុំវិញខ្លួន។

ចំណែកឯអត្រាពន្ធលើទំនិញប្រណិតមួយចំនួនវិញ មន្ត្រីមានសមត្ថកិច្ចនានាគួរពិចារណាឡើងវិញ ទៅលើមុខទំនិញទាំងអស់នោះ ដូចជា ផលិតផលស្រា បារី ឈើប្រណិតជាដើម ដែលនាពេលបច្ចុប្បន្នអត្រាពន្ធមានចំនួនតិច តែផលប៉ះពាល់ធ្ងន់ធ្ងរ។ បើធៀបនឹងប្រទេសជិតខាងដូចជា

ប្រទេសឡាវ ពន្ធលើបារី មានចំនួនដល់ទៅ ៦០% ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា អត្រាពន្ធត្រឹមតែ ២០% តែប៉ុណ្ណោះ។

ពន្ធលើការផ្ទេរប្រាក់ចំណេញទៅប្រទេសដើម ក្នុងប្រទេសកម្ពុជាមិនមានការគិតពន្ធទេ តែបើនៅក្នុងប្រទេសថៃវិញ ត្រូវបានគិតអត្រាពន្ធដល់ទៅ ១៥% នៃការផ្ទេរប្រាក់ចំណេញនេះ ដូច្នេះយើងគួរតែគិតគូលើចំណុចមួយនេះផង។

ជាការពិតណាស់ កម្ពុជាមានប្រភេទពន្ធមួយទៀត គឺពន្ធលើចំណូលរូបវន្តបុគ្គល ដែលជាពន្ធផ្ទាល់ ត្រូវបង់ដោយរូបវន្តបុគ្គល ហើយធ្វើការគណនាប្រាក់ពន្ធដោយខ្លួនឯង។ ប៉ុន្តែមកទល់បច្ចុប្បន្ន ប្រភេទពន្ធនេះ ពុំទាន់ត្រូវបានអនុវត្តឡើយ ដោយមូលហេតុថាពុំមានលិខិតបទដ្ឋានគតិយុត្តិណាមួយ ដែលជាយន្តការគាំទ្រ ដើម្បីអាចធ្វើការអនុវត្តលើការប្រមូលពន្ធនេះឡើយ។ ទោះជាយ៉ាងនេះក្តី នៅក្នុងអាណត្តិក្រោយ មន្ត្រីមានសមត្ថកិច្ច គប្បីធ្វើការសិក្សា និងពិភាក្សាលើបទដ្ឋានគតិយុត្តិ និងយន្តការនានា ដើម្បីកំណត់នីតិវិធី លើការប្រមូលពន្ធប្រាក់ចំណូលរូបវន្តបុគ្គលនេះ ដើម្បីបង្កើនប្រភពចំណូលថ្មីសម្រាប់ថវិកាជាតិ។

ចំណុចមួយទៀតនោះ អ្នកជាប់ពន្ធតូច ទោះបីជាអ្នកជាប់ពន្ធតូច ហាក់បីដូចជាមានផលរបរតិច ឬបង់ពន្ធមានបរិមាណតិចតួចក៏មែនពិត ប៉ុន្តែចំណូលពន្ធសរុប មួយភាគក៏បានមកពីបុគ្គលជាប់ពន្ធទាំងនោះផងដែរ។ ម្ល៉ោះហើយដើម្បីការបង់ពន្ធកាន់តែមានសុចរិតភាព តម្លាភាព និងគណនេយ្យភាពត្រឹមត្រូវ អគ្គនាយកដ្ឋានពន្ធដារ រួមទាំងមន្ត្រីនៅតាមការិយាល័យពន្ធដារស្រុកនីមួយៗ ត្រូវមាននីតិវិធីបន្ថែម ទៅលើការកាន់បញ្ជិការគណនេយ្យ របស់អ្នកជាប់ពន្ធតូចផ្ទាល់។ ការធ្វើបែបនេះ គឺនឹងផ្តល់នូវលទ្ធភាព ដល់អគ្គនាយកដ្ឋានពន្ធដារក្នុងការគ្រប់គ្រងទិន្នន័យ របស់អ្នកជាប់ពន្ធតូច កាន់តែមានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយសុចរិតភាព។

ការគ្រប់គ្រងទិន្នន័យ នៃអចលនទ្រព្យ ក៏ជាចំណុចមួយគួរឱ្យចាប់អារម្មណ៍ដែរ។ ការគ្រប់គ្រងពន្ធលើអចលនទ្រព្យ ពុំទាន់មានវិសាលភាពទូទាំងប្រទេសនៅឡើយទេ ដោយសារការចុះបញ្ជីនៃអចលនទ្រព្យមានភាពយឺតយ៉ាវ និងមិនទាន់សភាពការណ៍នៅឡើយ។ ទោះបីជា

បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារមានក្រុមការងារចុះធ្វើបច្ចុប្បន្នភាព និងចុះបញ្ជីអចលនទ្រព្យមែន-ពិត ប៉ុន្តែដំណើរការនៅមានសភាពយឺតយ៉ាវ និងខ្វះខាតធនធានមនុស្សសម្រាប់អនុវត្ត។ ហេតុដូចនេះហើយ អគ្គនាយកដ្ឋានពន្ធដារគួរតែបង្កើនចំនួនក្រុមការងារចុះបញ្ជី ឱ្យមានបរិមាណច្រើនតាមតម្រូវការ ដើម្បីពន្លឿនដំណើរការចុះបញ្ជីអចលនទ្រព្យឱ្យបានទូទាំងខណ្ឌទាំង១២ នៅក្នុងរាជធានី-ភ្នំពេញ និងទូទាំង២៣ ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

បន្ថែមពីលើនេះទៀត អគ្គនាយកដ្ឋានពន្ធដារ ត្រូវតែយកចិត្តទុកដាក់ជាចម្បងលើផ្នែករដ្ឋបាលរបស់ខ្លួន ជាពិសេសការផ្តត់ផ្តង់សេវាសាធារណៈ ជូនអ្នកជាប់ពន្ធទូទាំងប្រទេស ដែលគួរបម្រើអ្នកជាប់ពន្ធ ដោយរុះរស់រាក់ទាក់ ស្មោះត្រង់ ប្រកបដោយវិជ្ជាជីវៈខ្ពស់ ក្រមសីលធម៌ល្អ មិនប្រព្រឹត្តនូវអំពើពុករលួយ និងមានរចនាសម្ព័ន្ធល្អ មានន័យថា ត្រូវបង្កើននូវគុណភាពក្នុងការបម្រើសេវាដល់អ្នកជាប់ពន្ធទ្វេដង ឱ្យសមស្របទៅនឹងអភិក្រម របស់សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន គឺ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់" ។

# ឯកសារយោង

# ឯកសារយោង

ᢀᢀᢀ📖ᢀᢀᢀ

❖ **លិខិតបទដ្ឋានគតិយុត្តថ្នាក់ជាតិ**

**ច្បាប់**

- ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣
- ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨, លេខ នស/រកម/១២១៧/០១៩, ១៧ វិច្ឆិកា ២០១៧
- ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ នស/រកម/១២១៦/០១៩, ២២ វិច្ឆិកា ២០១៦
- ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦, លេខ នស/រកម/១២១៥/០១៦, ៣០ វិច្ឆិកា ២០១៥
- ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥, លេខ នស/រកម/១២១៣/០២៦, ២៨ វិច្ឆកា ២០១៤
- ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤, លេខ នស/រកម/១១១៣/០១៥, ១២ វិច្ឆិកា ២០១៣
- ច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣, លេខ នស/រកម/១២១២/០១០, ០៧ ធ្នូ ២០១២
- ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីសារពើពន្ធ, លេខ នស/រកម/០៣០៣/០១០, ០៤ កុម្ភៈ ២០០៣
- ច្បាប់ស្តីពី សារពើពន្ធ, លេខ នស.រកម.០២៩៧.០៣/២៤ កុម្ភៈ ១៩៩៧/ស្តីពីសារពើពន្ធ, ០៨ មករា ១៩៩៧
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨, លេខ នស/រកម/០៧១៤/០១៩, ២៦ មិថុនា ២០១៤

**អនុក្រឹត្យ**

- អនុក្រឹត្យ ស្តីពី ការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ ១៣៤ អនក្រ-បក, ១៥ កញ្ញា ២០០៨
- អនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ, លេខ ០៣ អនក្រ-បក, ០៦ មករា ២០១៦
- អនុក្រឹត្យស្តីពី វិធាន និងនីតិវិធីនៃការលើកលែង និងអនុគ្រោះពន្ធប្រថាប់ត្រា, លេខ ២៧ អនក្រ.បក, ២៤ កុម្ភៈ ២០១៧

**ប្រកាស**

- ប្រកាសស្តីពី ការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស, លេខ ០២៥ សហវ-ប្រក.អពដ, ២៤ មករា ២០១៨
- ប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ, លេខ ១២៣២ សហវ.ប្រក, ៣០ វិច្ឆិកា ២០១៧
- ប្រកាសស្តីពី ការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស, លេខ ១៨១៩ សហវ-ប្រក, ២៥ ធ្នូ ២០១៥
- ប្រកាសស្តីពី ការលើកទឹកចិត្តពន្ធដារចំពោះគ្រឹះស្ថានសិក្សា, លេខ ៩០៤ សហវ-ប្រក, ០៨ សីហា ២០១៦
- ប្រកាសស្តីពី ការចុះបញ្ជីពន្ធដារ, លេខ ៤៩៦ សហវ, ០៦ មេសា ២០១៦
- ប្រកាសស្តីពី វិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ ១៤៧០ សហវ-ប្រក, ០៦ វិច្ឆិកា ២០១៥

## សារាចរណែនាំ

- សារាចរណែនាំស្តីពី ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លេខ០០១ សហវ, ០៣ មករា ២០១៤
- សារាចរណែនាំស្តីពី ការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើប្រាក់បៀវត្ស និងពន្ធលើអត្ថប្រយោជន៍បន្ថែម, លេខ ០០២ សហវ, ២០ មករា ២០១៥
- សារាចរណែនាំស្តីពី ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, លេខ ០៤ សរណន, ០៩ មិថុនា ២០១៦

## របាយការណ៍

- របាយការណ៍ការអនុវត្តការងារពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលអាណត្តិទី៥ គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៣ រហូតមកដល់ ខែធ្នូ ឆ្នាំ២០១៤

## សេចក្តីប្រកាសព័ត៌មាន

- សេចក្តីប្រកាសព័ត៌មានស្តីពី កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០១៧ ព្រមទាំងទិសដៅសម្រាប់ការអនុវត្តបន្តឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានពន្ធដារសាលាជាតិពន្ធដារ ថ្ងៃព្រហស្បតិ៍ ០៩កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨, ២៥ មករា ២០១៨

## ❖ ឯកសារដែលចងក្រងជាសៀវភៅ និងឯកសារផ្សេងៗ

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា. យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨. www.tax.gov.kh (១៨ មករា ២០១៥)
- អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. សៀវភៅណែនាំស្តីពី ពន្ធលើប្រាក់ចំណេញ. www.tax.gov.kh (២០១៣)
- វេង គួងហេង. ២០១៨. តើអ្វីទៅជាអាករលើតម្លៃបន្ថែម. http://bizdoctors.asia/តើអ្វីទៅជាអាករលើតម្លៃប-2/ (ចេញផ្សាយ ២៣ មករា ២០១៨)

- លោក ឌី ចន្ទឌឿន (Dy Chandoeun). សំណួរ-ចម្លើយត្រៀមប្រឡងពន្ធដារ. លេខទូរស័ព្ទទំនាក់ទំនង ០៨៨ ៨៩៥ ២០០៦ (ពុំមានបញ្ជាក់ថ្ងៃ)
- លោក គង់ ប៊ុនធី. ២០១៣. នីតិពន្ធដារ. https://80reansot.wordpress.com (ចេញផ្សាយ ០៣ សីហា ២០១៣)
- សេចក្តីប្រកាសពតិមាន ស្តីពី ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលជួបសម្តែងការគួរសមរបស់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ និងផ្តល់អនុសាសន៍អំពីប្រព័ន្ធពន្ធដារកម្ពុជា និងកំណែទម្រង់រដ្ឋបាលសារពើពន្ធ, www.tax.gov.kh , ២៧ កញ្ញា ២០១៧
- សេចក្តីប្រកាសពតិមាន ស្តីពី ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ក្នុងសិក្ខាសាលាស្តីពី "ពន្ធប្រថាប់ត្រាលើការផ្ទេរយានយន្ត កំណែទម្រង់រដ្ឋបាលសារពើពន្ធ (E-Payment) និងកាតព្វកិច្ចពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ", www.tax.gov.kh , ០៥ មករា ២០១៨
- សេចក្តីប្រកាសព័ត៌មានស្តីពី កិច្ចប្រជុំស្តីពីការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រារបស់អគ្គនាយកដ្ឋានពន្ធដារ, www.tax.gov.kh , ០៧ ឧសភា ២០១៧


❖ **ប្រព័ន្ធផ្សព្វផ្សាយ និងគេហទំព័រផ្សេងៗ**


- www.mef.gov.kh
- www.tax.gov.kh
- https://80reansot.wordpress.com
- ភ្នំពេញ, ២០១៨, ឆ្នាំ២០១២៧ អគ្គនាយកដ្ឋានពន្ធដារប្រមូលពន្ធបានជិត២ពាន់លានដុល្លាអាមេរិក, ខេមបូណូមីស, https://cambonomist.com/news/tax-revenue-2017/ (បានចូលមើលចុងក្រោយ ២៧ ឧសភា ២០១៨)
- ភ្នំពេញ, ២០១៨, នាយកដ្ឋានពន្ធដារបង្កើត កម្មវិធីទូរស័ព្ទ សម្រាប់ពិនិត្យលិខិតសវនកម្ម, ភ្នំពេញប៉ុស្តិ៍, ២៧ មីនា, https://www.postkhmer.com/របាយការណ៍ពិសេស

នាយកដ្ឋាន/ពន្ធដារបង្កើត-app-សម្រាប់ត្រួតពិនិត្យលិខិតសវនកម្ម (បានចូលមើលចុងក្រោយ ១៨ មេសា ២០១៨)

- ភ្នំពេញ, ២០១៧, អគ្គនាយកពន្ធដារប្រកាសដាក់ឱ្យដំណើរការការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិច, Vayofm, ២១ វិច្ឆិកា, http://vayofm.com/news/detail/84974-813607610.html (បានចូលមើលចុងក្រោយ ១៨ មេសា ២០១៨)
- ភ្នំពេញ, ២០១៧, តើបំណុលកម្ពុជាជំពាក់បរទេសស្ថិតក្នុងកម្រិតហានិភ័យហើយឬនៅ?, VOD, ០៨ វិច្ឆិកា, https://vodhotnews.com/08/11/2017/is-cambodias-foreign-debt-risky/ (បានចូលមើលចុងក្រោយ ២៧ ឧសភា ២០១៨)
- ភ្នំពេញ, ២០១៦, រាជរដ្ឋាភិបាលប្រកាសមិនតំឡើងពន្ធរយៈពេល២ឆ្នាំ ប៉ុន្តែពង្រីកវិសាលភាពប្រមូលពន្ធ, KHMER TIMES, ២២ កញ្ញា, https://www.khmertimeskh.com/news/30059/ (បានចូលមើលចុងក្រោយ ១៨ មេសា ២០១៨)
- ភ្នំពេញ, ២០១៦, ក្រសួងបង្កើតប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដាររួម, គេហទំព័រភ្នំពេញប៉ុស្តិ៍, ០៧ កញ្ញា, https://www.postkhmer.com/សេដ្ឋកិច្ច/ក្រសួងបង្កើតប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម-និងពន្ធដារមួយ (បានចូលមើលចុងក្រោយ ១៨ មេសា ២០១៨)
- ភ្នំពេញ, ២០១៦, អគ្គនាយកដ្ឋានពន្ធដារ ប្រកាសពីការកែទម្រង់ច្បាប់ ដ៏ចម្រូងចម្រាស់, គេហទំព័រដើមអម្ពិល, ១៨ មេសា, https://www.dap-news.com/kh/ព័ត៌មានក្នុងប្រទេស/3020.html (បានចូលមើលចុងក្រោយ ១៨ មេសា ២០១៨)
- ភ្នំពេញ, ២០១៥, កំណែទម្រង់វិស័យពន្ធនៅកម្ពុជា, គេហទំព័រ KHMER TIMES, ០៨ វិច្ឆកា, https://www.khmertimeskh.com/news/17585/ (បានចូលមើលចុងក្រោយ ១៨ មេសា ២០១៨)
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល គង់ វិបុល (ប្រធានអគ្គនាយកដ្ឋានពន្ធដារ)បទ , សម្ភាសដោយBTV ,http://www.tax.gov.kh/videos.php?Id=5

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

១. ការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានពន្ធដារ.................................................

២. យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨.......................................

៣. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ......................................................

៤. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥.......................................................

៥. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦.......................................................

៦. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ ......................................................

៧. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ......................................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible].សហវ -ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការដំឡើងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មានស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់នូវការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅ ដូចខាងក្រោម÷

- រៀបចំទស្សនវិស័យ បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាគុណភាពនិងប្រសិទ្ធភាពនៃការបំពេញការងារពាក់ព័ន្ធនឹងពន្ធដារ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី ២
## ទស្សនវិស័យ បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ

**ប្រការ៤ ..**

អគ្គនាយកដ្ឋានពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានទស្សនវិស័យជាអង្គភាពសាធារណៈមួយដែលត្រូវបានទទួលស្គាល់ គោរព និងជឿទុកចិត្ត លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ។

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មផ្តល់នូវសេវាកម្មដែលមានគុណភាព ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សាមញ្ញភាព និងសមធម៌ ដើម្បីជំរុញអ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត ឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធដារប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**ប្រការ៥ ..**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ច ដូចតទៅ÷

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានស្តីពីពន្ធដារ កំណត់បញ្ជីឯកសារនិងលិខិតយុត្តិការនានា សម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ
- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្តល់សេវានិងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- កសាងកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- អនុវត្តវិធានការតឹងទារនិងទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់និងបទ-ប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំនិងអនុវត្តកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិននឹងពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**ប្រការ៦ ..**

អគ្គនាយកដ្ឋានពន្ធដារ គឺជារដ្ឋបាលសារពើពន្ធ ដែលមានប្រព័ន្ធចាត់តាំងឯកភាព ទទួលខុសត្រូវគ្រប់គ្រង និងត្រួតពិនិត្យទូទាំងប្រទេស នូវការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៧ ..**

អគ្គនាយកដ្ឋានពន្ធដារមានរចនាសម្ព័ន្ធដូចខាងក្រោម÷

**ក- ថ្នាក់កណ្តាល**

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ ថ្នាក់ស្មើនាយកដ្ឋាន
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ ថ្នាក់ស្មើនាយកដ្ឋាន។

**ខ- ថ្នាក់មូលដ្ឋាន**

នៅខណ្ឌនានានៃរាជធានីភ្នំពេញ និងខេត្តនីមួយៗ មានសាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាននៅថ្នាក់កណ្តាល និងអនុប្រធានសាខាពន្ធដារមួយចំនួន មានឋានៈស្មើប្រធានការិយាល័យនៅថ្នាក់កណ្តាល ជាជំនួយការ។

នៅស្រុក ក្រុង មានការិយាល័យពន្ធដារស្រុក ក្រុង មានថ្នាក់ស្មើការិយាល័យនៃសាខាពន្ធដារខេត្ត-ខណ្ឌ និងដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

**ប្រការ៨ ..**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការងាររដ្ឋបាល និងកិច្ចការទូទៅ។

ឧបសម្ព័ន្ធនៃប្រកាសលេខ...........សហវ.ប្រក
ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០១៧

# អង្គការលេខរបស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



## រាជរដ្ឋាភិបាលកម្ពុជា

# យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម

# ២០១៤ - ២០១៨

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលប្រែប្រួលដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងទៅនេះ ។ ប្រទេសយើងបានបញ្ចប់ដោយជោគជ័យនូវដំណាក់កាលអន្តរកាលឆ្លងពីសេដ្ឋកិច្ចផែនការមកសេដ្ឋកិច្ចទីផ្សារ, ពីរដ្ឋមួយដែលគ្រប់គ្រងដោយគណបក្សតែមួយ មកកាន់ប្រព័ន្ធមួយមានពហុបក្ស និងអភិបាលកិច្ចមួយដែលមានលក្ខណៈប្រជាធិបតេយ្យសេរី, ពីប្រទេសមួយមានសង្គ្រាម និងវិបត្តិនយោបាយ មកជាប្រទេសមួយប្រកបដោយសុខសន្តិភាពពេញលេញ និងប្រកបដោយចិរភាព ។ កម្ពុជាបានបញ្ចប់ជាស្ថាពរនូវទំព័រប្រវត្តិសាស្ត្រខ្មៅងងឹតពីអតីតកាលថ្មីៗរបស់ខ្លួន ហើយបោះជំហានទៅរកអនាគតកាលមួយដ៏ភ្លឺស្វាងត្រចះត្រចង់ ។ យើងបានបិទចោលទាំងស្រុងនូវទំព័រប្រវត្តិសាស្ត្រដ៏ជូចត់ដែលពោរពេញដោយចលាចល, អំពើហិង្សា, កលិយុគ និងប្រទូស្តរាយ ។ ព្រឹត្តិការណ៍នេះមិនមែនកើតឡើងដោយឯកឯងនោះទេ ។ វាគឺជាលទ្ធផលនៃការគិតគូរទុកជាមុន ដោយដាក់ចេញជាយុទ្ធសាស្ត្រ និងគោលនយោបាយ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រ និងគោលនយោបាយនេះ ។

ស្ថិតក្នុងបរិការណ៍ថ្មីនេះ កម្ពុជាបានការកសាងមូលដ្ឋានសេដ្ឋកិច្ចជាតិបានកាន់តែមានលក្ខណៈអំណោយផលដល់ការរីកលូតលាស់ទៅមុខទៀត ។ លើសពីនេះទៀត ក្នុងអំឡុងចុងទសវត្សរ៍ ៩០ ក្រោមនយោបាយ **«ឈ្នះ- ឈ្នះ»** កម្ពុជាមិនត្រឹមតែសម្រេចបានឯកភាពជាតិ, ការធានាបាននូវអធិបតេយ្យជាតិ, បូរណភាពទឹកដី, ស្មារតីមហាសាមគ្គីជាតិ និងសុខសន្តិភាពពេញលេញនៅទាំងប្រទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យម **៧,៧**% ក្នុងមួយឆ្នាំ ក្នុងអំឡុង ២ ទសវត្សរ៍កន្លងមក ហើយជីវភាព និងសុខុមាលភាពរបស់ប្រជាជនកាន់តែត្រូវបានលើកកម្ពស់គួរឱ្យកត់សម្គាល់ ក្នុងនោះអត្រានៃភាពក្រីក្រប្រមាណជាង ២% ក្នុងមួយឆ្នាំ ត្រូវបានកាត់បន្ថយ ។ ឈរលើវឌ្ឍនភាពជាបន្តបន្ទាប់នេះ ក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលកម្ពុជាកាន់តែមានឆន្ទៈដ៏មោះមុត ក្នុងការបន្តអភិវឌ្ឍប្រទេស ហើយបានដាក់ចេញនូវទស្សនាទាន និងចក្ខុវិស័យរបស់ខ្លួនក្នុងគោលដៅអភិវឌ្ឍកម្ពុជាឱ្យក្លាយទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍក្នុងឆ្នាំ ២០៥០ ។

យ៉ាងណាមិញ ចក្ខុវិស័យប្រកបដោយមហិច្ឆតានេះ និងចលនានៃការបន្តអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ឱ្យប្រកប-ដោយចិរភាពក្នុងបរិការណ៍ថ្មី ទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវតែមានលទ្ធភាព និងសមត្ថភាពខ្ពស់ ទាំងធនធានមនុស្ស និងមូលធន ក្នុងការបន្តនូវកិច្ចខិតខំប្រឹងប្រែងលើការងាររបស់ខ្លួន ។ ហេតុនេះ រាជរដ្ឋាភិបាលត្រូវរិះរកមធ្យោបាយ និងយុទ្ធសាស្ត្រឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ដើម្បីកៀរគរចំណូលឱ្យអស់លទ្ធភាព, អស់សក្តានុពល និងមានភាពស័ក្តិសិទ្ធិក្នុងគោលដៅបង្កើនភាពជាម្ចាស់ក្នុងការងារអភិវឌ្ឍរបស់ខ្លួន សម្រាប់ទ្រទ្រង់ និងឆ្លើយតបយ៉ាងសមស្របទៅនឹងកំណើននៃតម្រូវការចំណាយក្នុងគោលដៅសម្រេចឱ្យបាននូវការអភិវឌ្ឍវិស័យអាទិភាពនានា ដូចបានគូសបញ្ជាក់ក្នុង ***«យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៣»*** និង ***«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤- ២០១៨»*** ជាពិសេសធានាឱ្យបានកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំ ៧% ឱ្យប្រកបដោយចីរភាព, បរិយាប័ន្ន, សមធម៌ និងធន់នឹងវិបត្តិ ។

ឈរនៅលើមូលដ្ឋាននៃការគិតគូរនេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ និងដាក់ចេញនូវ ***«យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨»*** ដែលជាផ្នែកមួយនៃការបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ។ យុទ្ធសាស្ត្រនេះ ផ្តោតលើគោលការណ៍សំខាន់ចំនួន ៤ គឺ ***(១).*** ប្រមូលឱ្យអស់លទ្ធភាពនូវសក្តានុពលប្រមូលចំណូលដែលមាននាពេលបច្ចុប្បន្ន ***(២).*** មិនបង្កើតប្រភេទពន្ធថ្មី ***(៣).*** មិនដំឡើងអត្រាពន្ធ និងអាករ លើកលែងតែក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការការពារសុខភាព និង/ ឬ ការការពារបរិស្ថាន និង ***(៤).*** ធានាឱ្យបាននូវភាពងាយស្រួល សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូល ។ ក្នុងស្មារតីនេះ យើងសង្ឃឹមថា ការប្រមូលចំណូលចរន្តសរុបនឹងកើនបាន ០,៥% នៃផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ និងភាគរយនៃចំណូលចរន្តធៀបនឹងផលិតផលក្នុងស្រុកសរុបកើនពី ១៥,២% នៅក្នុងឆ្នាំ ២០១៤ ដល់ ១៧,៣៦% ក្នុងឆ្នាំ ២០១៨ និងឈានទៅសម្រេចបាននូវចក្ខុវិស័យដ៏មានមហិច្ឆតារបស់ខ្លួនយ៉ាងប្រាកដ ។

ចំពោះមុខ ខ្ញុំសង្ឃឹម និងជឿជាក់ថា គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពប្រមូលចំណូល ព្រមទាំងតួអង្គដែលពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន និងដៃគូអភិវឌ្ឍនឹងចូលរួមគាំទ្រ និងអនុវត្តការងារ ***យុទ្ធសាស្ត្រគៀរគរចំណូល*** នេះឱ្យសម្រេចបានជោគជ័យ តាមតួនាទី, ភារកិច្ច និងការទទួលខុសត្រូវដ៏ខ្ជាប់ខ្ជួនរបស់ខ្លួន និងរួមចំណែកអភិវឌ្ឍកម្ពុជាឱ្យមានវឌ្ឍនភាព និងភាពរុងរឿងជានិច្ចនិរន្តរ៍ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៥*

**ហ៊ុន សែន**

# មាតិកា

**១. សេចក្តីផ្តើម** ............ ១
**២. ចក្ខុវិស័យ** ............ ៣
**៣. គោលបំណង និងគោលដៅ** ............ ៣
**៤. អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ** ............ ៤
**៥. ការពង្រឹងរដ្ឋបាលចំណូល** ............ ៦
**៥.១ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ** ............ ៦
**៥.១.១ ការពង្រឹងមុខងារប្រតិបត្តិការស្នូល** ............ ៨
៥.១.១.១ ការចុះបញ្ជីអ្នកជាប់ពន្ធ ............ ៨
៥.១.១.២ ការផ្តល់សេវាអ្នកជាប់ពន្ធ ............ ៩
៥.១.១.៣ ការចាត់ចែងលិខិតប្រកាស ............ ១០
៥.១.១.៤ ការធ្វើសវនកម្ម ............ ១១
៥.១.១.៥ ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា ............ ១៣
**៥.១.២ ការពង្រឹងមុខងារគាំទ្រ** ............ ១៣
៥.១.២.១ ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ ............ ១៣
៥.១.២.២ ការគ្រប់គ្រងធនធានមនុស្ស ............ ១៥
៥.១.២.៣ បច្ចេកវិទ្យាព័ត៌មាន ............ ១៦
**៥.២ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ............ ១៧
**៥.២.១ ការពង្រឹងការត្រួតពិនិត្យ និងបញ្ចេញទំនិញ** ............ ១៩
៥.២.១.១ ការប្រកាសគយ ............ ១៩
ក. ការគ្រប់គ្រងឯកសារនាំចេញ-នាំចូល ............ ១៩
ខ. ការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ............ ២០
៥.២.១.២ ការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ ............ ២១
ក. ការគ្រប់គ្រងហានិភ័យ ............ ២១
ខ. ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ ............ ២២
៥.២.១.៣ សវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ............ ២៣
**៥.២.២ ការពង្រឹងយន្តការឆ្លងកាត់** ............ ២៤
៥.២.២.១ អំពើរត់គេចពន្ធ ............ ២៤
៥.២.២.២ តម្លៃគិតពន្ធគយ ............ ២៥
**៥.២.៣ ការពង្រឹងយន្តការគាំទ្រ** ............ ២៥
៥.២.៣.១ ប្រព័ន្ធអាស៊ីគូដា ............ ២៥

៥.២.៣.២ ប្រព័ន្ធបញ្ជរតែមួយជាតិ........................................................................................................ ២៦
៥.២.៣.៣ យន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន........................................................................ ២៧
៥.២.៣.៤ ផែនការអភិវឌ្ឍន៍ស្ថាប័ន................................................................................................................ ២៧
៥.២.៣.៥ ការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ.............................................................................. ២៨
៥.២.៣.៦ ការគ្រប់គ្រងធនធានមនុស្ស.......................................................................................................... ២៨
៥.២.៣.៧ សវនកម្មផ្ទៃក្នុង.............................................................................................................................. ២៩
**៥.៣ ការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ**.................................................................................... ៣០
**៥.៣.១ បរិការណ៍ និងបញ្ហាប្រឈមរួមនៃចំណូលមិនមែនសារពើពន្ធ**........................................................... ៣០
**៥.៣.២ វិស័យអាកាសចរណ៍ស៊ីវិល** ............................................................................................................ ៣៣
**៥.៣.៣ វិស័យទេសចរណ៍**.......................................................................................................................... ៣៤
**៥.៣.៤ ចំណូលពីអាករស្នាក់នៅ**................................................................................................................. ៣៥
**៥.៣.៥ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍** .............................................................................................. ៣៦
**៥.៣.៦ ចំណូលពីសម្បទានដីសេដ្ឋកិច្ច និងចំណូលពីផល-អនុផលព្រៃឈើ**................................................... ៣៧
**៥.៣.៧ ការជួលកោះ និងតំបន់ឆ្នេរសម្រាប់អភិវឌ្ឍតំបន់ទេសចរណ៍** ................................................................. ៣៩
**៥.៣.៨ ចំណូលពីសហគ្រាសសាធារណៈ**...................................................................................................... ៣៩
**៥.៣.៩ គ្រឹះស្ថានសាធារណៈរដ្ឋបាល**........................................................................................................... ៤០
**៥.៣.១០ ធនធានធម្មជាតិ**.......................................................................................................................... ៤២
**៥.៣.១១ ចំណូលពីឯកជនភាវូបនីយកម្ម (ការលក់ -ដោះដូរ) និងការជួលទ្រព្យសម្បត្តិរដ្ឋ**................................. ៤៣
**៥.៣.១២ ចំណូលពីកាស៊ីណូ**........................................................................................................................ ៤៤
**៥.៣.១៣ ចំណូលពីការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ** (C/O) ......................................................... ៤៥
**៥.៣.១៤ ចំណូលពីសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ** ........................................................................ ៤៥
**៦. ការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន** ........................................................................ ៤៧
**៦.១. ការកែលម្អប្រព័ន្ធសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**.............................................................. ៤៧
**៦.២ ការពង្រឹងយន្តការស្ថាប័ន**................................................................................................................. ៤៧
**៦.៣. ការកែលម្អគោលនយោបាយ និងក្របខ័ណ្ឌអនុវត្តលើចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ មួយចំនួន** ..................................................................................................................................... ៤៩
**៦.៣.១ អាករពិសេសលើទំនិញ និងសេវាមួយចំនួន**........................................................................................ ៤៩
**៦.៣.២ អាករលើតម្លៃបន្ថែម** ......................................................................................................................... ៥០
**៦.៣.៣ របបម៉ៅការ**..................................................................................................................................... ៥១
**៦.៣.៤ ពិនិត្យឡើងវិញរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ**............................................................ ៥២
**៦.៣.៥ កិច្ចព្រមព្រៀងពន្ធអន្តរជាតិ** ................................................................................................................ ៥២
**៦.៣.៦ ពន្ធលើអចលនទ្រព្យ**......................................................................................................................... ៥៣

**៦.៣.៧ ពន្ធលើចំណូលរូបវន្តបុគ្គល....................................................................................................................៥៤**
**៦.៣.៨ ពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ....................................................................................................៥៤**
**៦.៣.៩ ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពន្ធដារ..................................................................................................៥៥**
**៦.៣.១០ ការបាត់បង់ចំណូលពន្ធគយពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី..................................................................៥៥**
**៦.៣.១១ ការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ.......................................................................................................................... ៥៦**
**៧. ការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ.......................................................................................................... ៥៧**
**៨. សេចក្ដីសន្និដ្ឋាន..........................................................................................................................................៦១**
**ឧបសម្ព័ន្ធ.................................................................................................................................................... ៦២**
ឧបសម្ព័ន្ធ ១: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ......................... ៦២
ឧបសម្ព័ន្ធ ២: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា.......៧២
ឧបសម្ព័ន្ធ ៣: វិធានការសំខាន់ៗក្នុងការពង្រឹងរដ្ឋបាលចំណូលមិនមែនសារពើពន្ធ...................................៨១
ឧបសម្ព័ន្ធ ៤: វិធានការសំខាន់ៗក្នុងការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន................. ១០៤

# ១. សេចក្តីផ្តើម

**១.** នៅក្នុងអំឡុងមួយទសវត្សរ៍ចុងក្រោយនេះ ព្រះរាជាណាចក្រកម្ពុជាបាននិងកំពុងក្រេបជញ្ជក់នូវផ្លែផ្កានៃសន្តិភាព, ឯកភាពជាតិ និងស្ថិរភាពនយោបាយ ដែលជាសមិទ្ធផលប្រវត្តិសាស្ត្រនៃគោលនយោបាយឈ្នះឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លើមូលដ្ឋាននេះ ក្នុងទសវត្សរ៍កន្លងទៅ កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ប្រមាណ ៨% ក្នុងមួយឆ្នាំ និងការកាត់បន្ថយភាពក្រីក្រជាង ២% ក្នុងមួយឆ្នាំ ដែលជាសមិទ្ធផលគួរជាទីមោទនៈមួយ ក្នុងចំណោមបណ្តាប្រទេសដែលមានការអភិវឌ្ឍទាបនានាលើសកលលោក។ ដើម្បីបន្តធានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពទាំងនេះ ក្នុងទិសដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ក៏ដូចជាដើម្បីធានាស្ថិរភាព និងចីរភាពថវិកាសម្រាប់បម្រើសេចក្តីត្រូវការនៃចំណាយសាធារណៈចាំបាច់នានា ការពង្រឹងការប្រមូលចំណូលក្នុងស្រុកនឹងដើរតួនាទីជាគន្លឹះដ៏សំខាន់បំផុតមួយ។ នាពេលបច្ចុប្បន្ន នៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ចំណូលក្នុងស្រុកត្រូវបានទទួលស្គាល់ថាជាប្រភពធនធានមួយដ៏មានសារៈសំខាន់សម្រាប់ធានាចីរភាពនៃការអភិវឌ្ឍ ខណៈដែលជំនួយហិរញ្ញប្បទានពីខាងក្រៅត្រូវបានរំពឹងថានឹងមានទំហំមិនគ្រប់គ្រាន់ និងមានភាពមិនប្រាកដប្រជា ដែលអាចប៉ះពាល់ដល់ភាពជាម្ចាស់ពេញលេញក្នុងការគ្រប់គ្រងធនធានឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ថែមទៀត។

**២.** ដូចបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** នៅក្នុងបរិការណ៍ដែលកំពុងមានការផ្លាស់ប្តូរក្នុងតំបន់ និងសកលលោកជាពិសេសដំណើរផ្លាស់ប្តូរនៅក្នុងប្រទេសទាំងក្នុងវិស័យសេដ្ឋកិច្ច, សង្គម និងប្រជាសាស្ត្រ កម្ពុជាមានតម្រូវការចាំបាច់ក្នុងការកសាងប្រព័ន្ធចំណូលថវិកាជាតិមួយរឹងមាំប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ម៉្យាងដើម្បីធានាបាននូវមូលដ្ឋានអនុគ្រោះដល់ការធ្វើធុរកិច្ច និងការវិនិយោគ និងម្យ៉ាងទៀត ដើម្បីកសាងប្រភពចំណូលជាក់លាក់ និងមានស្ថិរភាព សំដៅឆ្លើយតបទៅនឹងការកើនឡើងនៃសេចក្តីត្រូវការចំណាយ សម្រាប់ធានានិរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ និងសម្រាប់ការអភិវឌ្ឍដូចជា ការកសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ការពង្រឹងវិស័យអប់រំ, ការបណ្តុះ-បណ្តាលជំនាញដល់យុវជន និងយុវនារី, ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាល, ការរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវសំណាញ់សុវត្ថិភាពសង្គម និងការពង្រឹងគុណភាពនៃការផ្តល់សេវាសាធារណៈ។ល។ ប្រការទាំងអស់នេះមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធានាបាននូវកំណើនសេដ្ឋកិច្ច ដែលមានលក្ខណៈបរិយាប័ន្ន និងចីរភាពព្រមទាំងការកាត់បន្ថយនូវភាពក្រីក្រ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។ ទន្ទឹមនេះ ការចាកចេញរបស់កម្ពុជាពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនឹងធ្វើឱ្យកម្ពុជាបាត់បង់ជាបណ្តើរៗនូវហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានសម្បទាន។ លើសពីនេះ សភាពការណ៍សេដ្ឋកិច្ចនៅក្នុងតំបន់ និងសកលលោក ពិសេសការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ព្រមទាំងការចូលរួមបង្កើតសហគមន៍សេដ្ឋកិច្ចតំបន់ ដូចជាសហគមន៍សេដ្ឋកិច្ចអាស៊ាន ២០១៥ ជាដើម នឹងធ្វើឱ្យប្រទេសកម្ពុជាបាត់បង់ចំណូលពន្ធពាណិជ្ជកម្មក្រៅប្រទេសមួយផ្នែកថែមទៀតផងដែរ។ ដូច្នេះ កត្តាទាំងនេះទាមទារឱ្យកម្ពុជាខិតខំប្រឹងប្រែងដោយខ្លួនឯងក្នុងការកៀរគរចំណូលទាំងរយៈពេលខ្លី និងមធ្យមឱ្យបានច្រើនថែមទៀត ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការដូចពោលខាងលើ។

៣. ក្នុងរយៈពេលកន្លងមកនេះ តាមរយៈការដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់លើការកៀរគរចំណូលបន្ថែម ដែលធ្វើឱ្យចំណូលក្នុងស្រុកមានការកើនឡើងជាលំដាប់។ ជាក់ស្តែង កិច្ចខិតខំប្រឹងប្រែងពង្រីកមូលដ្ឋានពន្ធ និងការកែលម្អអត្រាពន្ធ បានធ្វើឱ្យចំណូលចរន្តកើនឡើងគួរឱ្យកត់សម្គាល់ពី ១០,២៧% នៃ ផលិតផលក្នុងស្រុកសរុប (ផសស) នៅឆ្នាំ ២០០៤ ទៅ ១៥,០៤% នៃ ផសស នៅឆ្នាំ ២០១៣ តាមអត្រាកំណើនជាមធ្យម ១៧% ក្នុង ១ ឆ្នាំ។ ក្នុងនោះ ចំណូលសារពើពន្ធក៏បានកើនឡើងជាលំដាប់ផងដែរពី ៨,៤៦% នៃ ផសស ទៅ ១២,៦៩% នៃ ផសស ក្នុងអំឡុងឆ្នាំ ២០០៤-២០១៣។ ប៉ុន្តែចំណូលដែលប្រមូលបានរបស់កម្ពុជា នៅតែមានកម្រិតទាបនៅឡើយធៀបជាមួយប្រទេសនៅក្នុងតំបន់អាស៊ាន និងប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែលគ្នា។ កម្រិតចំណូលទាបនេះបណ្តាលមកពីមូលហេតុមួយចំនួន រួមមាន : (១)- មូលដ្ឋានពន្ធតូចចង្អៀតដោយសារតែរចនាសម្ព័ន្ធសេដ្ឋកិច្ចមិនមានលក្ខណៈទូលាយ និងឧស្សាហកម្មនៅមិនទាន់បានធ្វើពិពិធកម្ម, (២)- វប្បធម៌បង់ពន្ធ និងការគោរពច្បាប់នៅមានកម្រិត, (៣)- រដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធនៅទន់ខ្សោយ និង (៤)- កំណើននៃការលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

៤. ស្ថិតក្នុងបរិការណ៍នេះ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានរៀបចំឡើងដើម្បីកំណត់ចក្ខុវិស័យ, គោលបំណង និងគោលដៅ, អភិក្រម, វិធានការកែទម្រង់រដ្ឋបាល, ការកែលម្អគោល-នយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍កម្ពុជានាពេលបច្ចុប្បន្ន និងក្នុងរយៈពេលមធ្យមខាងមុខ។

## ២. ចក្ខុវិស័យ

**៥.** ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ គឺផ្សារភ្ជាប់នឹងចក្ខុវិស័យនៃការអភិវឌ្ឍកម្ពុជា ដោយផ្ដោតលើការប្រមូលចំណូលក្នុងស្រុកឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។ កម្ពុជាមានចក្ខុវិស័យសម្រេចឱ្យបាននូវឋានៈ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយចំណូលសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំនឹងកើនឡើងដល់រង្វង់ ៤.០០០ ទៅ ៥.០០០ ដុល្លារអាមេរិកនៅឆ្នាំ ២០៣០ តាមរយៈការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ដែលមានមូលដ្ឋានរឹងមាំ និងភាពធន់ខ្ពស់, សមធម៌នៃការបែងចែកផ្លែផ្កានៃកំណើន, ការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាបានប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ដែលមានបរិយាប័ន្ន, ផ្ដល់ឱកាសស្មើគ្នា និងប្រកបដោយយុត្តិធម៌។ ក្នុងន័យនេះ ចំណូលក្នុងស្រុករបស់កម្ពុជានឹងក្លាយជាគ្នាស់យ៉ាងសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ការផ្ដល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុងក្របខ័ណ្ឌនៃប្រព័ន្ធថវិកាជាតិដ៏សមស្របមួយ។ ម៉្យាងទៀត ការកៀរគរចំណូលឱ្យអស់សក្ដានុពល គឺជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍប្រទេស និងបំពេញឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការនៃចំណាយសាធារណៈចាំបាច់នានា ដើម្បីចូលរួមវិភាគទានដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យខាងលើ។

## ៣. គោលបំណង និងគោលដៅ

**៦.** យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានគោលបំណងពង្រឹងរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ និងលើកកម្ពស់វប្បធម៌បង់ពន្ធ និងការគោរពច្បាប់ ដើម្បីពង្រឹងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព, ឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចទីផ្សារដែលកំពុងលូតលាស់ និងការកើនឡើងនៃចំនួនអ្នកបង់ពន្ធ ក៏ដូចជាភាពស្មុគស្មាញនៃសកម្មភាពធុរកិច្ចក្នុងសម័យទំនើប ព្រមទាំងផ្ដល់ភាពងាយស្រួលដល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវការផ្ដល់សេវាជូនអ្នកបង់ពន្ធ, រួមចំណែកកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន, និងធានាសមធម៌ និងយុត្តិធម៌សម្រាប់ពលរដ្ឋទាំងអស់។

**៧.** ដើម្បីសម្រេចគោលបំណងខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានគោលដៅដូចតទៅ : (១)- ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិចបំផុត ០,៥ ពិន្ទុភាគរយ បន្ថែមលើផលធៀបរវាងចំណូលចរន្តនឹងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដោយត្រូវកើនពី ១៥,១៨% នៅឆ្នាំ ២០១៤ ដល់ ១៧,៣៥% នៅឆ្នាំ ២០១៨, (២)- ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍន៍ជាតិដែលស្របនឹង **យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣** និងដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នាពេលខាងមុខ, (៣)- ពង្រីកលំហថវិកា ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, គ្រប់គ្រងបំណុលប្រកបដោយចីរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស និង (៤)- បង្កើនធនធានថវិកាសម្រាប់តម្រូវការបន្ទាន់, ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត។

## ៤. អភិក្រមនៃការរៀបចំយុទ្ធសាស្ត្រ

៨. យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមានអភិក្រមផ្អែកលើគោលការណ៍ធំៗចំនួនបួនគឺ : (១)- ប្រមូលឱ្យអស់លទ្ធភាពនូវសក្ដានុពលចំណូលដែលមាននាពេលបច្ចុប្បន្ន, (២)- មិនបង្កើតប្រភេទពន្ធថ្មី, (៣)- មិនដំឡើងអត្រាពន្ធ និងអាករ លើកលែងតែនៅក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល និងការការពារសុខភាព និង/ឬការការពារបរិស្ថាន និង (៤)- ធានាឱ្យបាននូវភាពងាយស្រួល, សមធម៌ និងយុត្តិធម៌ ព្រមទាំងធានាប្រសិទ្ធភាព, តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូល។

៩. ផ្អែកលើគោលការណ៍ធំៗខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនឹងផ្ដោតលើការងារកែទម្រង់ ៤ យ៉ាងគឺ : (១)- ការលើកកម្ពស់វប្បធម៌បង់ពន្ធ, (២)- ការកែលម្អការផ្ដល់សេវាបង់ពន្ធ, (៣)- ការកែលម្អរដ្ឋបាលសារពើពន្ធ និងមិនមែនសារពើពន្ធ និង (៤)- ការកែលម្អអភិបាលកិច្ចសារពើពន្ធ និងមិនមែនសារពើពន្ធ ។

១០. ដើម្បីសម្រេចបាននូវចក្ខុវិស័យ, គោលបំណង, គោលដៅ និងគោលការណ៍ធំៗខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមត្រូវបានរៀបចំឡើងដោយផ្អែកលើសសរស្ដម្ភបី រួមមាន÷

- ***សសរស្ដម្ភទីមួយគឺការពង្រឹងរដ្ឋបាលចំណូល***: ជាមួយនឹងគោលការណ៍នៃការប្រមូលចំណូលសក្ដានុពលនាពេលបច្ចុប្បន្នឱ្យអស់លទ្ធភាព ការពង្រឹង និងការកែទម្រង់រដ្ឋបាល គឺជាការចាំបាច់សម្រាប់កាត់បន្ថយភាពទន់ខ្សោយ និងភាពមិនគ្រប់ជ្រុងជ្រោយនៃការគ្រប់គ្រងការប្រមូលចំណូល ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចទីផ្សារដែលកំពុងលូតលាស់, ការកើនឡើងនៃចំនួនអ្នកបង់ពន្ធ, ការកើនឡើងឥតឈប់ឈរនៃភាពស្មុគស្មាញនៅក្នុងសកម្មភាពពាណិជ្ជកម្ម និងការវិវត្តនៃកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ។ ការពង្រឹងរដ្ឋបាលនឹងផ្ដោតទៅលើបញ្ហាប្រឈមធំៗ ដែលមាននៅក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ហើយលើកជាវិធានការជាក់ស្ដែងដោយមានកំណត់ពេលវេលាច្បាស់លាស់សម្រាប់អនុវត្តឱ្យបានសម្រេច ដើម្បីដោះស្រាយបញ្ហាប្រឈមនីមួយៗប្រកបដោយប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិ។
- ***សសរស្ដម្ភទីពីរគឺការកែលម្អគោលនយោបាយចំណូល និងក្របខ័ណ្ឌស្ថាប័ន*** : ជាមួយនឹងការពង្រឹងរដ្ឋបាល ការកែលម្អគោលនយោបាយក៏ជាកត្តាគន្លឹះមួយនៅក្នុងការពង្រឹងប្រសិទ្ធភាពនៃការកៀរគរចំណូលផងដែរ។ ទោះបីជារួម ប្រភេទពន្ធថ្មីមិនត្រូវបានបង្កើត ហើយអត្រាពន្ធ និងអាករមិនត្រូវបានដំឡើងក៏ដោយក៏ប្រសិទ្ធភាពនៃការប្រមូលចំណូលតម្រូវឱ្យមានការកែលម្អគោលនយោបាយមួយចំនួន ដូចជា អាករពិសេស, អាករលើតម្លៃបន្ថែម, របបម៉ៅការ, កាតព្វកិច្ចពន្ធអន្តរជាតិ, ពន្ធលើអចលនទ្រព្យ និងរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ។ល។
- ***សសរស្ដម្ភទីបីគឺការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ***: ការអនុវត្តយុទ្ធសាស្ត្រនេះទាមទារឱ្យមានរចនាសម្ព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាក់លាក់។ ក្នុងន័យនេះ រចនាសម្ព័ន្ធត្រួតពិនិត្យ និងវាយតម្លៃត្រូវបង្កើតឡើងដោយរួមមាន គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលសារពើពន្ធ និងគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដែលមានតួនាទី និងភារកិច្ចច្បាស់លាស់។ ទន្ទឹមនេះ ដើម្បីវាយតម្លៃលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នប្រមូលចំណូលទាំងអស់ យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនឹងដាក់ចេញនូវសូចនាករតាមវិធានការនីមួយៗ និងសូចនាករលទ្ធផលនៃការប្រមូលចំណូលជាក់ស្ដែងតាមមុខចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដោយបញ្ជាក់អំពីពេលវេលាអនុវត្តច្បាស់លាស់។

រូបភាព ១: អភិក្រមនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨



# ៥. ការពង្រឹងរដ្ឋបាលចំណូល

**១១.** ការពង្រឹងរដ្ឋបាលចំណូល គឺជាការងារដ៏សំខាន់នៅក្នុងប្រទេសនីមួយៗ។ គោលនយោបាយចំណូលមានសក្តានុពលក្នុងការបង្កើនចំណូល ប៉ុន្តែចំណូលដែលទទួលបានពិតប្រាកដ ភាគច្រើនពឹងផ្អែកទៅលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃរដ្ឋបាលចំណូល។ ហេតុនេះ ការពង្រឹងរដ្ឋបាលចំណូលមានវិសាលភាពគ្របដណ្តប់លើការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ[1], ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងការពង្រឹងរដ្ឋបាលក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ៥.១ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

**១២.** អគ្គនាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងដើម្បីប្រមូលពន្ធនិងអាករក្នុងស្រុក និងចូលរួមក្នុងការរៀបចំគោលនយោបាយសារពើពន្ធ, សេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រមូលពន្ធ និងអាករ។ កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែទម្រង់ពេញលេញសំខាន់ៗចំនួន ២ លើក លើប្រព័ន្ធពន្ធដារ គឺនៅឆ្នាំ ១៩៩៤ និងឆ្នាំ ១៩៩៧ ព្រមទាំងការកែទម្រង់បន្ទាប់បន្សំមួយចំនួនទៀតលើគោលនយោបាយសារពើពន្ធ និងរដ្ឋបាលសារពើពន្ធ។ ជាមួយនឹងការកែទម្រង់ទាំងនេះ ការប្រមូលចំណូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយនេះមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយមានអត្រាកំណើនមធ្យមប្រចាំឆ្នាំប្រមាណជាង ២០% (រូបភាព ២)។ ចំណូលពន្ធដារសរុបរបស់អគ្គនាយកដ្ឋានពន្ធដារធៀបនឹង ផសស បានកើនឡើងប្រមាណ ៣ ដង គឺពី ១,៩% នៅឆ្នាំ ២០០២ ដល់ ៥,៨% នៅឆ្នាំ ២០១៣។ ចំណូលពន្ធដារគិតជាសមាមាត្រនៃចំណូលពន្ធសរុបបានកើនពី ២៧% នៅឆ្នាំ ២០០២ ដល់ ៤៦% នៅឆ្នាំ ២០១៣។

**រូបភាព ២៖ សមិទ្ធផលនៃការប្រមូលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ (២០០២-២០១៣)**




*ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

---

[1] អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ជាស្ថាប័នចំណុះក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**១៣.** សមិទ្ធផលទាំងនេះសម្រេចបានដោយសារកំណើនខ្ពស់របស់ប្រភេទពន្ធសំខាន់ៗដូចជា អាករលើតម្លៃបន្ថែមក្នុងស្រុក, ពន្ធលើប្រាក់ចំណេញ, អាករពិសេសក្នុងស្រុក, ពន្ធលើប្រាក់បៀវត្សរ៍, និងចំណូលពន្ធពីថ្នាក់ក្រោមជាតិ។ ក្នុងចំណោមប្រភេទពន្ធទាំងអស់ ដែលប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ អាករលើតម្លៃបន្ថែមក្នុងស្រុក និងពន្ធលើប្រាក់ចំណេញបានរួមចំណែកប្រមាណជាង ៦២% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ ២០១៣។ ប្រភេទពន្ធទាំងនេះត្រូវបានរំពឹងថានឹងបន្តល្បឿនកំណើនក្នុងរយៈពេលមធ្យមខាងមុខ ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់, កំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល, កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែ-ទម្រង់ជាបន្តបន្ទាប់ទៀតរបស់អគ្គនាយកដ្ឋានពន្ធដារនាពេលអនាគត។

**១៤.** អគ្គនាយកដ្ឋានពន្ធដារគ្រប់គ្រងការប្រមូលពន្ធតាមមុខងារ និងតាមប្រភេទអ្នកជាប់ពន្ធ។ ការគ្រប់គ្រងតាមមុខងារត្រូវបានបែងចែកជាមុខងារប្រតិបត្តិការស្នូល ដែលរួមមាន : (១)- ការចុះបញ្ជីអ្នកជាប់ពន្ធ, (២)- ការផ្តល់សេវាអ្នកជាប់ពន្ធ, (៣)- ការចាត់ចែងលិខិតប្រកាស, (៤)- ការធ្វើសវនកម្ម និង (៥)- ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា និងមុខងារគាំទ្រ ដែលរួមមាន : (១)- ការពង្រឹងការគ្រប់គ្រង និងរចនាសម្ព័ន្ធ, (២)- ការគ្រប់គ្រងធនធានមនុស្ស និង (៣)- បច្ចេកវិទ្យាព័ត៌មាន។

**១៥.** ជាមួយគ្នានេះ អ្នកជាប់ពន្ធត្រូវបានបែងចែកជាបីប្រភេទគឺ អ្នកជាប់ពន្ធធំ, អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធតូច។ អ្នកជាប់ពន្ធធំសំដៅដល់សហគ្រាស ដែលជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់, សាខាក្រុមហ៊ុនបរទេស និងសហគ្រាសផ្សេងទៀត ដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១.០០០ លានរៀលឡើងទៅ។ នៅឆ្នាំ ២០១៣ អ្នកជាប់ពន្ធធំទាំងនេះ គឺជាប្រភពចំណូលពន្ធដារប្រមាណជា ៨០% នៃចំណូលពន្ធសរុបរបស់អគ្គនាយក-ដ្ឋានពន្ធដារ។ ចំណូលពន្ធដែលប្រមូលបានពីអ្នកជាប់ពន្ធធំជាងគេទាំង ១០០ ក្រុមហ៊ុនមានសមាមាត្រជាង ៦០% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារ។

**១៦.** អ្នកជាប់ពន្ធមធ្យម គឺសំដៅដល់អ្នកជាប់ពន្ធដែលមានផលរបរប្រចាំឆ្នាំលើសពី ៥០០ លានរៀលចំពោះការផ្គត់ផ្គង់ទំនិញ, ផលរបរលើសពី ២៥០ លានរៀលចំពោះការផ្គត់ផ្គង់សេវា ឬផលរបរលើសពី ១២៥ លានរៀល ចំពោះការផ្គត់ផ្គង់ទំនិញ និងសេវាជាមួយរដ្ឋ។ នៅឆ្នាំ ២០១៣ អ្នកជាប់ពន្ធមធ្យមទាំងនេះជាប្រភពចំណូលពន្ធប្រមាណ ១៩,៣% នៃចំណូលពន្ធសរុបរបស់អគ្គនាយកដ្ឋានពន្ធដារ។ អ្នកជាប់ពន្ធតូច គឺសំដៅដល់អ្នកជាប់ពន្ធម៉ៅការដែលមិនស្ថិតនៅក្នុងអ្នកជាប់ពន្ធធំ និងមធ្យម និងជាប្រភពចំណូលពន្ធប្រមាណ ០,៧% នៃចំណូលសរុបរបស់អគ្គ-នាយកដ្ឋានពន្ធដារ។

**១៧.** ទោះបីជាអត្រាកំណើនចំណូលពន្ធក្នុងស្រុកមានកម្រិតខ្ពស់ អនុបាតចំណូលពន្ធធៀបនឹង ផសសរបស់ប្រទេសកម្ពុជាមានកម្រិតទាបជាងប្រទេសដែលមានកម្រិតអភិវឌ្ឍន៍ប្រហាក់ប្រហែល ដោយសារកម្ពុជាមានមូលដ្ឋានកំណត់ពន្ធតូចនៅឡើយ និងវប្បធម៌បង់ពន្ធក៏នៅមានកម្រិតទាប។ ម្យ៉ាងវិញទៀត បើធៀបជាមួយបណ្តារដ្ឋបាលសារពើពន្ធរបស់ប្រទេសមួយចំនួននៅក្នុងតំបន់ រដ្ឋបាលសារពើពន្ធកម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនទាំងផ្នែកសមត្ថភាព, ចំនួនមន្ត្រី, ធនធានសម្ភារៈ និងធនធានបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រដល់ប្រតិបត្តិការទូទៅ។

**១៨.** ដើម្បីដោះស្រាយបញ្ហាប្រឈមធំៗដូចបានរៀបរាប់ខាងលើ ការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយក-ដ្ឋានពន្ធដារ នឹងផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ការកែលម្អមុខងារនីមួយៗនឹងផ្តល់ផលវិជ្ជមានដល់មុខងារដទៃទៀត។

**រូបភាព ៣ : គំនូសបំព្រួញការពង្រឹងរដ្ឋបាលចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ**




### ៥.១.១ ការពង្រឹងមុខងារប្រតិបត្តិការស្នូល

**១៩.** មុខងារប្រតិបត្តិការស្នូលគឺជាប្រភេទមុខងារ ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងប្រតិបត្តិការប្រមូលពន្ធដោយផ្ទាល់លើរូបវន្តបុគ្គលនិងនីតិបុគ្គល ដែលច្បាប់ស្ដីពីសារពើពន្ធកំណត់ថាត្រូវជាប់កាតព្វកិច្ចបង់ពន្ធ។ ដំណើរការល្អនៃមុខងារប្រតិបត្តិការស្នូល អាចជួយសម្រួលដល់ការគ្រប់គ្រងក្នុងអគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ មុខងារប្រតិបត្តិការស្នូល រួមមាន : (១)- ការចុះបញ្ជីអ្នកជាប់ពន្ធ, (២)- ការផ្ដល់សេវាអ្នកជាប់ពន្ធ, (៣)- ការចាត់ចែងលិខិតប្រកាស, (៤)- ការធ្វើសវនកម្ម និង (៥)- ការប្រមូលបំណុលពន្ធ និងបណ្ដឹងតវ៉ា។

#### ៥.១.១.១ ការចុះបញ្ជីអ្នកជាប់ពន្ធ

**២០.** ប្រព័ន្ធនៃការចុះបញ្ជីអ្នកជាប់ពន្ធពេញលេញមួយ ដែលគ្រប់គ្រងទិន្នន័យបានត្រឹមត្រូវ និងផ្ដល់លេខអត្តសញ្ញាណកម្មសារពើពន្ធតែមួយ មានសារៈសំខាន់សម្រាប់រដ្ឋបាលសារពើពន្ធ ដើម្បីធ្វើជាមូលដ្ឋានក្នុងការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការប្រមូលបំណុលពន្ធ និងការត្រួតពិនិត្យផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាពទៅលើអ្នកជាប់ពន្ធ។ បច្ចុប្បន្ន អ្នកជាប់ពន្ធចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារមានចំនួនសរុបប្រមាណ ៩០.៥៥០ សហគ្រាស។ ទន្ទឹមនេះ ដើម្បីពង្រឹងប្រព័ន្ធនៃការចុះបញ្ជីអ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារបានដំឡើងបណ្ដាញតភ្ជាប់តំបន់ទូលាយ (Wide Area Network-WAN) ដើម្បីបញ្ជូនព័ត៌មាន និងទិន្នន័យអ្នកជាប់ពន្ធពីសាខាពន្ធដារខណ្ឌចំនួន ៧ (ជំហានទី១) និងខេត្តចំនួន ១៦ (ជំហានទី២) មកប្រមូលផ្ដុំនៅអគ្គនាយកដ្ឋានពន្ធដារ។

**២១.** ប្រសិទ្ធភាពនៃការចុះបញ្ជី និងការគ្រប់គ្រងបញ្ជីអ្នកជាប់ពន្ធនៅមានកម្រិត ដោយសារបញ្ហាប្រឈមមួយចំនួន ដូចជា : (១)- ការបញ្ជូនទិន្នន័យលើការចុះបញ្ជីអ្នកជាប់ពន្ធមកថ្នាក់កណ្ដាលនៅមិនទាន់មានលក្ខណៈស្វ័យប្រវត្តិ និងទាន់ពេលវេលា ដោយសារគម្រោងជំហានទី ២ នៅមិនទាន់បញ្ចប់នៅឡើយ, (២)- ព័ត៌មានអំពីក្រុមហ៊ុនមួយចំនួនមិនត្រឹមត្រូវ (ដូចជាអាសយដ្ឋានរបស់ក្រុមហ៊ុនពុំបានកំណត់ច្បាស់លាស់) ដោយសារការផ្ដល់ព័ត៌មានមិនច្បាស់លាស់ពីក្រសួងពាណិជ្ជកម្ម និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗ និង (៣)- ការខកខានមិនបានលុបចេញពីបញ្ជីអ្នកជាប់ពន្ធ (Deregistration) បន្ទាប់ពីបានធ្វើការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីចំនួនពីរលើកក្នុងឆ្នាំ ២០០២ និង ២០០៥ ចំពោះក្រុមហ៊ុនមួយចំនួនដែលបានបាត់ខ្លួន ឬមិនដាក់លិខិតប្រកាស។

**២២.** ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការមួយចំនួននៅក្នុងរយៈពេលខ្លី ដូចខាងក្រោម÷

- បង្កើតប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីក្រុមហ៊ុនតាមរយៈប្រព័ន្ធប្រមូលផ្ដុំទិន្នន័យនៅថ្នាក់កណ្ដាល,

- ធ្វើបច្ចុប្បន្នកម្មបញ្ជីអ្នកជាប់ពន្ធឱ្យបានទៀងទាត់ និងទាន់ពេលវេលា ពិសេសបន្តការងារលុបចេញពីបញ្ជីចំពោះសហគ្រាសដែលបាត់ខ្លួន ឬសហគ្រាសមិនដាក់លិខិតប្រកាសបន្ទាប់ពីបានធ្វើការត្រួតពិនិត្យរួច,
- ចុះត្រួតពិនិត្យដល់ទីតាំងរបស់ក្រុមហ៊ុន ដែលស្នើសុំចុះបញ្ជីពន្ធដារ និងធ្វើយុទ្ធនាការទូទាំងប្រទេស ដើម្បីប្រមូលព័ត៌មានចុះបញ្ជីដោយចុះអង្កេតស្រាវជ្រាវតាមដងផ្លូវ, ទិន្នន័យពីតតិយជន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីបញ្ចូលអ្នកជាប់ពន្ធទៅក្នុងបញ្ជី ឬដើម្បីពិនិត្យផលរបរ ដែលត្រូវផ្ទេរពីរបបម៉ៅការទៅរបបស្វ័យប្រកាស,
- ធ្វើបច្ចុប្បន្នកម្មវិញ្ញាបនបត្រអាករលើតម្លៃបន្ថែម (អតប) ដែលបានចេញ និងត្រៀមផ្តល់ជូនថ្មីដែលមានសុវត្ថិភាពជាងមុន,
- ចូលរួមអនុវត្តយន្តការ "ដំបូលតែមួយ" ជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្រសួងពាណិជ្ជកម្ម ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់កិច្ចការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម។

### ៥.១.១.២ ការផ្តល់សេវាអ្នកជាប់ពន្ធ

**២៣.** ការផ្តល់សេវាដល់អ្នកជាប់ពន្ធជាការងារសំខាន់ដែលជួយពង្រឹងការគោរពច្បាប់ និងវប្បធម៌បង់ពន្ធ ព្រមទាំងពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលពន្ធ។ បច្ចុប្បន្ន ការផ្តល់សេវាអ្នកជាប់ពន្ធមានវឌ្ឍនភាពតាមរយៈការអនុវត្តផែនការពង្រឹងសេវាអ្នកជាប់ពន្ធ ដូចជា រៀបចំសិក្ខាសាលាផ្សព្វផ្សាយ, ឆ្លើយសំណួរផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរទៅអ្នកជាប់ពន្ធ, បណ្តុះបណ្តាលភ្នាក់ងារសេវាកម្មពន្ធដារ និងសាធារណជននៅសាលាជាតិពន្ធដារ, ផ្តល់ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងផ្សេងៗ, បទប្បញ្ញត្តិស្តីពីពន្ធដារ និងសៀវភៅណែនាំមួយចំនួន និងផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ទន្ទឹមនេះ ដើម្បីបន្តពង្រឹងអភិបាលកិច្ច អគ្គនាយកដ្ឋានពន្ធដារបានបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវតារាងតម្លៃ និងពេលវេលាផ្តល់សេវាសាធារណៈ ព្រមទាំងបានរៀបចំឱ្យមានកន្លែង ឬប្រអប់សំបុត្រទទួលបណ្តឹង ជាពិសេសក្នុងករណីមានការអនុវត្តខុសឆ្គងពីស្តង់ដារសេវា, ការយកកម្រៃលើសពីការកំណត់ ឬការយឺតយ៉ាវជាដើម។

**២៤.** ជាមួយនឹងវឌ្ឍនភាពខាងលើនេះ អគ្គនាយកដ្ឋានពន្ធដារនៅមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការផ្តល់សេវាអ្នកជាប់ពន្ធ ដូចជា : (១)- កង្វះផែនការយុទ្ធសាស្ត្ររួមដែលបង្ហាញពីទិសដៅ និងកម្មវិធីជាក់លាក់នៃការលើកកម្ពស់ដល់ការយល់ដឹងជាសកលនៃវប្បធម៌បង់ពន្ធ, (២)- ការផ្តល់ និងបែងចែកធនធាននៅមិនទាន់គ្រប់គ្រាន់សម្រាប់សកម្មភាពសេវាអ្នកជាប់ពន្ធ, (៣)- នត្ថិភាពនៃការិយាល័យពិគ្រោះយោបល់ពន្ធតាមទូរស័ព្ទបានកាត់បន្ថយលទ្ធភាពក្នុងការទទួលបានព័ត៌មានលម្អិតទាក់ទងនឹងការបង់ពន្ធ និង (៤)- ចំនួន និងសមត្ថភាពរបស់មន្ត្រីមិនទាន់ឆ្លើយតបទៅនឹងទំហំនៃការងារផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព។

**២៥.** ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តវិធានការ ដូចខាងក្រោម÷

***វិធានការរយៈពេលខ្លី :***

- រៀបចំ និងដាក់ឱ្យអនុវត្តផែនការផ្តល់សេវាអ្នកជាប់ពន្ធធំបំផុតចំនួន ១៥០,